# វិន័យសតិភាគទី ១០



រៀបរៀងដោយ

ព្រះករុណា

ព្រះគ្រូ ប៊ុត សាវង្ស

# ក្នុងម្លប់ព្រះធម៌ព្រះវិន័យ

ក្នុងបិដកលេខ ២៤ ទំព័រ ៤៧៧ នៅក្នុង **ធម្មចេតិយសូត្រ** ព្រះបាទបសេនទិកោសល បានសម្ដែងនូវចំណុចនៃសេចក្ដីជ្រះថ្លាក្នុងព្រះរតនត្រ័យរបស់ព្រះអង្គ ថ្វាយដល់ព្រះដ៏មានព្រះភាគ ដែលព្រះដ៏មានព្រះភាគទ្រង់ទទួលថាជាធម្មចេតិយ មានប្រយោជន៍ដ៏សំខាន់ និងជាខាងដើមនៃព្រហ្មចរិយធម៌ ព្រមទាំងព្រះអង្គទ្រង់ណែនាំឱ្យព្រះ ភិក្ខុសង្ឃសិក្សាទ្រទ្រង់ចាំទុកទៀតផង ។

ក្នុងចំណុចនៃសេចក្ដីជ្រះថ្លាទាំងនោះ មានចំណុចមួយបានពណ៌នាអំពីលក្ខណៈនៃការរស់នៅរបស់ព្រះភិក្ខុសង្ឃ ក្នុងព្រះពុទ្ធ-សាសនា ដែលមានសេចក្ដីទាំងស្រុងដូចតទៅ :

បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត ខ្ញុំព្រះអង្គដើរក្រឡឹងមើលអំពីសួនច្បារ ១ ទៅសួនច្បារ ១ អំពីឧទ្យាន ១ ទៅឧទ្យាន ១ ឃើញសមណព្រាហ្មណ៍ពួកមួយក្នុងទីនោះ ស្គាំងស្គម សៅហ្មង អាប់សម្បុរ កើតរោគលឿងស្លេកស្លាំង មានខ្លួនវវាមដោយសរសៃ មិនទំនងឱ្យពួកជនរមិលមើលជាប់ភ្នែកបាន ។





បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះយ៉ាងនេះថា លោកមានអាយុទាំងនេះ ទំនងជាប្រព្រឹត្តព្រហ្មចរិយធម៌ទាំងមិនត្រេកអរ ពុំនោះសោតលោកមានអាយុទាំងនោះ ធ្វើបាបកម្មណាមួយដ៏កំបាំង បានជាលោកមានអាយុទាំងនេះ ស្គម សៅហ្មង អាប់សម្បុរ កើតរោគលឿងស្លេកស្លាំង មានខ្លួនវវាមដោយសរសៃ មិនទំនងឱ្យជាប់ភ្នែកដល់ជនអ្នកមើល ។ ខ្ញុំព្រះអង្គក៏ចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយនិយាយយ៉ាងនេះថា ដូច-ម្ដេចបានជាលោកមានអាយុទាំងឡាយ ស្គម សៅហ្មង អាប់សម្បុរ កើតរោគលឿងស្លេកស្លាំង មានខ្លួនវវាមដោយសរសៃ មិនទំនងឱ្យជាប់ភ្នែកដល់ជនអ្នកមើលដូច្នេះ ។ សមណព្រាហ្មណ៍ទាំងនោះនិយាយយ៉ាងនេះថា បពិត្រមហារាជ យើងទាំងឡាយមានរោគជាប់តាមពូជមក។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញពួកភិក្ខុក្នុងសាសនានេះ មានចិត្តរីករាយក្រៃពេក មានចិត្តខ្ពស់បំផុត មានសភាពត្រេកអរក្រៃពេក មានឥន្ទ្រិយពេញលេញ មានសេចក្ដីខ្វល់-ខ្វាយតិច មានរោមសម្ងបហើយ ចិញ្ចឹមជីវិតដោយសារទានរបស់អ្នកដទៃ មានចិត្តមានសភាពដូចជាម្រឹគ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា លោកមានអាយុទាំងឡាយនេះ ដឹងនូវគុណវិសេសដទៃក្រៃលែងជាងកាលមុនក្នុង

សាសនារបស់ព្រះមានបុណ្យនោះ ដោយពិតហើយបានជាលោកមានអាយុទាំងនេះ មានចិត្តរីករាយក្រៃពេក មានចិត្តខ្ពស់បំផុត មានសភាពត្រេកអរក្រៃពេក មានឥន្ទ្រិយពេញលេញ មានសេចក្តីខ្វល់ខ្វាយតិច មានរោមសម្ងបហើយ ចិញ្ចឹមជីវិតដោយទានរបស់អ្នកដទៃ មានចិត្តមានសភាពដូចជាម្រឹគ។ បពិត្រព្រះអង្គដ៏ចម្រើន នេះឯងដែលនាំឱ្យខ្ញុំព្រះអង្គ បានយល់ធម៌ក្នុងសំណាក់ព្រះមានព្រះភាគថា ព្រះមានព្រះភាគត្រាស់ដឹងដោយប្រពៃមែន ព្រះសង្ឃជាសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃមែន ។

ក្នុងវិន័យបិដកលេខ ៩ ទំព័រ ៥៣ ពោលអំពីភិក្ខុមានការសង្រួមល្អ ។ សម័យនោះឯង មានភិក្ខុមួយរូបចាំវស្សាក្នុងដែនកាសី រួចហើយទៅកាន់ក្រុងសាវត្ថីដើម្បីគាល់ព្រះដ៏មានព្រះភាគ ក៏ដើរសំដៅទៅកិដាគិរីជនបទ ។ លុះវេលាព្រឹកឡើង ភិក្ខុនោះក៏ស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ ដើរចូលទៅកាន់កិដាគិរិជនបទដើម្បីបិណ្ឌបាត មានភ្នែកសង្រួម មានឥរិយាបថរម្យទម ឈានដើរទៅមុខ ឬថយក្រោយ ក្រឡេកមើលទៅមុខ ឬមើលចំហៀង បត់ដៃចូល ឬលាចេញ គួរឱ្យកើតសេចក្តីជ្រះថ្លា ។

ក្នុងបិដកលេខ ១៦ ទំព័រ ១៦៣ នៅក្នុង **មហាបរិនិព្វាន-សូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីសេចក្តីចម្រើនតែងមានប្រាកដ





ដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ មានដូចតទៅ :

កាលដែលវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ ចេញទៅមិនយូរប៉ុន្មាន ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរទៅឱ្យភិក្ខុទាំងអស់ដែលនៅអាស្រ័យក្នុងក្រុងរាជគ្រឹះ ប្រជុំគ្នាក្នុងឧបដ្ឋានសាលា ។ ព្រះអានន្ទដ៏មានអាយុ ទទួលព្រះបន្ទូលព្រះមានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយប្រជុំភិក្ខុសង្ឃទាំងអស់ដែលនៅអាស្រ័យក្នុងក្រុងរាជគ្រឹះ ក្នុងឧបដ្ឋានសាលា ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចឋិតនៅក្នុងទីសមគួរ ។ ព្រះអានន្ទដ៏មានអាយុ លុះឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃប្រជុំគ្នាហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសំគាល់នូវកាលគួរនឹងស្តេចទៅក្នុងកាលឥឡូវនេះ ។ លំដាប់នោះព្រះមានព្រះភាគ ទ្រង់ក្រោកអំពីអាសនៈ ហើយស្តេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលទុក ។ លុះព្រះមានព្រះភាគ គង់នៅហើយ ក៏ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹង

សម្តែងអបរិហានិយធម៌ ៧ ប្រការដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់ភាសិតនោះ ចូរប្រុងធ្វើទុកក្នុងចិត្តឱ្យល្អចុះ តថាគតនឹងសម្តែងប្រាប់ ។ ភិក្ខុទាំងឡាយនោះក៏ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រជុំគ្នារឿយៗ ប្រជុំគ្នាដោយច្រើន អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាលើកទីប្រជុំ ព្រមព្រៀងគ្នាធ្វើកិច្ចរបស់សង្ឃ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ ( អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនបញ្ញត្តសិក្ខាបទ ដែលតថាគតមិនបានបញ្ញត្តហើយ មិនដកសិក្ខាបទដែលតថាគតបញ្ញត្តហើយ កាន់តាម ប្រព្រឹត្តតាមសិក្ខាបទ ដែលតថាគតបញ្ញត្តហើយយ៉ាងណា អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងធ្វើ



សក្ការៈ គោរពរាប់អាន បូជាពួកភិក្ខុជាថេរៈអ្នកដឹងរាត្រី (ច្រើន ) បួសយូរ ជាបិតានៃសង្ឃ ជាបរិនាយករបស់សង្ឃ (ជាអ្នកណែនាំសង្ឃ) ទាំងរាប់អានជឿពាក្យដែលគួរស្តាប់របស់ភិក្ខុជាថេរៈទាំង-នោះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ )។ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមិនលុះក្នុងអំណាចតណ្ហា ជាធម្មជាតិនាំសត្វទៅក្នុងភពថ្មីទៀត ដែលកើតឡើងហើយអស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងមានសេចក្តីប្រាថ្នាក្នុងសេនាសនៈទាំងឡាយ ដែលតាំងនៅក្នុងព្រៃ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យ មិនមានឡើយ (អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើពួកភិក្ខុនឹងប្រុងស្មារតីក្នុងខ្លួនថា ធ្វើម្តេចហ្ន៎ ពួកសព្រហ្មចារី មានសីលធម៌ជាទីស្រឡាញ់ ដែលមិនទាន់មកដល់ ក៏សូមឱ្យនិមន្តមក ពួកសព្រហ្មចារីមានសីលធម៌ជាទីស្រឡាញ់ ដែលមកដល់ហើយ សូមឱ្យនៅជាសុខដូច្នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយ

សេចក្តីចម្រើនតែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ ) ។ ម្នាលភិក្ខុទាំងឡាយ បើអបរិហានិយធម៌ទាំង ៧ នេះ នឹងឋិតនៅក្នុងភិក្ខុទាំងឡាយ ឬថាភិក្ខុទាំងឡាយនឹងប្រតិបត្តិក្នុងអបរិហានិយធម៌ទាំង ៧ នេះ អស់កាលត្រឹមណា ម្នាលភិក្ខុទាំងឡាយសេចក្តីចម្រើន តែងមានប្រាកដដល់ពួកភិក្ខុ សេចក្តីសាបសូន្យមិនមានឡើយ (អស់កាលត្រឹមណោះ ) ។

ក្នុងអង្គុត្តរនិកាយ សត្តកនិបាត បិដកលេខ ៤៧ ទំព័រ ៣៩ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីធម៌មិនសាបសូន្យនេះដូចគ្នាដែរ ។

សេចក្តីទាំងប៉ុន្មានដូចដែលពុទ្ធបរិស័ទបានសិក្សាមកនេះ គឺជាលក្ខណៈខាងក្រៅ និងជាជីវិតរស់នៅជាពួក ជាក្រុមនៃសង្គមសង្ឃដែលគួរឱ្យជ្រះថ្លា ជាបន្តទៅ គឺភាពជាឥស្សរៈរបស់ចិត្ត និងសេចក្តីសុខស្ងប់ ។

ក្នុងបិដកលេខ ៣២ ទំព័រ ២៦៦ នៅក្នុង **នាគសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីភិក្ខុជាថេរៈមិនជាប់ជំពាក់ មិនវង្វេងមិនជ្រុលជ្រប់ក្នុងលាភសក្ការៈ ឧបមាដូចជាដំរីធំ សូមពុទ្ធបរិស័ទជ្រះថ្លា សិក្សាក្នុងព្រះសូត្រនោះទាំងស្រុងដូចតទៅ :

ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមាន-



ព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏ក្នុងសម័យនោះឯង មានភិក្ខុបួសថ្មីមួយរូបចូលទៅរកត្រកូលហួសវេលា ។ ភិក្ខុទាំងឡាយនិយាយនឹងភិក្ខុនោះ យ៉ាងនេះថា លោកមានអាយុ កុំចូលទៅរកត្រកូលហួសវេលាឡើយ ។ ភិក្ខុនោះ កាលបើពួកភិក្ខុនិយាយប្រាប់ ក៏បែរជាពោល យ៉ាងនេះថា អម្បាលយ៉ាងពួកភិក្ខុជាថេរៈទាំងនេះ ម្តេចគង់ សំគាល់នូវត្រកូល ថាគួរចូលទៅរកបាន នឹងបាច់និយាយថ្វីត្រឹមខ្ញុំករុណា ។ គ្រានោះឯង ភិក្ខុច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ មានភិក្ខុបួសថ្មីមួយរូប ចូលទៅរកត្រកូលហួសវេលា ពួកភិក្ខុបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុ កុំចូលទៅរកត្រកូលហួសវេលាឡើយ ភិក្ខុនោះ កាលបើពួកភិក្ខុនិយាយប្រាប់ ក៏បែរជានិយាយយ៉ាងនេះថា អម្បាលយ៉ាងពួកភិក្ខុជាថេរៈទាំងនេះ ម្តេចគង់សំគាល់នូវត្រកូល ថាគួរចូលទៅរកបាន នឹងបាច់ពោលទៅថ្វីត្រឹមខ្ញុំករុណា ។

ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយមក មានស្រះធំមួយ ក្នុងព្រៃរំលោង ដំរីទាំងឡាយតែងអាស្រ័យនៅនឹងស្រះធំនោះ ។ ដំរីទាំងនោះចុះទៅកាន់ស្រះនោះ ដកយកក្រអៅឈូក និងមើមឈូក ដោយប្រមោយ ហើយរលាស់ឱ្យស្អាតល្អ លាងឱ្យជ្រះភក់ហើយ ទើបបរិភោគ ឯសរីរៈនោះ របស់ដំរីទាំងនោះ ក៏មានសម្បុរល្អផង មានកម្លាំងផង ដំរីទាំងនោះក៏មិនដល់នូវមរណៈ ឬមិនដល់នូវទុក្ខស្មើរនឹងមរណៈ ព្រោះអាហារនោះជាហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានពួកកូនដំរីក្មេងសិក្សាតាមដំរីធំៗទាំងនោះឯង ក៏នាំគ្នាចុះទៅកាន់ស្រះនោះ ដកយកក្រអៅឈូកនិងមើមឈូកដោយប្រមោយ មិនបានរលាស់ឱ្យស្អាតល្អ មិនបានលាងនូវក្រអៅ និងមើមដែលមានភក់ចេញ ក៏បរិភោគទៅ សរីរៈនោះ របស់កូនដំរីក្មេងទាំងនោះ ក៏មិនមានសម្បុរល្អ មិនមានកម្លាំង កូនដំរីក្មេងទាំងនោះ ក៏ដល់នូវមរណៈ ឬដល់នូវទុក្ខស្មើរនឹងមរណៈ ព្រោះអាហារនោះជាហេតុ ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះមានឧបមេយ្យដូចពួកភិក្ខុជាថេរៈ ក្នុងសាសនានេះ ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត ថេរៈទាំងនោះសម្តែងធម៌ក្នុងស្រុកនិគមនោះៗ មានពួកគ្រហស្ថគេ





ជ្រះថ្លា ធ្វើនូវអាការជ្រះថ្លាចំពោះថេរៈទាំងនោះ ថេរៈទាំងនោះក៏មិនបានជាប់ចំពាក់ មិនបានវង្វេង មិនបានជ្រុលជ្រប់នឹងលាភនោះឡើយ ជាអ្នកឃើញទោស មានបញ្ញាសម្រាប់រើខ្លួន ទើបបរិភោគ សរីរៈនោះ របស់ថេរៈទាំងនោះ ក៏មានសម្បុរល្អផង មានកម្លាំងផង ថេរៈទាំងនោះ ក៏មិនដល់នូវមរណៈ ឬមិនដល់នូវទុក្ខស្មើរនឹងមរណៈ ព្រោះលាភនោះជាហេតុឡើយ ។

ម្នាលភិក្ខុទាំងឡាយ ចំណែកពួកភិក្ខុដែលសិក្សាតាមពួកភិក្ខុជាថេរៈនោះឯង ក៏ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត ភិក្ខុទាំងនោះក៏សម្តែងធម៌ក្នុងស្រុកឬនិគមនោះៗ ពួកគ្រហស្ថក៏មានសេចក្តីជ្រះថ្លា ធ្វើអាការជ្រះថ្លាចំពោះភិក្ខុទាំងនោះ ភិក្ខុទាំងនោះក៏ជាប់ចំពាក់ វង្វេង ជ្រុលជ្រប់នឹងលាភនោះ ជាអ្នកមិនឃើញទោស មិនមានបញ្ញាសម្រាប់រើខ្លួនហើយបរិភោគឡើយ សរីរៈនោះ របស់ភិក្ខុទាំងនោះ ក៏មិនមានសម្បុរល្អផង មិនមានកម្លាំងផង ភិក្ខុទាំងនោះតែងដល់នូវមរណៈ ឬដល់នូវទុក្ខស្មើរនឹងមរណៈ ព្រោះលាភនោះជាហេតុ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូច្នេះក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងទាំង-ឡាយ ជាអ្នកមិនជាប់ជំពាក់ មិនវង្វេង មិនជ្រុលជ្រប់ (នឹងលាភ)

ឡើយ ត្រូវជាអ្នកឃើញទោស ទាំងមានបញ្ញាសម្រាប់រើខ្លួនហើយ ទើបបរិភោគ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាង នេះចុះ ។

ព្រះពុទ្ធភាសិតនៅខាងចុងនៃ **អត្តទណ្ឌសូត្រ សុត្តនិបាត** បិដកលេខ ៥៤ ទំព័រ ៣១៧ ព្រះអង្គទ្រង់ត្រាស់សម្តែងថា :

អ្នកដែលមិនមានចិត្តញាប់ញ័រ ជាអ្នកដឹងច្បាស់ រមែងមិន មានការតាក់តែងនូវអភិសង្ខារឯណានីមួយឡើយ ហើយជាអ្នក ឃើញសេចក្តីក្សេមក្នុងទីទាំងពួង ។ អ្នកប្រាជ្ញ រមែងមិននិយាយ អួតខ្លួន ដោយមានមានះថា អញជាបុគ្គលស្មើគ្នា ក្នុងពួកបុគ្គល ស្មើគ្នា ថាអញជាបុគ្គលថោកទាប ក្នុងពួកបុគ្គលដែលថោកទាប ថាអញជាបុគ្គលប្រសើរ ក្នុងពួកបុគ្គលដែលប្រសើរ បុគ្គលនោះ ជាអ្នកស្ងប់ ប្រាសចាកសេចក្តីកំណាញ់ រមែងមិនប្រកាន់ មិន អន្ទះសា ។

ក្នុងបិដកលេខ ៥២ គម្ពីរឧទាន ទំព័រ ១៥៤ **កាឡិគោធា-ភទ្ទិយសូត្រ** បានសម្តែងអំពី **ព្រះភទ្ទិយៈ** ដែលបានចេញពី សក្យត្រកូលមកបួស ហើយឧទានថា ឱហ្ន៎ ! សុខអ្វីម្ល៉េះ ។ គួរ ពុទ្ធបរិស័ទរីករាយជ្រះថ្លាសិក្សាដូចតទៅ :

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ





ទ្រង់គង់នៅក្នុងវត្តអម្ពវ័ន ទៀបក្រុងអនុប្បយា ។ សម័យនោះ ព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្រនាងសាកិយានី ឈ្មោះកាឡិគោធា ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែង បន្លឺនូវឧទានរឿយៗថា ឱហ្ន៎ សុខអ្វីម្ល៉េះ ឱហ្ន៎ សុខអ្វីម្ល៉េះ ។ ពួក ភិក្ខុជាច្រើនរូបបានឮថា ព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្រនៃនាង សាកិយានី ឈ្មោះកាឡិគោធា ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺនូវឧទានរឿយៗថា ឱហ្ន៎ សុខ អ្វីម្ល៉េះ ឱហ្ន៎ សុខអ្វីម្ល៉េះ ដូច្នេះដែរ ។ លុះពួកភិក្ខុទាំងនោះបានឮ ហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះភទ្ទិយៈដ៏មានអាយុ ជា បុត្រនាងសាកិយានី ឈ្មោះកាឡិគោធា ប្រាកដជា អផ្សុកនឹង ប្រព្រឹត្តព្រហ្មចរិយធម៌ដោយពិត ព្រះភទ្ទិយៈដ៏មានអាយុនោះ នឹក រលឹកសេចក្តីសុខក្នុងរាជ្យរបស់លោក កាលនៅជាគ្រហស្ថអំពីដើម ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែង បន្លឺនូវឧទានរឿយៗថា ឱហ្ន៎ សុខអ្វីម្ល៉េះ ឱហ្ន៎ សុខអ្វីម្ល៉េះ ។ លំដាប់នោះ ពួកភិក្ខុជាច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក្រាប ទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះភទ្ទិយៈ

ដ៏មានអាយុ ជាបុត្រនៃនាងសាកិយានី ឈ្មោះកាឡិគោធា ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺនូវឧទានរឿយៗថា ឱហ្ន៎ សុខ អ្វីម្ល៉េះ ឱហ្ន៎ សុខអ្វីម្ល៉េះ ព្រះភទ្ទិយៈជាបុត្រនាងសាកិយានី ឈ្មោះកាឡិគោធា ប្រាកដជា អផ្សុកនឹងប្រព្រឹត្តព្រហ្មចរិយធម៌ដោយពិត ។ល។ ឱហ្ន៎ សុខអ្វីម្ល៉េះ ។

គ្រានោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុមួយរូបហើយបង្គាប់ថា ម្នាលភិក្ខុអ្នកចូលមក ចូរហៅភទ្ទិយភិក្ខុតាមពាក្យតថាគតថា នែអាវុសោភទ្ទិយៈ ព្រះសាស្តាទ្រង់ឱ្យហៅអ្នក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ រួចចូលទៅរកព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្រនាងសាកិ-យានី ឈ្មោះកាឡិគោធា លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្រនាងសាកិយានី ឈ្មោះកាឡិគោធាថា នែអាវុសោ ភទ្ទិយៈ ព្រះសាស្តាត្រាស់ហៅអ្នក ព្រះភទ្ទិយៈដ៏មានអាយុជាបុត្រនាងសាកិយានី ឈ្មោះកាឡិគោធា បានទទួលពាក្យភិក្ខុនោះថា អើអាវុសោ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំនូវព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះភទ្ទិយៈដ៏មានអាយុជាបុត្រនាងសាកិយានីឈ្មោះកាឡិគោធា អង្គុយក្នុងទីសមគួរ





ហើយ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភទ្ទិយៈ បានឮថា អ្នកទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានរឿយៗថា ឱហ្ន៎ សុខអ្វីម្ល៉េះ ឱហ្ន៎ សុខអ្វីម្ល៉េះ ដូច្នេះមែនឬ ។ ព្រះភទ្ទិយៈក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ម្នាលភទ្ទិយៈអ្នកពិចារណា ឃើញអំណាចប្រយោជន៍ដូចម្តេច បានជាចូលទៅនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានរឿយៗថា ឱហ្ន៎ សុខអ្វីម្ល៉េះ ឱហ្ន៎ សុខអ្វីម្ល៉េះ ដូច្នេះ។ បពិត្រព្រះអង្គដ៏ចម្រើន កាលពីដើមខ្ញុំព្រះអង្គនៅជាគ្រហស្ថសោយសុខក្នុងរាជ្យ ការរក្សាខាងក្នុងព្រះរាជវាំង គេបានចាត់ចែងល្អហើយ ការរក្សាខាងក្រៅព្រះរាជវាំង គេក៏ចាត់ចែងល្អហើយ ការរក្សាខាងក្នុងនគរ គេចាត់ចែងល្អហើយ ការរក្សាខាងក្រៅនគរ គេចាត់ចែងល្អហើយ ការរក្សាក្នុងជនបទ គេចាត់ចែងល្អហើយ ការរក្សាខាងក្រៅជនបទ គេចាត់ចែងល្អហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះឯង ដែលគេរក្សាគ្រប់គ្រងយ៉ាងនេះហើយ ក៏នៅតែភ័យភ្ញាក់ផ្អើលរង្កៀសតក់ស្លុត បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះខ្ញុំព្រះអង្គតែម្នាក់ឯង ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ក៏លែងភ័យ លែងភ្ញាក់ផ្អើល លែងតក់ស្លុតហើយ ជាអ្នកមានការខ្វល់ខ្វាយតិច ឥត

ព្រៃព្រួចរោម ចិញ្ចឹមជីវិតដោយបច្ច័យដែលអ្នកដទៃឱ្យ នៅដោយមានចិត្តដូចជាពួកម្រឹគ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណា ឃើញអំណាចប្រយោជន៍នេះហើយ ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានរឿយៗថា ឱហ្ន៎ សុខអ្វីម្ល៉េះ ឱហ្ន៎ សុខអ្វីម្ល៉េះ ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនេះហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា :

សេចក្តីក្រោធ មិនមានក្នុងចិត្តរបស់បុគ្គលណា បុគ្គលនោះឈ្មោះថា កន្លងផុតនូវសេចក្តីចម្រើន និងសេចក្តីវិនាស ទេវតាទាំងឡាយ កម្រនឹងបានឃើញបុគ្គល ដែលប្រាសចាកភ័យ បានប្រកបដោយសេចក្តីសុខ ឥតសោកនោះឡើយ ។

ក្នុងបិដកលេខ ៤១ ទំព័រ ៨៨ **ហត្ថកសូត្រ** ព្រះពុទ្ធអង្គទ្រង់សម្តែងអំពី បុគ្គលដែលមានបាបបន្សាត់ចោល និងមានទុក្ខរលត់ហើយ រមែងដេកជាសុខសព្វកាល ព្រះអង្គទ្រង់ត្រាស់សម្តែងចំពោះព្រះរាជកុមារព្រះនាម **ហត្ថកអាឡវកៈ** ក្នុងដែនអាឡវី ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

សម័យមួយ ព្រះមានព្រះភាគទ្រង់គង់លើកម្រាលស្លឹកឈើ ដែលជ្រុះក្នុងព្រៃផ្នង់ជិតផ្លូវគោ ក្នុងដែនអាឡវី ។ លំដាប់នោះឯង





ព្រះរាជកុមារព្រះនាមហត្ថកអាឡវកៈ ត្រាច់ទៅមកដើម្បីសម្រួលព្រះជង្ឃា ក៏បានឃើញព្រះមានព្រះភាគ ទ្រង់គង់លើកម្រាលស្លឹកឈើក្នុងព្រៃផ្នង់ជិតផ្លូវគោ លុះឃើញហើយក៏ចូលទៅគាល់ព្រះមានព្រះភាគហើយគង់ក្នុងទីសមគួរ ។ លុះហត្ថកអាឡវកៈគង់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ផ្ទំស្រួលទេឬ ។ ម្នាលកុមារ យ៉ាងហ្នឹងហើយ តថាគតបានសិងស្រួលហើយ ពួកជនណាដេកស្រួលក្នុងលោក បណ្តាជនទាំងនោះ តថាគតក៏ជាអ្នកសិងស្រួលមួយនឹងគេដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន រាត្រីក្នុងហេមន្តរដូវត្រជាក់ កាលក្នុង ៨ ថ្ងៃជាចន្លោះ (ខែមាឃនិងខែផល្គុន) ជាសម័យធ្លាក់ទឹកសន្សើម ផែនដីដែលត្រូវក្រចកជើងគោជាន់ខ្ទង់រដិបរដុបក៏រឹង កម្រាលស្លឹកឈើក៏ស្តើង អស់ទាំងស្លឹកឈើក៏រង្វើល សំពត់កាសាយៈក៏ត្រជាក់ខ្យល់វល់ដ៏ត្រជាក់ក៏បក់មក កាលបើយ៉ាងហ្នឹង ម្តេចក៏ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលកុមារ យ៉ាងហ្នឹងហើយ តថាគតបានសិងស្រួលហើយ ពួកជនណាដេកស្រួលក្នុងលោក បណ្តាជនទាំងនោះតថាគតក៏ជាអ្នកសិងស្រួលមួយនឹងគេដែរ ។ ម្នាលកុមារ បើដូច្នោះ តថាគតនឹងសួរអ្នកក្នុងដំណើរនុ៎ះ ថាបើអ្នកគាប់ចិត្តយ៉ាងណា គប្បីព្យាករនូវ

ដំណើរនោះយ៉ាងនោះចុះ ។ ម្នាលកុមារ អ្នកសំគាល់ហេតុនោះដូចម្តេច គហបតីឬគហបតិបុត្រក្នុងលោកនេះ មានផ្ទះកំពូលប្លូកលាបខាងក្រៅ ខ្យល់ចូលមិនរួច មានទ្វារដ៏ជិត មានបង្អួចបិទជិតក្នុងផ្ទះនោះ មានបល្ល័ង្កក្រាលដោយកម្រាលគោណកៈ ក្រាលដោយកម្រាលបដិកៈ ក្រាលដោយកម្រាលបដលិកៈមានកម្រាលដ៏ប្រសើរ ជាវិការនៃស្បែកឈ្លុស មានខ្នើយក្រហមទាំងពីរខាងព្រមទាំងពិតានក្រហម ទាំងប្រទីបប្រេងក៏ឆេះភ្លឺក្នុងផ្ទះនោះ មានប្រពន្ធ ៤ នាក់ នៅផ្គត់ផ្គង់បម្រើដោយសេចក្តីគាប់ចិត្ត ។ ម្នាលកុមារ អ្នកសំគាល់ហេតុនោះដូចម្តេច បុគ្គលនោះគួរដេកជាសុខឬទេ ឬអ្នកមានសេចក្តីយល់ក្នុងដំណើរនុ៎ះដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលនោះគួរដេកជាសុខ ពួកជនណាដេកជាសុខក្នុងលោក បណ្តាជនទាំងនោះ អ្នកនោះជាអ្នកដេកសុខមួយនឹងគេដែរ ។ ម្នាលកុមារ អ្នកសំគាល់ហេតុនោះ ដូចម្តេច គហបតីឬគហបតិបុត្រនោះ កើតសេចក្តីរសាប់រសល់ផ្សាយទៅក្នុងកាយក្នុងចិត្តដែលបណ្តាលអំពីរាគៈ គហបតីឬគហបតិបុត្រនោះ ត្រូវសេចក្តីរសាប់រសល់ដែលបណ្តាលអំពីរាគៈណារោលរាល តើត្រូវដេកជាទុក្ខឬទេ ។ យ៉ាងហ្នឹងហើយព្រះអង្គ ។ ម្នាលកុមារ គហបតីឬគហបតិបុត្រនោះត្រូវសេចក្តីរសាប់រសល់ដែលបណ្តាល



អំពីរាគៈណារោលរាល ត្រូវដេកជាទុក្ខ រាគៈនោះតថាគតបានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឱ្យកើតទៀត ដូចជាត្នោតកំបុតក ធ្វើឱ្យវិនាស មិនឱ្យកើតតទៅទៀតជាធម្មតា ហេតុនោះទើបតថាគតបានសិងជាសុខ ម្នាលកុមារ អ្នកសំគាល់ហេតុនោះដូចម្តេច គហបតីឬ គហបតិបុត្រកើតសេចក្តីរសាប់-រសល់ ដែលបណ្តាលអំពីទោសៈ ។ល។ កើតសេចក្តីរសាប់រសល់ផ្សាយទៅក្នុងកាយក្នុងចិត្ត ដែលបណ្តាលអំពីមោហៈ បុគ្គលនោះត្រូវសេចក្តីរសាប់រសល់ ដែលបណ្តាលអំពីមោហៈណារោលរាល តើត្រូវដេកជាទុក្ខឬទេ ។ យ៉ាងហ្នឹងហើយព្រះអង្គ ។ ម្នាលកុមារ គហបតី ឬគហបតិបុត្រ នោះត្រូវសេចក្តីរសាប់រសល់ ដែលបណ្តាលអំពីមោហៈណារោលរាល ត្រូវដេកជាទុក្ខ មោហៈនោះតថាគតបានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឱ្យកើតទៀត ដូចជាត្នោតកំបុតក ធ្វើឱ្យវិនាស មិនឱ្យមានទីកើតតទៅទៀតជាធម្មតា ហេតុនោះទើបតថាគតបានសិងជាសុខ ។

អ្នកណាមានបាបបន្សាត់ចោល រំលត់ទុក្ខហើយរមែងដេកជាសុខសព្វកាល បុគ្គលណាមិនជាប់ជំពាក់ក្នុងកាមទាំងឡាយ មានសេចក្តីត្រជាក់ មិនមានឧបធិក្កិលេស បានផ្តាច់បង់នូវតណ្ហាទាំងអស់ បន្ទោបង់នូវសេចក្តីក្រវល់ក្រវាយក្នុងហឫទ័យ បុគ្គល

ស្ងប់ រមែងដេកជាសុខដល់នូវការស្ងប់នៃចិត្តបាន ។

ក្នុងអង្គុត្តរនិកាយ ចតុក្កនិបាត **វស្សការសូត្រ** បិដកលេខ ៤២ ទំព័រ ៨៨ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់អំពីមហាបុរសដែលជាម្ចាស់លើចិត្តគំនិតរបស់ខ្លួន ព្រះអង្គទ្រង់ត្រាស់ថា :

ម្នាលព្រាហ្មណ៍ បុគ្គលក្នុងលោកនេះជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ពួកជនច្រើនគ្នាបានតម្កល់ហើយ ក្នុងផ្លូវដ៏ប្រសើរ គឺកល្យាណធម៌និងកុសលធម៌ ។

បុគ្គលជាមហាបុរស អ្នកមានបញ្ញាច្រើននោះ ប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កណា ក៏ត្រិះរិះនូវវិតក្កនោះបាន មិនប្រាថ្នាដើម្បីត្រិះរិះនូវវិតក្កណា ក៏មិនត្រិះរិះនូវវិតក្កនោះ ប្រាថ្នាដើម្បីសម្រេចនូវគំនិតណា ក៏សម្រេចនូវគំនិតនោះ មិនប្រាថ្នាដើម្បីសម្រេចនូវគំនិតណា ក៏មិនសម្រេចនូវគំនិតនោះឡើយ ជាអ្នកបានដល់នូវចេតោវសីក្នុងផ្លូវនៃវិតក្កទាំងឡាយ ។

*នៅក្រោមម្លប់ព្រះធម៌ព្រះវិន័យ មានសេចក្ដីសុខក្សេមមិនមានបញ្ហាក្នុងការរស់នៅ ក្នុងការស្លាប់ ឬការព្រាត់ប្រាសអ្វីឡើយ ព្រមទាំងមាននូវមេត្តាករុណាចំពោះសព្វសត្វទៀតផង ។

ក្នុងបិដកលេខ ៥៧ ទំព័រ ៩១ **សារីបុត្តត្ថេរគាថា** :

ខ្ញុំមិនត្រេកអរនឹងសេចក្ដីស្លាប់ មិនត្រេកអរនឹងការរស់នៅ





ខ្ញុំជាបុគ្គលដឹងខ្លួន មានស្មារតីខ្ជាប់ខ្ជួន ទម្លាយចោលនូវរាងកាយនេះ ។ ខ្ញុំមិនត្រេកអរនឹងសេចក្ដីស្លាប់ មិនត្រេកអរនឹងការរស់នៅ ខ្ញុំរង់ចាំតែពេលវេលា ដូចអ្នកស៊ីឈ្នួលទន្ទឹងតែការអស់ទៅនៃថ្ងៃ (ដើម្បីបានឈប់សម្រាកតែប៉ុណ្ណោះ) ។

ក្នុងបិដកលេខ ៥២ ទំព័រ ២២២ **ឧបសេនវង្គន្តបុត្តសូត្រ** ព្រះអង្គទ្រង់ឧទានប្រារព្ធចំពោះព្រះឧបសេន ដែលមានសេចក្ដីត្រិះរិះដោយប្រពៃ មានសេចក្ដីទាំងស្រុងដូចតទៅ :

ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តវេឡុវ័ន កលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះឧបសេនវង្គន្តបុត្តដ៏មានអាយុ ទៅក្នុងទីស្ងាត់ហើយសម្ងំនៅ មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា ឱហ្ន៎ អញពេញជាមានលាភ ឱហ្ន៎ អញពេញជាបានល្អ (ព្រោះ) ព្រះដ៏មានព្រះភាគជាគ្រូអញ ព្រះអង្គជាព្រះអរហន្តសម្មាសម្ពុទ្ធផង អញក៏បានចេញចាកផ្ទះចូលទៅកាន់ផ្នួស ក្នុងធម្មវិន័យដែលព្រះមានព្រះភាគ ត្រាស់ទុកដោយប្រពៃផង ពួកសព្រហ្មចារីរបស់អញ ជាអ្នកមានសីល មានកល្យាណធម៌ផង អញជាអ្នកធ្វើឱ្យពេញលេញក្នុងសីលទាំងឡាយផង ជាអ្នកមានចិត្តតាំងមាំល្អ មានចិត្តមូលនឹងក្នុងអារម្មណ៍តែមួយផង ជាអរហន្តខីណាស្រពផង ជាអ្នកមានឫទ្ធិ

ច្រើន មានអានុភាពច្រើនផង រស់នៅក៏ចម្រើន ស្លាប់ក៏ចម្រើន ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីត្រិះរិះក្នុងចិត្តរបស់ព្រះឧបសេនវង្គន្តបុត្តដ៏មានអាយុ ដោយព្រះទ័យរបស់ព្រះអង្គហើយ ទើបទ្រង់បន្លឺឧទាននេះ ក្នុងវេលានោះថា :

ជីវិតរបស់បុគ្គលណា មិនក្តៅក្រហាយ បុគ្គលនោះ រមែងមិនសោកក្នុងកាលជិតស្លាប់ ប្រសិនបើ អ្នកប្រាជ្ញនោះឯង បានឃើញបទគឺព្រះនិព្វាន រមែងមិនសោកក្នុងកណ្តាលពួកអ្នកសោកឡើយ ។ ភិក្ខុបានគាស់រំលើងតណ្ហាក្នុងភព មានចិត្តស្ងប់ មានជាតិសំសារអស់ហើយ ភពថ្មីទៀតមិនមានដល់ភិក្ខុឡើយ ។

ក្នុងសំយុត្តនិកាយ និទានវគ្គ បិដកលេខ ៣២ ទំព័រ ២៧៧ **ឧបតិស្សសូត្រ** ព្រះសារីបុត្តដ៏មានអាយុ បានឆ្លើយតបសំនួររបស់ព្រះអានន្ទដ៏មានអាយុ មានសេចក្តីដូចតទៅ :

ព្រះសារីបុត្តមានអាយុ បានពោលពាក្យដូច្នេះថា ម្នាលអាវុសោ ក្នុងទីឯណោះ ខ្ញុំបាននៅក្នុងទីដ៏ស្ងាត់ សម្ងំនៅ ក៏មានបរិវិតក្កកើតឡើងក្នុងចិត្តយ៉ាងនេះថា សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ការចង្អៀតចង្អល់ចិត្ត គប្បីកើតឡើងដល់អាត្មាអញ ព្រោះការប្រែប្រួលនិងការផ្លាស់ប្តូរនៃសត្វនិងសង្ខារ





ណា សត្វនិងសង្ខារនោះ មានតិចតួចក្នុងលោកខ្លះដែរឬ ។ ម្នាលអាវុសោ ខ្ញុំនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ការចង្អៀតចង្អល់ចិត្ត មិនគប្បីកើតឡើងដល់អាត្មាអញ ព្រោះការប្រែប្រួលនិងការផ្លាស់ប្តូរនៃសត្វ និងសង្ខារណា សត្វនិងសង្ខារនោះមិនមានតិចតួចក្នុងលោកសោះឡើយ ។

កាលព្រះសារីបុត្តពោលយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏បាននិយាយនឹងព្រះសារីបុត្តមានអាយុយ៉ាងនេះថា ម្នាលសារីបុត្តមានអាយុ សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ការចង្អៀតចង្អល់ចិត្ត មិនកើតដល់លោក ព្រោះការប្រែប្រួលនិងការផ្លាស់ប្តូរនៃព្រះសាស្តាដែរឬ ។ ម្នាលអាវុសោ សេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត ការចង្អៀតចង្អល់ចិត្ត មិនកើតឡើងដល់ខ្ញុំ ព្រោះការប្រែប្រួល និងការផ្លាស់ប្តូរនៃព្រះសាស្តាទេ តែខ្ញុំមានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ព្រះសាស្តាមានស័ក្តិធំ មានឫទ្ធិច្រើន មានអានុភាពច្រើន បាត់បង់ទៅហើយ ប្រសិនបើ ព្រះមានព្រះភាគ ព្រះអង្គគប្បីគង់នៅអស់កាលជាអង្វែងទៅ ការគង់នៅរបស់ព្រះអង្គនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បី

អនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីគុណ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។

ក្នុងបិដកលេខ ៥៧ ថេរគាថា ទំព័រ ៤៥ **អធិមុត្តត្ថេរ** បានបកស្រាយសេចក្ដីប្រាប់ដល់ពួកចោរ ព្រមដោយការមិនតក់ស្លុតមានសេចក្ដីដូចតទៅ :

(ចោរពោលថា) ក្នុងកាលមុន យើងខ្ញុំទាំងឡាយ សម្លាប់សត្វពួកណា ដើម្បីយញ្ញ ឬដើម្បីទ្រព្យ ភ័យក៏កើតមាន (ដល់សត្វពួកនោះ) ឥតមានសេសសល់ សត្វទាំងនោះរមែងញាប់ញ័រផង សោកសៅផង ។ (ឥឡូវនេះ) សេចក្ដីភិតភ័យនៃលោកមិនមានទាំងសម្បុរ (មុខលោក) ក៏ស្រស់បស់ក្រៃពេក ហេតុអ្វីក៏លោកមិនខ្សឹកខ្សួល ព្រោះភ័យធំ មានសភាពយ៉ាងនេះ ។

(ព្រះអធិមុត្តត្ថេរពោលថា) ម្នាលចោរជាធំ សេចក្ដីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត នៃបុគ្គលអ្នកមិនមានសេចក្ដីអាឡោះអាល័យមិនមានទេ បុគ្គលអ្នកមានសំយោជនៈអស់ហើយ បានកន្លងផុតនូវភ័យទាំងពួង ។ កាលបើតណ្ហាជាគ្រឿងនាំសត្វទៅកាន់ភពក្នុងបច្ចុប្បន្នអស់ហើយដោយហេតុណាមួយ ភ័យចំពោះសេចក្ដីស្លាប់ក៏មិនមានឡើយ ដូចការមិនមានភ័យក្នុងកិរិយាដាក់ចុះភារៈចេញ (អំពីក្បាល) ។ ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយ ទាំងមគ្គ





អាត្មាក៏បានចម្រើនល្អហើយ ភ័យចំពោះសេចក្ដីស្លាប់ នៃអាត្មាមិនមានទេ ដូចការមិនមានភ័យក្នុងកិរិយាអស់ទៅនៃរោគទាំងឡាយ។ ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយ ទាំងមគ្គ អាត្មាក៏បានចម្រើនល្អហើយ ភពទាំងឡាយដែលមិនមានសេចក្ដីត្រេកអរ អាត្មាក៏បានឃើញហើយ ដូចបុគ្គលផឹកនូវថ្នាំពិស ហើយខ្ជាក់ចោលវិញ ។ បុគ្គលអ្នកដល់នូវត្រើយ គឺព្រះនិព្វាន មិនមានសេចក្ដីប្រកាន់ មានសោឡសកិច្ចធ្វើហើយ មិនមានអាសវៈ រមែងជាអ្នកត្រេកអរក្នុងកិរិយាអស់ទៅនៃអាយុ ដូចបុគ្គលរួចហើយចាកការសម្លាប់ ។ បុគ្គលបានដល់នូវធម៌ដ៏ឧត្ដម ជាអ្នកមិនត្រូវការក្នុងលោកទាំងអស់ រមែងមិនមានសោកសៅ ព្រោះសេចក្ដីស្លាប់ ដូចបុគ្គលស្ទុះផុតចាកផ្ទះដែលភ្លើងឆេះ ។ ការជួបជុំដោយសត្វនិងសង្ខារឯណានីមួយក្ដី ការកើតមានក្នុងពួកសត្វឯណាក្ដី ទាំងអស់នុ៎ះ មិនមែនជាធំឡើយ ពាក្យនេះព្រះសម្មាសម្ពុទ្ធ អ្នកស្វែងរកនូវគុណធំបានសម្ដែងហើយ ។ បុគ្គលណា បានដឹងច្បាស់នូវព្រះពុទ្ធដីកា តាមដែលព្រះពុទ្ធទ្រង់សម្ដែងហើយនោះ បុគ្គលនោះមិនប្រកាន់នូវភពនីមួយឡើយ ដូចបុរសមិនកាន់ដុំដែកដែលក្ដៅសព្វ ។ អាត្មាមិនមានសេចក្ដីត្រិះរិះថាខ្លួនអញបានមានហើយទេ អាត្មាមិនមានគិតថា ខ្លួនអញនឹងមានតទៅទេ (ព្រោះថា) សង្ខារទាំងឡាយ

ទៀងតែវិនាសទៅវិញ ហេតុនោះនឹងខ្សឹកខ្សួលក្នុងសង្ខារទាំង-នោះដូចម្តេចកើត ។ ម្នាលចោរជាធំ បុគ្គលដែលឃើញច្បាស់តាមសេចក្តីពិតនូវការប្រជុំកើតនៃធម៌ដ៏បរិសុទ្ធ និងតំណនៃសង្ខារដ៏បរិសុទ្ធ ភ័យមិនមានឡើយ ។ បុគ្គលដែលឃើញច្បាស់ដោយបញ្ញានូវលោក ប្រាកដស្មើដោយស្មៅ និងកំណាត់ឈើក្នុងកាលណា ក្នុងកាលនោះ បុគ្គលនោះ ក៏មិនបាននូវសេចក្តីប្រកាន់ថារបស់អញ រមែងមិនសោកសៅថា របស់អញមិនមានឡើយ ។ អាត្មាធុញទ្រាន់នឹងសរីរៈ ជាអ្នកមិនត្រូវការដោយភព ព្រោះថាកាយនេះនឹងបែកធ្លាយទៅ ទាំងកាយដទៃទៀតក៏នឹងមិនមានដែរ។ កិច្ចណាដោយសរីរៈមានដល់ពួកអ្នក ពួកអ្នកប្រាថ្នានូវកិច្ចណា ចូរធ្វើនូវកិច្ចនោះចុះ សេចក្តីទោមនស្សក្តី សេចក្តីស្រឡាញ់ក្តីនៃអាត្មានឹងមិនមានក្នុងអំពើទាំងនោះ ព្រោះបច្ច័យនៃកិច្ចនោះឡើយ ។

ពួកចោរបានស្តាប់ពាក្យនៃព្រះអធិមុត្តត្ថេរនោះ ជាពាក្យចម្លែកអស្ចារ្យ គួរឱ្យព្រឺរោម ហើយក៏ទម្លាក់ចោលនូវគ្រឿងសស្ត្រាទាំងឡាយ បានពោលពាក្យនេះថា បពិត្រលោកដ៏ចម្រើនលោកបានធ្វើតបោកម្មដូចម្តេច ឬអ្នកណាជាអាចារ្យរបស់លោកសេចក្តីមិនសោកសៅ លោកបានព្រោះអាស្រ័យពាក្យប្រដៅរបស់អ្នកណា ។





ព្រះថេរៈឆ្លើយថា ព្រះជិនស្រីព្រះអង្គជាសព្វញ្ញូ ទ្រង់ឃើញនូវធម៌ទាំងពួង ជាសាស្តាប្រកបដោយករុណាដ៏ធំ ទ្រង់រក្សានូវសត្វលោកទាំងអស់ ជាអាចារ្យរបស់អាត្មា ។ ព្រះធម៌នេះ ជាធម៌ដល់នូវកិរិយាអស់ទៅនៃកិលេស ជាធម៌ដ៏ប្រសើរ ព្រះជិនស្រីនោះបានសម្តែងហើយ សេចក្តីមិនសោកសៅដែលអាត្មាបាន ព្រោះអាស្រ័យនូវធម៌ជាពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រីនោះ។

ចោរទាំងឡាយ បានស្តាប់នូវសុភាសិតនៃឥសី (អធិមុត្ត-ត្ថេរ ) ក៏ទម្លាក់ចោលនូវគ្រឿងសស្ត្រាទាំងឡាយផង នូវអាវុធទាំងឡាយផង ពួកខ្លះក៏វៀរចាកចោរកម្មនោះ ពួកខ្លះក៏ពេញចិត្តនឹងបព្វជ្ជា ។ ចោរទាំងនោះក៏ចូលទៅបួសក្នុងសាសនានៃព្រះ-សុគត ចម្រើននូវពោជ្ឈង្គ និងពលៈទាំងឡាយ ជាបណ្ឌិតមានចិត្តខ្ពស់ឡើង មានចិត្តល្អ មានឥន្ទ្រិយចម្រើនហើយ ក៏បានពាល់ត្រូវនូវនិព្វានបទ ជាអសង្ខតធម៌ ។

ក្នុងបិដកលេខ ២១ ទំព័រ ២៤ នៅក្នុង **កកចូបមសូត្រ** ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា :

ម្នាលភិក្ខុទាំងឡាយ បើពួកចោរ ដែលប្រព្រឹត្តអាក្រក់ នាំគ្នាអារអវយវៈតូចធំរបស់អ្នកទាំងឡាយ ដោយរណារដែលមានដងទាំងសងខាង ភិក្ខុណាមួយ ញុំាងចិត្តឱ្យប្រទូស្តចំពោះចោរទាំង-

អម្បាលនោះ ភិក្ខុនោះមិនឈ្មោះថាជាអ្នកធ្វើតាមសាសនារបស់តថាគតឡើយ នេះព្រោះហេតុមកអំពីការមិនអត់ធន់ហ្នឹងឯង ។

ក្នុងបិដកលេខ ៤១ ទំព័រ ២៧៤ នៅក្នុង **ឧបោសថសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងដល់នាងវិសាខា អំពីការរក្សាឧបោសថដោយការធ្វើតាមព្រះអរហន្ត មានជាអាទិ៍ដូចតទៅ :

ម្នាលនាងវិសាខា អរិយសាវ័កនោះ តែងពិចារណាឃើញដូច្នេះថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប ប្រកបដោយសេចក្តីអាណិត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះសព្វសត្វដែលមានជីវិត ។ ឯអាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់បាណាតិបាត ។ល។ ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះសព្វសត្វដែលមានជីវិត អស់ថ្ងៃនេះនិងយប់នេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថឈ្មោះថាអាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។

* ព្រះបរមសាស្តាទ្រង់ត្រាស់បន្តរហូតដល់គ្រប់អង្គទាំង ៨ នៃឧបោសថ រួចហើយព្រះអង្គទ្រង់ត្រាស់សម្តែងអំពីផលានិសង្សដ៏ក្រៃលែង អានហើយក៏គិតថា ឧបោសថសីលគួរតែរក្សាដោយ



រីករាយជ្រះថ្លា ។

ក្នុងបិដកលេខ ៥២ ទំព័រ ១៩ នៅក្នុង **មេត្តសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងថា :

(គួរផ្សាយមេត្តាចិត្ត ចំពោះពពួកសត្វថា) សត្វទាំងឡាយទាំងពួង សូមឱ្យមានសេចក្តីសុខ ឱ្យមានសេចក្តីក្សេម ឱ្យមានខ្លួនដល់នូវសេចក្តីសុខចុះ ។ល។ សត្វដទៃមិនគួរកំហែងបៀតបៀននូវសត្វដទៃឡើយ មិនគួរមើលងាយគេតិចតួចក្នុងទីណាមួយឡើយ មិនគួរប្រាថ្នានូវសេចក្តីទុក្ខដល់គ្នានិងគ្នា ព្រោះសេចក្តីក្រេវក្រោធនិងសេចក្តីចង្អៀតចង្អល់ក្នុងចិត្តឡើយ ។

មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយ ស្មើដោយជីវិត យ៉ាងណាមិញ បុគ្គលគួរចម្រើនមេត្តាចិត្ត មិនមានប្រមាណ ចំពោះសត្វទាំងឡាយទាំងពួងយ៉ាងនោះឯង ។

# កម្មផលជាច្បាប់របស់ជីវិត

* អ្នកដែលបានយល់ដឹងអំពីជីវិត រមែងជាអ្នកធ្ងន់ក្នុងហេតុផល ចេះមើលឃើញដល់ការធ្វើ និងផលនៃការធ្វើនោះៗ មិនចេះតែជឿដោយងងឹតឥតពិចារណា មានការភ្ញាក់ផ្អើលផ្សេងៗ ដូចជារឿងទឹកទន្លេស័ក្តិសិទ្ធិជាដើម ។

ក្នុងបិដកលេខ ២០ ទំព័រ ១២៦ នៅក្នុង **វត្ថូបមសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពី ការលាងបាបក្នុងព្រះពុទ្ធសាសនាដែលមានសេចក្តីដូចតទៅ :

សម័យនោះឯង មានព្រាហ្មណ៍ម្នាក់ឈ្មោះសុន្ទរិកភារទ្វាជៈ អង្គុយនៅជិតព្រះមានព្រះភាគ ។ លំដាប់នោះឯង សុន្ទរិកភារ-ទ្វាជព្រាហ្មណ៍ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា ចុះព្រះគោតមដ៏ចម្រើន ធ្លាប់យាងទៅកាន់ស្ទឹងពាហុកា ដើម្បីលាងជម្រះដែរឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ប្រយោជន៍អ្វីដោយស្ទឹងពាហុកា ស្ទឹងពាហុកានោះនឹងធ្វើអ្វីឱ្យ ។ ព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថាស្ទឹងពាហុកាមានជនច្រើនគ្នាសន្មតហើយថាជាស្ទឹងបរិសុទ្ធ បពិត្រ





ព្រះគោតមដ៏ចម្រើន ព្រោះថាស្ទឹងពាហុកា មានជនច្រើនគ្នាសន្មតហើយថាជាបុណ្យ ម្យ៉ាងទៀត ជនច្រើនគ្នាតែងបណ្តែតបាបកម្មដែលគេធ្វើហើយ ចោលទៅក្នុងស្ទឹងពាហុកា (នេះដែរ)។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សម្តែងដោយបទគាថាទាំងឡាយចំពោះសុន្ទរិកភារទ្វាជព្រាហ្មណ៍ថា :

ជនពាលមានកម្មអាក្រក់ (ក្នុងសន្តាន) បើទុកជាចូលទៅកាន់ស្ទឹងពាហុកាក្តី កាន់កំពង់ឈ្មោះអធិកក្កៈក្តី កាន់កំពង់ឈ្មោះគយាក្តី កាន់ស្ទឹងឈ្មោះសុន្ទរិកាក្តី កាន់ស្ទឹងឈ្មោះសរស្សតីក្តី កាន់កំពង់ឈ្មោះបយាគៈក្តី ឬក៏កាន់ស្ទឹងឈ្មោះពាហុមតីក្តី អស់កាលជានិច្ច ក៏នៅតែមិនស្អាតឡើយ ព្រោះថាស្ទឹងឈ្មោះសុន្ទរិកានឹងធ្វើអ្វីឱ្យ កំពង់ឈ្មោះបយាគៈនឹងធ្វើអ្វីឱ្យ ស្ទឹងឈ្មោះពាហុកានឹងធ្វើអ្វីឱ្យ ព្រោះថាស្ទឹងឈ្មោះសុន្ទរិកាជាដើម មិនដែលលាងជម្រះសត្វមានពៀរ មានបាបកម្មដ៏ក្លៀវក្លា ដែលខ្លួនធ្វើហើយ មានកម្មដ៏លាមកនោះ ឱ្យស្អាតបានឡើយ ផគ្គុណឫក្ស (ឫក្សល្អក្រៃលែង) តែងមានសព្វៗកាល ដល់បុគ្គលដែលបរិសុទ្ធ ឧបោសថ តែងមានសព្វៗកាល ដល់បុគ្គលដែលបរិសុទ្ធ ការកាន់យកនូវវត្ត តែងសម្រេចសព្វៗកាល ដល់បុគ្គលដែលបរិសុទ្ធ មានកម្មដ៏ស្អាត ។ ម្នាលព្រាហ្មណ៍ អ្នកចូរលាងជម្រះខ្លួនក្នុងសាសនាតថាគតវិញ

អ្នកចូរធ្វើសេចក្តីក្សេមក្សាន្តចំពោះពួកសត្វទាំងពួងចុះ បើអ្នកមិននិយាយកុហក បើអ្នកមិនបៀតបៀនសត្វ បើអ្នកមិនកាន់យកនូវទ្រព្យ ដែលគេមិនបានឱ្យ មានចិត្តជឿហើយ មិនមានសេចក្តីកំណាញ់ អ្នកចាំបាច់ទៅកាន់កំពង់ទឹកធ្វើអ្វីទៀត អ្នកផឹកទឹក (ឬងូត) តែក្នុងកំពង់ទឹក របស់អ្នកឯង (បានហើយ) ។

កាលបើព្រះមានព្រះភាគ មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ទើបសុន្ទរិកភារទ្វាជព្រាហ្មណ៍ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ហាក់ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬក៏ដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោតដូចជាគេកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សមានភ្នែកតែងមើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក ខ្ញុំព្រះអង្គសូមបាននូវបព្វជ្ជា សូមបាននូវឧបសម្បទាក្នុងសំណាក់នៃព្រះគោតមដ៏ចម្រើន ។ សុន្ទរិកភារទ្វាជព្រាហ្មណ៍ក៏បានបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។





ភារទ្វាជភិក្ខុដ៏មានអាយុ ដែលបានឧបសម្បទា មិនទាន់អស់កាលយូរប៉ុន្មាន ជាភិក្ខុម្នាក់ឯង ចៀសចេញ (ចាកពួក) ជាអ្នកមិនប្រមាទ មានព្យាយាមដុតបំផ្លាញកិលេស មានចិត្តស្លុងទៅកាន់ (ព្រះនិព្វាន) ពួកកុលបុត្រដែលចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា (ភារទ្វាជ-ភិក្ខុ) ក៏បានធ្វើឱ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយប្រាជ្ញារបស់ខ្លួនដោយខ្លួនឯងក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ មិនយូរប៉ុន្មានក៏បានដឹងច្បាស់ថា ជាតិកំណើតរបស់អាត្មាអញអស់ហើយ ព្រហ្ម-ចរិយធម៌ អញក៏បាននៅរួចហើយ កិច្ចដែលត្រូវធ្វើ អញក៏បានធ្វើហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ភារទ្វាជភិក្ខុដ៏មានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

ក្នុងថេរីគាថា បិដកលេខ ៥៧ ទំព័រ ១៨៩ នាង**បុណ្ណិកា** បានទូន្មានព្រាហ្មណ៍អ្នកងូតទឹកលាងបាប មានសេចក្តីដូចតទៅ :

ខ្ញុំជាស្ត្រីអ្នកដងទឹក មានការខ្លាចទណ្ឌភ័យនៃជនជាម្ចាស់ទាំងឡាយ ត្រូវភ័យអំពីវាចានិងទោសបៀតបៀន ហើយចុះទឹក

រាល់ពេលក្នុងកាលត្រជាក់រងា ។ ម្នាលព្រាហ្មណ៍ អ្នកខ្លាចអ្នកណា ទើបចុះទឹករាល់ពេល មានខ្លួនញាប់ញ័រ ទទួលរងរងាដ៏ក្រៃលែង ។

**ព្រា.** ម្នាលនាងបុណ្ណិកាដ៏ចម្រើន នាងដឹង (ថាខ្ញុំ) កំពុងធ្វើកុសលកម្មជាគ្រឿងបិទនូវបាបកម្មដែរ ម្តេចក៏សួរដេញដោល ។ បុគ្គលណា ទោះចាស់ក្តី ក្មេងក្តីបានធ្វើបាបកម្មហើយ បុគ្គលនោះរមែងរួចចាកបាបកម្មនោះ ព្រោះការស្រោចស្រពដោយទឹក ។

**បុ.** អ្នកល្ងង់ណាហ្ន៎ បាននិយាយពាក្យនេះ ទៅរកអ្នកដែលល្ងង់ដែរ (ថាបុគ្គល) រមែងរួចចាកបាបកម្ម ព្រោះការស្រោចស្រពដោយទឹក (បើដូច្នេះ) កង្កែប អណ្តើក នាគ ក្រពើ ឬសត្វដទៃណាមួយ ដែលត្រាច់ទៅក្នុងទឹកទាំងអស់ នឹងទៅកាន់ឋានសួគ៌ដោយពិត ។ ឯពួកជនអ្នកសម្លាប់ទ្រាយ សម្លាប់ជ្រូក នេសាទត្រី អ្នកចាប់ម្រឹគ ពួកចោរ ពួកពេជ្ឈឃាត ឬពួកជនឯទៀត ដែលមានកម្មដ៏លាមក ពួកជនទាំងនោះ ក៏រួចចាកបាបកម្ម ព្រោះការស្រោចស្រពដោយទឹកដែរ។ ប្រសិនបើស្ទឹងទាំងនោះ អាចបន្សាត់ចោលនូវបាប ដែលអ្នកធ្វើក្នុងកាលមុនបាន ស្ទឹងទាំងនោះក៏អាចបន្សាត់ចោលនូវបុណ្យរបស់អ្នកបានដែរ ព្រោះហេតុនោះ ខ្លួនអ្នកនឹងទៅជាបុគ្គលក្រៅស្រឡះ ។ ម្នាលព្រាហ្មណ៍ អ្នកខ្លាចចំពោះ





បាបកម្មណា ហើយចុះត្រាំទឹក គ្រប់ៗពេល ម្នាលព្រាហ្មណ៍ អ្នកកុំធ្វើនូវបាបនោះវិញ កុំ (ចុះត្រាំទឹក) ឱ្យរងាបៀតបៀននូវសម្បុរសរីរៈរបស់អ្នកឡើយ ។

**ព្រា.** នាងដឹកនាំខ្ញុំដែលដើរផ្លូវខុស ឱ្យដើរទៅតាមផ្លូវដ៏ប្រសើរ ម្នាលនាងដ៏ចម្រើន ខ្ញុំសូមជូនសាដកសម្រាប់ស្រោចស្រពទឹកនេះដល់នាង ។

**បុ.** សំពត់សាដកចូរនៅជារបស់អ្នកដដែលចុះ ខ្ញុំមិនត្រូវការសំពត់សាដក (របស់អ្នក) ទេ ។ បើអ្នកខ្លាចសេចក្តីទុក្ខ បើសេចក្តីទុក្ខមិនជាទីស្រឡាញ់នៃអ្នកទេ អ្នកកុំធ្វើបាបកម្ម ទោះបីក្នុងទីវាលក្តី ក្នុងទីកំបាំងក្តី ។ បើអ្នកនឹងធ្វើ ឬកំពុងធ្វើបាបកម្ម សូម្បីអ្នកហោះរត់ទៅក៏មិនរួចចាកទុក្ខ ។ បើអ្នកខ្លាចសេចក្តីទុក្ខ បើសេចក្តីទុក្ខមិនជាទីស្រឡាញ់របស់អ្នកទេ អ្នកចូរដល់នូវព្រះពុទ្ធជាតាទិបុគ្គលផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ជាទីពឹងចុះ ចូរសមាទានសីលទាំងឡាយចុះ ការដល់នូវទីពឹងនិងការសមាទានសីលនោះ នឹងញុំាំងអ្នកឱ្យរួចចាក (ទុក្ខ) ។

**ព្រា.** ពីដើមខ្ញុំជាព្រាហ្មណ៍តែពូជ ថ្ងៃនេះខ្ញុំជាព្រាហ្មណ៍ពិត មានត្រៃវិជ្ជា បរិបូណ៌ដោយវេទ ជាអ្នកមានសួស្តី ជាអ្នកលាងបាប ។

ក្នុងគម្ពីរឧទាន ពោធិវគ្គ បិដកលេខ ៥២ ទំព័រ ១២៦ នៅក្នុង **ជដិលសូត្រ** ព្រះអង្គទ្រង់ឧទានដូច្នេះថា :

បុគ្គលមិនដែលស្អាត ព្រោះទឹកដែលមនុស្សច្រើននាក់ រមែងនាំគ្នាចុះងូតនោះទេ សច្ចៈ ១ ធម្ម ១ មាននៅក្នុងបុគ្គលណា បុគ្គលនោះទើបឈ្មោះថា ជាអ្នកស្អាតផង ឈ្មោះថា ជាព្រាហ្មណ៍ផង ។

ក្នុងអដ្ឋកថា **មង្គលជាតក** បានពោលអំពីព្រាហ្មណ៍ម្នាក់ អ្នកនៅក្នុងនគររាជគ្រឹះ ជាអ្នកប្រកាន់មង្គលភ្ញាក់ផ្អើល មិនជ្រះថ្លាក្នុងព្រះរតនត្រ័យ ជាបុគ្គលមិច្ឆាទិដ្ឋិ មានភោគទ្រព្យច្រើន ។

ក្នុងកាលនោះ កណ្ដុរបានកាត់នូវសំពត់សាដកមួយគូរបស់គាត់ ។ ដល់ពេលគាត់ត្រូវការឱ្យគេយកសំពត់នោះមក ទើបដឹងថាត្រូវកណ្ដុរកាត់ដាច់ជាអន្លើៗទៅហើយ ។ ព្រាហ្មណ៍គិតថា សំពត់នេះជាអពមង្គល បើទុកនៅនឹងផ្ទះនាំឱ្យមានការវិនាសយ៉ាងក្រៃលែង គឺវាដូចជាកាឡកណ្ណិមួយអីចឹង ទាំងមិនអាចឱ្យដល់បុត្រធីតា ឬទាសកម្មករផង ព្រោះសេចក្ដីវិនាសនឹងកើតមានដល់អ្នកទទួលនូវសំពត់នោះទៅគ្រប់គ្នា ត្រូវយកទៅចោលក្នុងព្រៃខ្មោចទើបបាន ។

ព្រាហ្មណ៍មិច្ឆាទិដ្ឋិ មិនឱ្យពួកទាសកម្មករយកទៅចោលទេ



ដោយខ្លាចពួកទាសកម្មករ នាំយកនូវសំពត់នោះទៅប្រើប្រាស់ បណ្ដាលឱ្យវិនាសតៗគ្នា ។ ទើបព្រាហ្មណ៍ប្រាប់ឱ្យកូនប្រុសរបស់គាត់យកឈើឆ្កឹះទាក់នូវសំពត់នោះ នាំទៅចោលនៅព្រៃខ្មោច ហើយត្រូវងូតទឹកជ្រមុជឱ្យលិចក្បាលសឹមត្រឡប់មកផ្ទះវិញ ។

ព្រះបរមសាស្ដាសម្មាសម្ពុទ្ធគង់ប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ជ្រាបឧបនិស្ស័យនៃព្រាហ្មណ៍ពីរនាក់ឪពុកនិងកូន ព្រះអង្គបានយាងទៅកាន់ព្រៃខ្មោចនោះ ហើយទ្រង់កាន់យកនូវសំពត់សាដកដែលកូនប្រុសរបស់ព្រាហ្មណ៍បានចោលហើយ ទាំងដែលកូនប្រុសនោះឃាត់ព្រះអង្គមិនឱ្យចាប់ ដោយអាងថា ជារបស់ចង្រៃ ។ ព្រះបរមសាស្ដាទ្រង់កាន់យកនូវសំពត់មួយគូនោះ វិលត្រឡប់មកកាន់វត្តវេឡុវ័នវិញ ។

កាលដែលកូនប្រុសត្រឡប់មកជំរាបរឿងរ៉ាវ ដល់ឪពុកហើយ ឪពុកនិងកូនក៏ប្រញាប់នាំគ្នាទៅកាន់វត្តវេឡុវ័ន ដើម្បីសូមឱ្យព្រះសម្មាសម្ពុទ្ធចោលនូវសំពត់នោះទៅវិញ ។ ព្រាហ្មណ៍គិតថា បើព្រះសមណគោតម ប្រើសំពត់នេះទៅ វាត្រូវធ្វើឱ្យលំបាកដល់ព្រះអង្គផង ត្រូវវិនាសវត្តវេឡុវ័នផង ម្ល៉ោះហើយគេនឹងនិន្ទាស្ដីថា មកដល់យើងជាពិតប្រាកដ ដូច្នេះ យើងត្រូវយកសំពត់សាដកថ្មីៗ ទៅថ្វាយដល់ព្រះសមណគោតម ដើម្បីសូមឱ្យព្រះសមណគោតម

ចោលនូវសំពត់ចង្រៃនោះ ។

នៅពេលដែលព្រាហ្មណ៍ឪពុក និងកូនប្រុសបានទៅដល់វត្ត ហើយ ព្រាហ្មណ៍ជាឪពុកបានក្រាបទូលព្រះសម្មាសម្ពុទ្ធដោយសព្វគ្រប់ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពួកយើងមានឈ្មោះថាជាបព្វជិត ដូច្នេះ សំពត់ចាស់ៗដែលគេចោលនៅព្រៃខ្មោច ឬគំនរសំរាមជាដើម រមែងសមគួរដល់ពួកយើង ឯចំណែកព្រាហ្មណ៍ឯង មិនមែនទើបតែឥឡូវនេះទេ ពីជាតិមុនមកក៏ធ្លាប់ប្រកាន់នូវលទ្ធិដូច្នេះដែរ ។

កាលដែលព្រាហ្មណ៍អារាធនាហើយ ព្រះអង្គទ្រង់ត្រាស់សម្តែងនូវរឿងរ៉ាវអតីតជាតិ មានសេចក្តីប្រហែលគ្នានឹងបច្ចុប្បន្នដែរ គ្រាន់តែកាលណោះ ព្រះបរមពោធិសត្វជាតាបសបានឈានហើយប្រោសព្រាហ្មណ៍ ឯព្រាហ្មណ៍ក៏បានយកព្រះបរមពោធិសត្វជាសរណៈ ។

ក្នុងបិដកលេខ ៥៨ ទំព័រ ៣៨ **មង្គលជាតក** ព្រះបរម-សាស្តាទ្រង់ត្រាស់ថា :

មង្គលទាំងឡាយក្តី ឧត្បាតទាំងឡាយក្តី សុបិនទាំងឡាយក្តី លក្ខណៈទាំងឡាយក្តី ដែលបុគ្គលណាបានផ្តាច់បង់ហើយ បុគ្គលនោះឈ្មោះថា អ្នកកន្លងផុតនូវទោសនៃមង្គល (ភ្ញាក់ផ្អើល) ។ ជា





អ្នកគ្របសង្កត់នូវយុគក្កិលេស (ក្រោធ ១ ការចងគំនុំ ១ ការរមិលគុណ ១ និងការវាយឫកស្មើ ១ ទាំង ៤ នេះ ហៅយុគក្កិលេស ) និងយោគក្កិលេស (កាមយោគ ១ ភវយោគ ១ ទិដ្ឋិយោគ ១ អវិជ្ជាយោគ ១ ) រមែងមិនមកកើតទៀតឡើយ ។

ដោយសេចក្តីថា បុគ្គលណាមិនប្រកាន់មង្គលភ្ញាក់ផ្អើល មិនប្រកាន់ឧត្បាត មិនប្រកាន់ការយល់សប្តិ មិនប្រកាន់លក្ខណៈជោគល្អ ឬជោគអាក្រក់ បុគ្គលនោះឈ្មោះថា ជាអ្នកកន្លងផុតនូវទោសនៃការប្រកាន់មង្គលភ្ញាក់ផ្អើល ។

ព្រះបរមសាស្តា ទ្រង់សម្តែងធម៌ឱ្យព្រាហ្មណ៍ឪពុក និងកូនបានសម្រេចសោតាបត្តិផល ។

ក្នុងអដ្ឋកថា **នក្ខត្តជាតក** បានពោលអំពី ត្រកូលមួយនៅក្រៅក្រុងសាវត្ថី បានទៅស្តីដណ្តឹងកុលធីតាម្នាក់នៅក្នុងក្រុងសាវត្ថី ដើម្បីជាប្រយោជន៍ដល់កូនប្រុសរបស់ខ្លួន ។ គេបានសន្យាថ្ងៃកំណត់មកទទួលយកកូនស្រីទៅកាន់ត្រកូលខាងប្រុស ប៉ុន្តែ លុះដល់ថ្ងៃកំណត់ ត្រកូលខាងប្រុសគេបានសួរអាជីវកម្នាក់ដែលបានចូលទៅកាន់ត្រកូលរបស់ខ្លួនថា លោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះពួកខ្ញុំនឹងធ្វើនូវមង្គលមួយ តើនក្ខត្តឫក្សល្អដែរទេ ?

អាជីវកមានការខឹងក្រោធជាខ្លាំង ព្រោះគិតថាពួកអស់នេះ

មិនសួរយើងពីដំបូង ឥឡូវដល់ថ្ងៃទៅហើយទើបតែសួរ យើងនឹងផ្តល់មេរៀនឱ្យគេម្តង ដូច្នេះហើយក៏ពោលថា ថ្ងៃនេះមិនល្អទេ អ្នកទាំងអស់គ្នាកុំធ្វើមង្គលឡើយ បើចចេសចេះតែធ្វើនឹងមានការវិនាសធំ ។ ពួកមនុស្សក្នុងត្រកូលក៏ជឿអាជីវកនោះ ហើយក៏មិនបានទៅទទួលយកកូនស្រីក្នុងថ្ងៃហ្នឹងឡើយ ។

ចំណែកត្រកូលខាងស្រី បានចាត់ការមង្គលរៀបចំចាំទទួលភ្ញៀវខាងប្រុស លុះមិនឃើញពួកគេមកតាមសន្យា ក៏លើកធីតាឱ្យទៅត្រកូលដទៃសម្រេចស្រេចបាច់ក្នុងថ្ងៃនោះដែរទៅ ។

ថ្ងៃស្អែកឡើងត្រកូលក្រៅក្រុងក៏បាននាំគ្នាមកដល់សូមយកកូនស្រី ពួកអ្នកក្នុងក្រុងក៏បានតិះដៀលថា ពួកអ្នកឯងសមនឹងឈ្មោះអ្នកក្រៅក្រុងមែនហើយ ជាមនុស្សខ្វះសម្បត្តិរបស់មនុស្សល្អ ជាមនុស្សអាក្រក់ សន្យាគ្នាហើយ មើលងាយពាក្យសន្យា មិនមកតាមកំណត់ អញ្ជើញទៅតាមផ្លូវដែលអ្នករាល់គ្នាមកនោះវិញទៅ ពួកយើងលើកកូនស្រីយើងឱ្យអ្នកផ្សេងទៅហើយ ។

ពួកអ្នកក្រៅក្រុង ខំប្រឹងឈ្លោះនឹងអ្នកក្រុងអស់មួយសន្ទុះធំ លុះដឹងប្រាកដថាមិនបានកូនក្រមុំពិតហើយ ក៏នាំគ្នាត្រឡប់ទៅវិញតាមផ្លូវដែលមកនោះឯង ។

រឿងទាំងអស់បានជ្រាបដល់ព្រះមានព្រះភាគ ព្រះអង្គទ្រង់





ត្រាស់ព្រះជាតក ពីអាជីវកនោះធ្លាប់បំផ្លាញមង្គលរបស់គេតាំងពីជាតិមុនមកដែរ ។

ក្នុងជាតិមុននោះ អ្នកក្រុងពារាណសី ទៅស្តីដណ្តឹងកូនស្រីអ្នកជនបទ ហើយមិនទៅតាមសន្យា ព្រោះថាជឿតាមពាក្យកុហករបស់អាជីវក ។ រឿងរ៉ាវមានទំនងដូចគ្នា ខុសត្រង់ថាអ្នកជនបទបានតិះដៀលអ្នកក្រុងពារាណសីថា ពួកអ្នករាល់គ្នាឈ្មោះថាជាអ្នកក្រុង ប៉ុន្តែខ្វះនូវសម្បត្តិរបស់មនុស្សល្អ ព្រោះមិនគោរពពាក្យសន្យា ។ ក្នុងកាលណោះ ព្រះបរមពោធិសត្វជាបណ្ឌិត បានពោលថា ផ្កាយទាំងឡាយនឹងមានប្រយោជន៍អ្វី ព្រោះការបានកូនស្រីក្រមុំជាឫក្សល្អស្រេចទៅហើយ មិនមែនទេឬ ? រួចហើយទើបព្រះបរមពោធិសត្វពោលនូវគាថា :

ក្នុងបិដកលេខ ៥៨ ទំព័រ ២២ **នក្ខត្តជាតក** បណ្ឌិតបុរសពោធិសត្វ ពោលថា :

**នក្ខត្តំ បដិមានេន្តំ អត្ថោ ពាលំ ឧបច្ចគា**
**អត្ថោ អត្ថស្ស នក្ខត្តំ កឹ ករិស្សន្តិ តារកាតិ ។**

ប្រែថា : ប្រយោជន៍រមែងកន្លងបង់នូវមនុស្សល្ងង់ដែលរាប់អាននូវនក្ខត្តឫក្ស ប្រយោជន៍ជានក្ខត្តឫក្សរបស់ប្រយោជន៍ ឯផ្កាយទាំងឡាយនឹងធ្វើអ្វីបាន ។

## អដ្ឋកថានក្ខត្តជាតក

≈≈≈≈≈≈≈≈≈≈≈≈≈

បណ្តាបទទាំងនោះ បទថា **បដិមានេន្តំ** ដោយសេចក្តីថា អ្នករង់ចាំមើល អធិប្បាយថា រវល់តែរង់ចាំមើល នក្ខត្តឫក្សនឹងមានក្នុងពេលនេះ នឹងមានក្នុងកាលឥឡូវនេះ ។

បទថា **អត្ថោ ពាលំ ឧបច្ចគា** ដោយសេចក្តីថា ប្រយោជន៍ ពោលគឺការបាននូវកូនក្រមុំ កន្លងផុតនូវមនុស្សល្ងង់ដែលជាអ្នកក្រុងពារាណសីនោះ ។

បទថា **អត្ថោ អត្ថស្ស នក្ខត្តំ** ដោយសេចក្តីថា បុគ្គលស្វែងរកនូវប្រយោជន៍ណា ប្រយោជន៍ដែលគេបានហើយនោះឯងឈ្មោះថាជានក្ខត្តឫក្សរបស់ប្រយោជន៍ ។

បទថា **កឹ ករិស្សន្តិ តារកា** ដោយសេចក្តីថា តើដួងផ្កាយទាំងឡាយក្នុងអាកាសក្រៅអំពីនេះ នឹងញុំាងប្រយោជន៍ដូចម្តេចឱ្យសម្រេចបាន ។

ក្នុងបិដកលេខ ៤១ ទំព័រ ៤៧៥ **សុបុព្វណ្ហសូត្រ** ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ពេលណាដែលសត្វទាំងឡាយប្រព្រឹត្តល្អដោយកាយវាចាចិត្ត ពេលនោះឈ្មោះថាជានក្ខត្តឫក្សល្អ ... មានសេចក្តីទាំងស្រុងដូចតទៅ :



ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងបុព្វណ្ហសម័យ ម្នាលភិក្ខុទាំងឡាយសត្វទាំងនោះឈ្មោះថាមានបុព្វណ្ហសម័យដ៏ល្អ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងមជ្ឈន្តិកសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះឈ្មោះថា មានមជ្ឈន្តិកសម័យដ៏ល្អ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងសាយណ្ហសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះឈ្មោះថាមានសាយណ្ហសម័យដ៏ល្អ។

ពេលណាដែលសត្វទាំងឡាយប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះឈ្មោះថា នក្ខត្តឫក្សល្អ មង្គលល្អ ពេលភ្លឺស្វាងល្អ ពេលនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជា ) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ ) ឈ្មោះថាជាគ្រឿងបូជាល្អ (ក្នុងថ្ងៃនោះ ) កាយកម្មឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន វចីកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន មនោកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថា នាំឱ្យមានសេចក្តី

ចម្រើន បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចម្រើន ហើយរមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំង-ឡាយ ។ អ្នកទាំងឡាយនោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា ។

* អ្នកមានសទ្ធាប្រកបដោយបញ្ញា យល់ច្បាស់ពីកម្មផល រមែងប្រាកដក្នុងចិត្តថា ផលសម្រេចដែលខ្លួនត្រូវការ ឬទិសដៅដែលខ្លួនប្រាថ្នានឹងចូលឱ្យដល់ នឹងសម្រេចបានដោយការប្រព្រឹត្តធ្វើ ដែលយើងនិយាយថា «ចុះដៃធ្វើ » ដូច្នេះទើបត្រូវពឹងខ្លួនឯង និងត្រូវឧស្សាហ៍ព្យាយាម ដោយមិនរង់ចាំជោគជតារាសីឬសង្ឃឹមផលដោយការអង្វរករ បួងសួងអ្វីឡើយ ។

ក្នុងបិដកលេខ ២៨ ទំព័រ ២ **ភទ្ទេករត្តសូត្រ** ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា :

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ដែលកន្លងទៅហើយ មិនគប្បីប្រាថ្នាបញ្ចក្ខន្ធ ដែលមិនទាន់មកដល់ទេ ព្រោះបញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ ។ មួយទៀតបុគ្គលណា ឃើញច្បាស់នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះៗ បុគ្គលនោះ





លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម និងមិនបានកម្រើក (ដោយពួកកិលេស ) គប្បីចម្រើនឱ្យរឿយៗ នូវផលសមាបត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ។ ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ ។ អ្នកប្រាជ្ញដែលស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមិនខ្ជិលច្រអូសអស់យប់និងថ្ងៃនោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន។

ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត បិដកលេខ ៤៤ ទំព័រ ៩៥ **ឥដ្ឋសូត្រ** ព្រះអង្គទ្រង់សម្តែងអំពីធម៌៥ គឺអាយុ១ វណ្ណៈ១ សុខ១ យស ១ និងស្ថានសួគ៌ ១ ធម៌ទាំង ៥ នេះមិនមែនបាន អំពីការបន់ស្រន់ ឬគ្រាន់តែប្រាថ្នានោះទេ មានសេចក្តីជាអាទិ៍ដូចតទៅ :

គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី ធម៌ ៥ យ៉ាង ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រក

បានដោយក្រក្នុងលោក ។ ធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលគហបតី អាយុជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ ពណ៌សម្បុរជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ សុខជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ យសជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ ស្ថានសួគ៌ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ១ ។ ម្នាលគហបតី ធម៌ទាំង ៥ យ៉ាងនេះឯង ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោក ។ ម្នាលគហបតី តថាគតមិនពោលនូវការបានចំពោះធម៌ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោកទាំង ៥ ព្រោះការបន់ស្រន់ ឬព្រោះការប្រាថ្នាទេ ។ ម្នាលគហបតី បើការបានចំពោះនូវធម៌ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត រកបានដោយក្រក្នុងលោកទាំង ៥ នេះ សម្រេចហើយព្រោះការបន់ស្រន់ ឬព្រោះការប្រាថ្នានោះ នរណាមួយ ក្នុងលោកនេះអាចញុំាងនរណាឱ្យសាបសូន្យបាន ។

* ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីធម៌ទាំង ៥ មានអាយុជាដើម រមែងសម្រេចបានពីបដិបទា គឺការប្រព្រឹត្តធ្វើ ដោយមិន





គួរគប្បីបន់ស្រន់ ឬត្រេកអរភ្លើតភ្លើននឹងអាយុជាដើមនោះ ព្រោះហេតុនៃការចង់បាននោះឡើយ ។

ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ បិដកលេខ ៣៣ ទំព័រ ៣៤៦ **នាវាសូត្រ** ព្រះអង្គទ្រង់សម្តែងអំពីកិរិយាអស់ទៅនៃអាសវៈ មានសេចក្តីជាអាទិ៍ដូចតទៅ :

ជិតក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវកិរិយាអស់ទៅនៃអាសវៈ ចំពោះបុគ្គលដែលដឹងច្បាស់ ឃើញច្បាស់ មិនពោលចំពោះបុគ្គលដែលមិនដឹងច្បាស់ មិនឃើញច្បាស់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ រមែងមានដល់បុគ្គលដែលដឹងអ្វី ឃើញអ្វី ។ (ដល់បុគ្គលដឹងឃើញ) ថារូបដូច្នេះ ហេតុឱ្យកើតឡើងនៃរូបដូច្នេះ សេចក្តីអស់ទៅនៃរូបដូច្នេះ។ វេទនាដូច្នេះ ។ សញ្ញាដូច្នេះ ។ សង្ខារដូច្នេះ ។ វិញ្ញាណដូច្នេះ ហេតុឱ្យកើតឡើងនៃវិញ្ញាណដូច្នេះ សេចក្តីអស់ទៅនៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ការអស់ទៅនៃអាសវៈ រមែងមានដល់បុគ្គលដែលដឹងយ៉ាងនេះ ឃើញយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលមិនប្រកបរឿយៗនូវភាវនា-នុយោគ ទុកជាមានសេចក្តីប្រាថ្នា កើតឡើងយ៉ាងនេះថា ឱហ្ន៎ ចិត្តរបស់អាត្មាអញគប្បីរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះ

មិនបានប្រកាន់មាំក៏ដោយ ចិត្តរបស់ភិក្ខុនោះក៏នៅតែមិនរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនបានប្រកាន់មាំឡើយ ។ សេចក្តីនោះ ព្រោះហេតុដូចម្តេច ។ គប្បីឆ្លើយថា ព្រោះភិក្ខុនោះមិនបានចម្រើន។ មិនបានចម្រើនអ្វី ។ មិនបានចម្រើនសតិប្បដ្ឋានទាំង ៤ មិនបានចម្រើនសម្មប្បធានទាំង ៤ មិនបានចម្រើនឥទ្ធិបាទទាំង ៤ មិនបានចម្រើនឥន្ទ្រិយទាំង ៥ មិនបានចម្រើនពលៈទាំង ៥ មិនបានចម្រើនពោជ្ឈង្គទាំង ៧ មិនបានចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាមេមាន់មានស៊ុត ៨ ក្តី ១០ក្តី ១២ក្តី ឯស៊ុតទាំងនោះបើមេមាន់មិនបានក្រាបដោយប្រពៃ មិនបានឱ្យចំហាយដោយប្រពៃ មិនបានអប់កម្តៅដោយប្រពៃទេ មេមាន់នោះទុកជាមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ កូនមាន់របស់អាត្មាអញគប្បីទម្លាយនូវសម្បកស៊ុត ដោយចុងក្រចកជើង ឬដោយចុងចំពុះហើយញាស់មកដោយសួស្តីដូច្នេះក៏ដោយ កូនមាន់ទាំងនោះ ក៏មិនគួរដើម្បីទម្លាយនូវសម្បកស៊ុត ដោយចុងក្រចកជើង ឬដោយចុងចំពុះហើយញាស់មកដោយសួស្តីបានឡើយ ។

*ជាចុងក្រោយនៃព្រះសូត្រ ព្រះអង្គទ្រង់សម្តែងអំពីមេមាន់ក្រាបពងផង អំពីជាងឈើផង និងអំពីទូក (នាវា) ផង មាន





សេចក្តីទាំងស្រុងដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ ដូចជាមេមាន់មានស៊ុត ៨ ក្តី ១០ក្តី ១២ក្តី ឯស៊ុតទាំងនោះ មេមាន់ក៏បានក្រាបដោយប្រពៃ បានឱ្យចំហាយដោយប្រពៃ បានអប់កម្តៅដោយប្រពៃ ទុកជាមេមាន់នោះមិនមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ កូនមាន់របស់អាត្មាអញគប្បីទម្លាយនូវសម្បកស៊ុត ដោយចុងក្រចកជើងឬដោយចុងចំពុះ ហើយញាស់ចេញមកដោយសួស្តីដូច្នេះក៏ដោយ កូនមាន់ទាំងនោះក៏គួរដើម្បី ទម្លាយនូវសម្បកស៊ុត ដោយចុងក្រចកជើង ឬដោយចុងចំពុះ ហើយញាស់ចេញមកដោយសួស្តីបានដោយពិត។ សេចក្តីនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថាមេមាន់ដែលមានស៊ុត ៨ ក្តី ១០ក្តី ១២ក្តី ឯស៊ុតទាំងនោះ មេមាន់បានក្រាបដោយប្រពៃ បានឱ្យចំហាយដោយប្រពៃ បានអប់កម្តៅដោយប្រពៃ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ឯភិក្ខុអ្នកប្រកបរឿយៗនូវភាវនានុយោគ ទុកជាមិនមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ ចិត្តរបស់អាត្មាអញគប្បីរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនបានប្រកាន់មាំ ដូច្នេះក៏ដោយ ចិត្តរបស់ភិក្ខុនោះ រមែងរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនបានប្រកាន់មាំ បានដោយពិត ។ សេចក្តីនោះ ព្រោះហេតុអ្វី ។

គប្បីឆ្លើយថា ព្រោះភិក្ខុនោះបានចម្រើន ។ បានចម្រើនអ្វី ។ បានចម្រើនសតិប្បដ្ឋានទាំង ៤ បានចម្រើនសម្មប្បធានទាំង ៤ បានចម្រើនឥទ្ធិបាទទាំង ៤ បានចម្រើនឥន្ទ្រិយទាំង ៥ បានចម្រើនពលៈទាំង ៥ បានចម្រើនពោជ្ឈង្គទាំង ៧ បានចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ ។

ម្នាលភិក្ខុទាំងឡាយ ដូចជាជាងឈើ ឬកូនសិស្សរបស់ជាងឈើ រមែងយកម្រាមដៃ និងមេដៃចាប់កាន់ត្រង់មៀនកាំបិតជាប្រាកដ ប៉ុន្តែជាងឈើនោះក៏មិនមានសេចក្តីដឹងយ៉ាងនេះថា ក្នុងថ្ងៃនេះ មៀនកាំបិតរបស់អាត្មាអញសឹកអស់ទៅប៉ុណ្ណេះ ម្សិលមិញសឹកអស់ប៉ុណ្ណេះ ម្សិលម្ង៉ៃសឹកអស់ប៉ុណ្ណេះ ដូច្នេះឡើយ ជាងឈើនោះគ្រាន់តែមានសេចក្តីដឹងថាអស់ទៅ ៗ តែប៉ុណ្ណោះ ដោយពិត យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបរឿយៗ នូវភាវនានុយោគ ក៏មិនមានសេចក្តីដឹងយ៉ាងនេះថា ក្នុងថ្ងៃនេះ អាសវៈរបស់អាត្មាអញអស់ទៅប៉ុណ្ណេះ ម្សិលមិញអស់ទៅប៉ុណ្ណេះ ម្សិលម្ង៉ៃអស់ទៅប៉ុណ្ណេះ ដូច្នេះដែរ ភិក្ខុនោះគ្រាន់តែមានសេចក្តីដឹងថាអស់ទៅ ៗ តែប៉ុណ្ណោះ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ដូចជាទូកនៅក្នុងសមុទ្រ ដែលគេចងដោយចំណងផ្តៅត្រាំនៅក្នុងទឹកអស់ ៦ ខែ ទើបគេស្រង់ឡើងដាក់លើ





គោកក្នុងហេមន្តរដូវ ឯចំណងផ្តៅទាំងនោះ ត្រូវខ្យល់និងកម្តៅថ្ងៃគ្របសង្កត់មេឃបង្អុរទឹកភ្លៀងគ្របសង្កត់ ក៏រមែងល្មាសពុកផុយទៅដោយមិនយូរ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបរឿយៗ នូវភាវនានុយោគ រមែងមានសញ្ញោជនៈស្ងប់រម្ងាប់ទៅ ពុកផុយទៅដោយមិនលំបាក ក៏យ៉ាងនោះឯង ។

* ការជាក់ច្បាស់ចំពោះដំណើរជីវិតដែលជាតួហេតុ តួផលនាំឱ្យប្រឹងប្រែងជួយខ្លួនឯង ។

ក្នុង**គាថាធម្មបទ** បិដកលេខ ៥២ ទំព័រ ៧៨ ក្នុងវគ្គដែលសម្តែងអំពីមគ្គ ព្រះអង្គទ្រង់ត្រាស់ថា :

**តុម្ហេហិ កិច្ចំ អាតប្បំ អក្ខាតារោ តថាគតា**

អ្នកទាំងឡាយគប្បីធ្វើនូវសេចក្តីព្យាយាម ជាគ្រឿងដុតនូវកិលេស ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់ ។

បិដកលេខ ៥២ ទំព័រ ៥៥ **អត្តវគ្គ** :

**អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា**
**អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។**

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនបានទូន្មានល្អហើយ រមែងបាននូវទីពឹង ដែលគេ

បានដោយកម្រ ។

**សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ**

បរិសុទ្ធិ និងមិនបរិសុទ្ធិ មានចំពោះខ្លួនឯង អ្នកដទៃនឹងធ្វើអ្នកដទៃ ឱ្យបរិសុទ្ធពុំបានឡើយ ។

ក្នុងបិដកលេខ ១៦ ទំព័រ ២១៤ នៅក្នុង **មហាបរិនិព្វានសូត្រ** ព្រះអង្គទ្រង់សម្តែងឱ្យយកខ្លួនជាទីពឹង យកខ្លួនជាទីរលឹក កុំយករបស់ដទៃ ជាទីរលឹក ចូរយកធម៌ជាទីពឹង យកធម៌ជាទីរលឹក កុំយករបស់ដទៃ ជាទីរលឹកឡើយ ។

ក្នុងបិដកលេខ ១៨ ទំព័រ ១៥៦ នៅក្នុង **ចក្កវត្តិសូត្រ** និងក្នុងបិដកលេខ ៣៣ ទំព័រ ៩៦ នៅក្នុង **អត្តទីបសូត្រ** ព្រះអង្គទ្រង់សម្តែងឱ្យយកខ្លួនជាទីពឹងដូចក្នុង**មហាបរិនិព្វានសូត្រ**ដែរ :

ម្នាលអានន្ទ ភិក្ខុយកខ្លួនជាទីពឹង យកខ្លួនជាទីរលឹក មិនយករបស់ដទៃជាទីរលឹក យកធម៌ជាទីពឹង យកធម៌ជាទីរលឹក មិនយករបស់ដទៃជាទីរលឹកនោះតើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ មានព្យាយាមដុតកម្តៅកិលេស មានសម្បជញ្ញៈ មានសតិ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ក្នុងវេទនាទាំងឡាយ ។ ក្នុងចិត្ត ។ ភិក្ខុ





ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ... ។

* បុគ្គលអ្នកយល់ក្នុងកម្មផលច្បាស់ រមែងមានការទទួលខុសត្រូវចំពោះខ្លួនឯង ពោលគឺ វៀរចាកអំពើអាក្រក់ជាស្រេចតែម្តង និងមានការទទួលខុសត្រូវចំពោះអ្នកដទៃ ដោយការធ្វើល្អ គ្រប់គ្រងល្អ សង្គ្រោះល្អ ។

ក្នុងបិដកលេខ ៤៦ ទំព័រ ២៦១ នៅក្នុង **និព្វេធិកសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីការទម្លាយកិលេស ដោយទ្រង់លើកយកធម៌ ៦ មុខមកសម្តែង គឺកាម ១ វេទនា ១ សញ្ញា ១ អាសវៈ ១ កម្ម ១ ទុក្ខ ១ ។ ព្រះអង្គទ្រង់សម្តែងថា បុគ្គលគប្បីដឹងនូវធម៌ ៦ មុខនេះ ក្នុងមួយមុខៗ ៦ ចំណុចគឺ តួសភាវៈនៃធម៌ទាំងនោះ ១ ហេតុនាំឱ្យកើត ១ សេចក្តីប្លែកគ្នា ១ វិបាក ១ ការរលត់ ១ បដិបទា ១ ក្នុងទំព័រ ២៧២ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពី ៦ ចំណុចរបស់កម្ម មានដូចតទៅ :

**ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ចេតយិត្វា កម្មំ ករោតិ កាយេន វាចាយ មនសា ។**

ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនា ថាជាកម្ម ព្រោះបុគ្គលគិតហើយទើបធ្វើកម្មដោយកាយ វាចា ចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ចុះហេតុដែលនាំឱ្យកើតកម្មទាំងឡាយ តើដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ផស្សៈជាហេតុនាំឱ្យកើតកម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីប្លែកគ្នានៃកម្មទាំងឡាយ តើដូច-ម្តេច ។ ម្នាលភិក្ខុទាំងឡាយ កម្មនាំឱ្យទទួលផល ក្នុងនរកក៏មាន កម្មនាំឱ្យទទួលផល ក្នុងកំណើតតិរច្ឆានក៏មាន កម្មនាំឱ្យទទួលផល ក្នុងប្រេតវិស័យក៏មាន កម្មនាំឱ្យទទួលផលក្នុងមនុស្សលោកក៏មាន កម្មនាំឱ្យទទួលផល ក្នុងទេវលោកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សេចក្តីប្លែកគ្នានៃកម្មទាំងឡាយ ។ ម្នាលភិក្ខុទាំង-ឡាយ ចុះវិបាករបស់កម្មទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវវិបាករបស់កម្មទាំងឡាយ ថាមាន ៣ ប្រការ គឺវិបាករបស់កម្ម ក្នុងបច្ចុប្បន្ន ១ វិបាករបស់កម្ម ក្នុងអត្ត-ភាពបន្ទាប់ ១ វិបាករបស់កម្ម ក្នុងអត្តភាពជាលំដាប់ៗទៅ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា វិបាករបស់កម្មទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីរលត់កម្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីរលត់កម្ម ព្រោះរលត់ផស្សៈ ។ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ជាបដិបទាមានដំណើរទៅកាន់សេចក្តីរលត់កម្ម គឺសម្មាទិដ្ឋិ ១ ។ល។ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអរិយសាវក ដឹងច្បាស់នូវកម្ម យ៉ាងនេះ ដឹងច្បាស់នូវហេតុនាំឱ្យកើតកម្មទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវ



សេចក្តីប្លែកគ្នានៃកម្មទាំងឡាយយ៉ាងនេះ ដឹងច្បាស់នូវវិបាករបស់កម្មទាំងឡាយ យ៉ាងនេះ ដឹងច្បាស់នូវសេចក្តីរលត់កម្ម យ៉ាងនេះ ដឹងច្បាស់នូវបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់កម្មយ៉ាងនេះ ហើយ អរិយសាវកនោះ ក៏ដឹងច្បាស់នូវព្រហ្មចរិយធម៌ ជាគ្រឿងទម្លុះទម្លាយនេះថាជាសេចក្តីរលត់កម្ម ។

ក្នុងបិដកលេខ ២៨ ទំព័រ ៥៤ នៅក្នុង **ចូឡកម្មវិភង្គសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីកម្មបែងចែកសត្វឱ្យថោកទាប ឬឱ្យខ្ពង់ខ្ពស់ ចំពោះសុភមាណព ។ ព្រះអង្គទ្រង់សម្តែងកម្ម ៧ គូគឺ ការសម្លាប់សត្វ និងការមិនសម្លាប់សត្វជាគូ ១ ការបៀតបៀនសត្វ និងការមិនបៀតបៀនសត្វជាគូ ១ ការខឹងក្រោធនិងការមិនខឹងក្រោធជាគូ ១ ការច្រណែននិងការមិនច្រណែនជាគូ ១ ការកំណាញ់និងការឱ្យទានជាគូ ១ ការមិនគោរពឱនលំទោននិងការគោរពឱនលំទោនជាគូ១ ការមិនសាកសួរនិងការសាកសួរជាគូ១។

នៅក្នុងទំព័រ ៦៩ ខាងចុងនៃព្រះសូត្រ ព្រះអង្គទ្រង់សម្តែងអំពីកម្ម ៧ គូនោះ ថាជាការប្រតិបត្តិប្រព្រឹត្តទៅដើម្បីឱ្យមានផលដោយសង្ខេប មានសេចក្តីដូចតទៅ :

ម្នាលមាណព ព្រោះហេតុថា សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅឱ្យមានអាយុខ្លី រមែងនាំឱ្យមានអាយុខ្លី សេចក្តីប្រតិបត្តិដែល

ប្រព្រឹត្តទៅ ដើម្បីឱ្យមានអាយុវែង រមែងនាំឱ្យមានអាយុវែង សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឱ្យមានអាពាធច្រើន រមែងនាំឱ្យមានអាពាធច្រើន សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឱ្យមានអាពាធតិច រមែងនាំឱ្យមានអាពាធតិច សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឱ្យមានសម្បុរអាក្រក់ រមែងនាំឱ្យមានសម្បុរអាក្រក់ សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីជាអ្នកមានសម្បុរជ្រះថ្លា រមែងនាំឱ្យជាអ្នកមានសម្បុរជ្រះថ្លា សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឱ្យមានស័ក្តិតូច រមែងនាំឱ្យមានស័ក្តិតូច សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឱ្យមានស័ក្តិធំ រមែងនាំឱ្យមានស័ក្តិធំ សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឱ្យមានភោគសម្បត្តិតិច រមែងនាំឱ្យមានភោគសម្បត្តិតិច សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឱ្យមានភោគសម្បត្តិច្រើន រមែងនាំឱ្យមានភោគសម្បត្តិច្រើន សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឱ្យមានត្រកូលថោកទាប រមែងនាំឱ្យមានត្រកូលថោកទាប សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឱ្យមានត្រកូលខ្ពង់ខ្ពស់ រមែងនាំឱ្យមានត្រកូលខ្ពង់ខ្ពស់ សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីមិនមានប្រាជ្ញា រមែងនាំឱ្យមិនមានប្រាជ្ញា សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឱ្យមានប្រាជ្ញាច្រើន រមែងនាំឱ្យមានប្រាជ្ញាច្រើន ។ ម្នាលមាណព



សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរលឹក កម្មតែងចែកពួកសត្វដើម្បីឱ្យថោកទាបនិងខ្ពង់ខ្ពស់ **«កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយាតិ»** ។

ក្នុងបិដកលេខ ៣០ ទំព័រ ២៦៩ នៅក្នុង **សមុទ្ទកសុត្ត** មានគាថារបស់ពួកឥសី អ្នកមានសីល មានគុណធម៌ដ៏ល្អ ដូច្នេះថា :

**យាទិសំ លភតេ ពីជំ តាទិសំ លភតេ ផលំ**
**កល្យាណការី កល្យាណំ បាបការី ច បាបកំ ។**

បុគ្គលសាបព្រោះពូជបែបណា រមែងបានទទួលផលបែបនោះ អ្នកធ្វើល្អរមែងបានល្អ អ្នកធ្វើអាក្រក់រមែងបានអាក្រក់ ។

ក្នុងបិដកលេខ ៥២ ទំព័រ ៣៥ នៅក្នុង **ពាលវគ្គ** ព្រះអង្គទ្រង់ត្រាស់ថា :

**ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ**
**យស្ស អស្សុមុខោ រោទំ វិបាកំ បដិសេវតិ ។**

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយតាមក្រោយ មានមុខទទឹកដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ គឺជាកម្មមិនល្អឡើយ ។

**តញ្ច កម្មំ កតំ សាធុ  យំ កត្វា នានុតប្បតិ**
**យស្ស បតីតោ សុមនោ  វិបាកំ បដិសេវតិ ។**

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយតាមក្រោយ មានសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ គឺជាកម្មល្អ ។

**មធុវា មញ្ញតី ពាលោ  យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ  អថ ទុក្ខំ និគច្ឆតិ ។**

ដរាបណា បាបមិនទាន់ហុចផលឱ្យ ដរាបនោះ បុគ្គលពាល សម្គាល់នូវបាបនោះថាផ្អែមដូចជាទឹកឃ្មុំ លុះដល់កាលណាបាបឱ្យផល បុគ្គលពាល ទើបជួបប្រទះនូវទុក្ខក្នុងកាលណោះ ។

ក្នុងបិដកលេខ ២៩ ទំព័រ ១៥២ **ខេមសូត្រ** ខេមទេវបុត្រ បានពោលនូវពាក្យជាសុភាសិតនេះ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ខេមទេវបុត្រ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ពោលគាថាទាំងនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា កម្មដ៏លាមកណាមានផលក្តៅផ្សា ពួកជនពាល ឥតប្រាជ្ញា មានខ្លួនដូចជាសត្រូវ រមែងប្រព្រឹត្តធ្វើនូវកម្មដ៏លាមកនោះ ។ បុគ្គលធ្វើកម្មណាហើយ





តែងក្តៅក្រហាយតាមក្រោយ (ឬ) បុគ្គលមានមុខទទឹកដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា កម្មដែលបុគ្គលធ្វើហើយនោះ មិនប្រពៃទេ ។ បុគ្គលធ្វើកម្មណាហើយ មិនក្តៅក្រហាយតាមក្រោយ (ឬ )បុគ្គលមានសេចក្តីត្រេកអរ មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលបុគ្គលធ្វើហើយនោះ ជាកម្មប្រពៃ ។ បុគ្គលដឹងនូវកម្មណា ដែលជាប្រយោជន៍ដល់ខ្លួន ត្រូវតែធ្វើកម្មនោះជាមុនឱ្យហើយ ។ អ្នកប្រាជ្ញដែលមានប្រាជ្ញា មានសេចក្តីប្រឹងប្រែង មិនត្រូវធ្វើកម្មដោយគំនិតដូចជាអ្នកបររទេះឡើយ អ្នកបររទេះ ព្រោះតែលះបង់ផ្លូវស្មើ លះបង់ផ្លូវធំចេញ ហើយបរឡើងលើផ្លូវមិនស្មើវិញ រមែងបាក់ភ្លៅរទេះ ហើយសញ្ជប់សញ្ជឹងយ៉ាងណាមិញ ឯបុគ្គលខ្លៅ ព្រោះតែគេចចេញអំពីកុសលធម៌ ហើយប្រព្រឹត្តតាមអកុសលធម៌វិញ ក៏រមែងដល់នូវមាត់នៃមច្ចុ ហើយសញ្ជប់សញ្ជឹងដូចជាអ្នកបររទេះបាក់ភ្លៅ យ៉ាងនោះឯង ។

＊ បុគ្គលមានសិទ្ធិដោយធម្មជាតិ ដែលនឹងធ្វើកម្មផ្សេងៗ ដើម្បីសាងខ្លួនឱ្យប្រសើរឡើង ។ សមត្ថភាពក្តី គុណធម៌ក្តី ការបដិបត្តិក្តី ទាំងអស់នេះគឺជាគ្រឿងសម្រាប់វាស់នូវភាពថោកទាប ឬខ្ពង់ខ្ពស់របស់មនុស្ស មិនមែនបែងចែកគ្នាដោយជាតិត្រកូល ឬវណ្ណៈឡើយ ។

ក្នុងបិដកលេខ ២៥ ទំព័រ ២១១ នៅក្នុង **វាសេដ្ឋសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីពាក្យថាព្រាហ្មណ៍ :

ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា ក្នុងបណ្តាមនុស្សទាំងឡាយ មនុស្សណាមួយចិញ្ចឹមជីវិតដោយការភ្ជួររាស់ អ្នកនោះជាអ្នកភ្ជួររាស់ មិនមែនជាព្រាហ្មណ៍ទេ ។

បណ្តាមនុស្សទាំងឡាយ មនុស្សណា ចិញ្ចឹមជីវិតដោយសិប្បៈផ្សេងៗ (មានការត្បាញជាដើម ) ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះឈ្មោះថា ជាអ្នកមានសិប្បៈ មិនមែនព្រាហ្មណ៍ទេ។បណ្តាមនុស្សទាំងឡាយ មនុស្សណាមួយចិញ្ចឹមជីវិតដោយការជួញ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះជាពាណិជ មិនមែនព្រាហ្មណ៍ទេ ។ បណ្តាមនុស្សទាំងឡាយ មនុស្សណាចិញ្ចឹមជីវិតដោយការបម្រើអ្នកដទៃ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះជាអ្នកបម្រើគេ មិនមែនព្រាហ្មណ៍ទេ ។ បណ្តាមនុស្សទាំងឡាយ មនុស្សណាមួយ ចិញ្ចឹមជីវិត ដោយការលួច ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះជាចោរ មិនមែនព្រាហ្មណ៍ទេ។បណ្តាមនុស្សទាំងឡាយ មនុស្សណាមួយចិញ្ចឹមជីវិត ដោយការកាន់គ្រឿងសស្ត្រាវុធ ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះជាទាហាន មិនមែនព្រាហ្មណ៍ទេ ។ បណ្តា





មនុស្សទាំងឡាយ មនុស្សណាចិញ្ចឹមជីវិតដោយនាទីជាបុរោហិត ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះជាអ្នកបូជា មិនមែនព្រាហ្មណ៍ទេ ។ បណ្តាមនុស្សទាំងឡាយ មនុស្សណាមួយបរិភោគស្រុកឬដែន ម្នាលវាសេដ្ឋៈ អ្នកចូរដឹងយ៉ាងនេះថា អ្នកនោះជាព្រះរាជា មិនមែនព្រាហ្មណ៍ទេ មួយទៀត តថាគតមិនបានពោលបុគ្គលដែលកើតអំពីកំណើត ឬកើតអំពីសំណាក់នៃមាតាថាជាព្រាហ្មណ៍ទេ បុគ្គលនោះ គ្រាន់តែឈ្មោះថាភោវាទី (អ្នកពោលថាភោភោ ) ព្រោះបុគ្គលនោះឯង នៅមានកង្វល់គឺកិលេស លុះតែបុគ្គលមិនមានកង្វល់ មិនមានសេចក្តីប្រកាន់មាំ ទើបតថាគតពោលថាជាព្រាហ្មណ៍ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ហៅបុគ្គលថាជាព្រាហ្មណ៍ នៅមានសេចក្តីច្រើនទៀត ក្នុងន័យអ្នកបានលះបង់នូវកិលេស រួចហើយជាបន្តព្រះអង្គទ្រង់ត្រាស់សម្តែងថា :

នាមនិងគោត្រដែលគេបានកំណត់តាំងទុក ហៅតៗគ្នាមកឈ្មោះនេះ គ្រាន់តែជាវោហារក្នុងលោក ដែលពួកញាតិ និងសាលោហិត បានកំណត់តាំងទុក ។ ក្នុងកាលព្រាហ្មណ៍កើតហើយក្នុងទីនោះៗ ក៏កើតជាទិដ្ឋិដេកត្រាំនៅក្នុងពួកជនដែលមិនដឹងអស់កាលជាយូរអង្វែង កាលបើពួកជនទាំងនោះមិនដឹង ក៏នាំគ្នា

និយាយថា បុគ្គលជាព្រាហ្មណ៍ព្រោះជាតិ ។ បុគ្គលខ្វចកាច មិនមែនព្រោះជាតិទេ បុគ្គលដែលជាព្រាហ្មណ៍ ក៏មិនមែនព្រោះជាតិដែរ តាមពិតបុគ្គលដែលខ្វចកាចព្រោះកម្ម(គឺការងារក្នុងបច្ចុប្បន្ន) បុគ្គលដែលជាព្រាហ្មណ៍ក៏ព្រោះកម្ម ជាអ្នកស្រែក៏ព្រោះកម្ម ជាអ្នកមានសិប្បៈក៏ព្រោះកម្ម ជាពាណិជក៏ព្រោះកម្ម ជាអ្នកបម្រើគេក៏ព្រោះកម្ម ទោះបីជាចោរក៏ព្រោះកម្ម ជាទាហានក៏ព្រោះកម្ម ជាអ្នកបូជាក៏ព្រោះកម្ម ជាព្រះរាជាក៏ព្រោះកម្ម។ អ្នកប្រាជ្ញទាំងឡាយបានឃើញច្បាស់នូវធម៌ជាបច្ច័យអាស្រ័យកើតតៗគ្នា ជាអ្នកឈ្លាសក្នុងវិបាករបស់កម្ម តែងឃើញកម្មនេះ តាមសេចក្តីពិតយ៉ាងនេះថា **លោកតែងប្រព្រឹត្តទៅតាមកម្ម** ប្រជាជនតែងប្រព្រឹត្តទៅតាមកម្ម សត្វទាំងឡាយដែលជាប់នៅក្នុងកម្ម ទើបប្រព្រឹត្តទៅបានដូចជារទេះដែលមានភ្លៅ ទើបបរទៅបាន ។

**វាសេដ្ឋសូត្រ** នេះក៏មាននៅក្នុងបិដកលេខ ៥៤ ដែរ ទំព័រ ២០៦ គឺជាព្រះសូត្រតែមួយ ។

ក្នុងបិដកលេខ ២៥ ទំព័រ ១៥២ នៅក្នុង **ឯសុការីសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីការបម្រើ :

ម្នាលព្រាហ្មណ៍ តថាគតមិនពោលថា បុគ្គលគាប់ប្រសើរព្រោះតែមានត្រកូលខ្ពស់ទេ ម្នាលព្រាហ្មណ៍ ទាំងតថាគតនឹងបាន





ពោលថាបុគ្គលថោកថយ ព្រោះតែមានត្រកូលខ្ពស់ក៏ទេដែរ ។ ម្នាលព្រាហ្មណ៍ តថាគតមិនពោលថា បុគ្គលគាប់ប្រសើរ ព្រោះតែមានជាតិថ្លៃថ្លាទេ ម្នាលព្រាហ្មណ៍ ទាំងតថាគតនឹងបានពោលថាបុគ្គលថោកទាប ព្រោះតែមានជាតិថ្លៃថ្លាក៏ទេដែរ ។ ម្នាលព្រាហ្មណ៍ តថាគតមិនពោលថា បុគ្គលប្រសើរវិសេស ព្រោះតែមានភោគៈលើសលុបទេ ម្នាលព្រាហ្មណ៍ ទាំងតថាគតនឹងបានពោលថាបុគ្គលថោកទាប ព្រោះតែមានភោគៈលើសលុបក៏ទេដែរ។ ម្នាលព្រាហ្មណ៍ ព្រោះថាបុគ្គលពួកខ្លះ ក្នុងលោកនេះ សូម្បីមានត្រកូលខ្ពង់ខ្ពស់ តែជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តកាមេសុមិច្ឆា ពោលពាក្យមុសា មានវាចាញុះញង់ មានវាចាទ្រគោះ និយាយពាក្យឥតប្រយោជន៍ ជាអ្នកមានអភិជ្ឈា មានចិត្តព្យាបាទ ជាមិច្ឆាទិដ្ឋិ ហេតុនោះបានជា តថាគតមិនពោលថាបុគ្គលប្រសើរវិសេស ព្រោះតែមានត្រកូលខ្ពង់ខ្ពស់ទេ ។ ម្នាលព្រាហ្មណ៍ ព្រោះថាបុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានត្រកូលខ្ពង់ខ្ពស់ ហើយបានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិក៏មាន ហេតុនោះ បានជាតថាគត

មិនពោលថាបុគ្គលថោកទាប ព្រោះតែមានត្រកូលខ្ពង់ខ្ពស់ទេ ។ ម្នាលព្រាហ្មណ៍ មនុស្សពួកខ្លះក្នុងលោកនេះ ទុកជាមានជាតិថ្លៃថ្លាក៏ដោយ តែជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តកាមេសុមិច្ឆា ពោលពាក្យមុសា មានវាចាញុះញង់ មានសំដីអាក្រក់ និយាយពាក្យឥតប្រយោជន៍ មានអភិជ្ឈា មានចិត្តព្យាបាទ ជាមិច្ឆាទិដ្ឋិ ហេតុនោះបានជា តថាគតមិនពោលថា បុគ្គលវិសេសវិសាល ព្រោះតែមានជាតិថ្លៃថ្លាទេ ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានជាតិថ្លៃថ្លា ហើយបានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិក៏មាន ហេតុនោះ បានជាតថាគតមិនពោលថា បុគ្គលថោកទាប ព្រោះតែមានជាតិថ្លៃថ្លាទេ ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ សូម្បីមានភោគៈលើសលុប តែជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តកាមេសុមិច្ឆា ពោលពាក្យមុសា មានវាចាញុះញង់ មានពាក្យអាក្រក់ និយាយពាក្យឥតប្រយោជន៍ ជាអ្នកមានអភិជ្ឈា មានចិត្តព្យាបាទ ជាមនុស្សមិច្ឆាទិដ្ឋិ ហេតុនោះបានជាតថាគតមិនពោលថា បុគ្គលប្រសើរវិសេស ព្រោះតែមានភោគៈលើសលុប



ទេ ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានភោគៈដ៏លើសលុប ហើយបានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិក៏មាន ហេតុនោះបានជាតថាគតមិនពោលថា បុគ្គលថោកទាប ព្រោះតែមានភោគៈលើសលុបទេ ។ ម្នាលព្រាហ្មណ៍ តថាគតមិនពោលថា ត្រូវតែបម្រើអ្នកទាំងអស់ (នោះ )ទេ ម្នាលព្រាហ្មណ៍ ទាំងតថាគតនឹងបានពោលថា មិនត្រូវបម្រើអ្នកទាំងអស់ក៏ទេដែរ ។ ម្នាលព្រាហ្មណ៍ ព្រោះថាកាលបើគេបម្រើបុគ្គលណា សទ្ធាចម្រើន សីលចម្រើន សុតៈចម្រើន ចាគៈចម្រើន ប្រាជ្ញាក៏ចម្រើន ព្រោះការបម្រើ (នោះ ) ជាហេតុ តថាគតទើបពោលថា ត្រូវបម្រើបុគ្គលនោះ ។

ក្នុងបិដកលេខ ៥៤ ទំព័រ ៤៣ នៅក្នុង **វសលសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្ដែងអំពីបុគ្គលថោកទាបព្រោះកម្ម មានដូចតទៅ :

បុគ្គលណា មានសេចក្ដីក្រោធ ចងសេចក្ដីក្រោធទុក (គំនុំ) ជាបុគ្គលបាប លុបគុណគេ ប្រាសចាកសម្មាទិដ្ឋិ មានមាយា អ្នក

ចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ក្នុងលោកនេះ បៀតបៀននូវសត្វដែលមានកំណើតម្តង ឬមានកំណើតពីរដង ឬបុគ្គលណា មិនមានសេចក្តីអាណិតចំពោះសត្វ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប។

បុគ្គលណា សម្លាប់ឬឡោមរឹបជាន់នូវអ្នកស្រុកឬអ្នកនិគម ដែលអ្នកផងដឹងច្បាស់ថា ជាអ្នកសង្កត់សង្កិនគេ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា កាន់យកទ្រព្យក្នុងស្រុក ឬក្នុងព្រៃដែលបុគ្គលប្រកាន់ថាជារបស់អញ ជាទ្រព្យដែលគេមិនឱ្យ ដោយអាការលួច អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា បុលទ្រព្យគេ យកមកប្រើប្រាស់ ហើយគេចតែថា (អញ) មិនជំពាក់បំណុលអ្នកទេ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា សម្លាប់អ្នកផង ដែលដើរក្នុងផ្លូវ ដោយប្រាថ្នាទ្រព្យរបស់ណាមួយ ដណ្តើមយកទ្រព្យរបស់ណាមួយ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា គេសួរជាបន្ទាល់និយាយកុហក ព្រោះហេតុនៃខ្លួនក្តី ព្រោះហេតុនៃបុគ្គលដទៃក្តី ព្រោះហេតុនៃទ្រព្យក្តី អ្នកចូរ





ដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ប្រព្រឹត្តខូច ចំពោះប្រពន្ធរបស់ពួកញាតិ ឬសម្លាញ់ដោយការកំហែង ឬដោយការស្រឡាញ់ស្ម័គ្រចិត្ត អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ជាអ្នកស្តុកស្តម្ភ តែមិនចិញ្ចឹមមាតា ឬបិតា ដែលចាស់ជរា មានវ័យកន្លងហើយ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ប្រហារមាតា ឬបិតា បងប្អូនប្រុស បងប្អូនស្រី ឬម្តាយក្មេក ឬក៏ជេរប្រទេចដោយវាចា អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា កាលដែលគេសួរចំពោះហេតុមានប្រយោជន៍ ហើយពន្យល់ប្រាប់ហេតុដែលគ្មានប្រយោជន៍ បង្ហាញដោយពាក្យបិទបាំង អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា បានធ្វើបាបកម្ម ហើយប្រាថ្នាថា អ្នកផងកុំគប្បីដឹងនូវអញ បុគ្គលណា មានការងារបិទបាំង អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ទៅកាន់ត្រកូលញាតិមិត្តដទៃ ទាំងបានបរិភោគភោជនដ៏ស្អាត ហើយមិនបានបូជាគេដែលមកកាន់ផ្ទះរបស់ខ្លួនវិញ

អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា បញ្ឆោតព្រាហ្មណ៍ក្តី សមណៈក្តី ឬអ្នកសូមឯទៀតក្តី ដោយពាក្យកុហក អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ជេរសមណៈឬព្រាហ្មណ៍ដោយវាចាក្តី មិនឱ្យភោជនក្នុងវេលាភត្តកាល ដែលគួរទំនុកបម្រុងក្តី អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ក្នុងលោកនេះ ត្រូវមោហៈរួបរឹតហើយ កាលស្វែងរកចំពោះទ្រព្យណាមួយ ក៏និយាយបោកប្រាស់ដោយពាក្យមិនពិត (នឹងស្ត្រី) អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា លើកតម្កើងខ្លួនឯង ឬបន្តុះបង្អាប់ពួកជនដទៃ តែខ្លួនជាអ្នកសាបសូន្យ (ចាកគុណ) ព្រោះការតម្កើងនិងការបន្តុះបង្អាប់របស់ខ្លួន អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា កោងកាចក្តី ស្វូរកន្ទ្រីសក្តី មានសេចក្តីប្រាថ្នាអាក្រក់ក្តី កំណាញ់ក្តី អំនួតក្តី មិនអៀនខ្មាសក្តី មិនខ្លាចបាបក្តី អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គលថោកទាប ។

បុគ្គលណា ជេរប្រទេចព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ឬបរិព្វាជក ឬក៏គ្រហស្ថ អ្នកចូរដឹងបុគ្គលនោះ ថាជាបុគ្គល





ថោកទាប ។

បុគ្គលណា មិនមែនជាព្រះអរហន្តទេ តែប្តេជ្ញា (ខ្លួន) ថាជាព្រះអរហន្ត បុគ្គលនោះ ជាចោរក្នុងលោកព្រមទាំងព្រហ្មលោកនេះឯងជាបុគ្គលថោកទាបបំផុត ។

បុគ្គលថោកទាប ទាំងនេះឯង តថាគតបានប្រកាសហើយ បុគ្គលមិនមែនថោកទាប ព្រោះជាតិទេ ក៏មិនមែនជាព្រាហ្មណ៍ព្រោះជាតិដែរ គឺបុគ្គលថោកទាបព្រោះកម្ម ជាព្រាហ្មណ៍ក៏ព្រោះកម្ម ។

អ្នកទាំងឡាយ ចូរដឹងនូវសេចក្តីនោះ ដោយពាក្យនេះចុះ ដូចឧទាហរណ៍នេះឯង កូនរបស់មនុស្សចណ្ឌាល មានឈ្មោះប្រាកដថា សោបាកមាតង្គៈ មាតង្គកុមារនោះ បាននូវយសដ៏ប្រសើរ ដែលគេបានដោយក្រក្រៃលែង ពួកក្សត្រព្រាហ្មណ៍ជាច្រើន តែងមកកាន់ទីបម្រើរបស់កុមារនោះ ។

មាតង្គកុមារនោះ ឡើងកាន់យានគឺសមាបត្តិ ៨ អាចឱ្យទៅកាន់ទេវលោកប្រាសចាកធូលីគឺកិលេស ជាផ្លូវធំ នឿយណាយនឹងកាមរាគហើយទៅកើតក្នុងព្រហ្មលោក ។

ជាតិមិនមែនឃាត់មាតង្គៈនោះ ចាកការកើតក្នុងព្រហ្ម-លោកទេ ។ ពួកព្រាហ្មណ៍ជាផៅពង្សអ្នកស្វាធ្យាយមន្ត កើតក្នុង

ត្រកូលអ្នករៀនមន្ត តែពួកព្រាហ្មណ៍ទាំងនោះ រមែងប្រាកដក្នុងបាបកម្មទាំងឡាយរឿយៗ ទើបត្រូវគេតិះដៀលក្នុងបច្ចុប្បន្ន និងភពខាងមុខក៏ជាទុគ្គតិ (ព្រោះបាបកម្មជាបច្ច័យ) ។

ជាតិមិនមែនឃាត់ព្រាហ្មណ៍ទាំងនោះ ចាកទុគ្គតិ ឬចាកការតិះដៀលទេ ។ បុគ្គលមិនមែនថោកទាបព្រោះជាតិទេ ក៏មិនមែនជាព្រាហ្មណ៍ព្រោះជាតិដែរ បុគ្គលថោកទាបព្រោះកម្ម ជាព្រាហ្មណ៍ ក៏ព្រោះកម្ម ។

ក្នុងបិដកលេខ ៤៨ ទំព័រ ៩៥ នៅក្នុង **បហារាទសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្ដែងថា :

ម្នាលបហារាទ វណ្ណៈទាំង ៤ នេះគឺក្សត្រ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ បើវណ្ណៈទាំងនោះចេញចាកផ្ទះ ចូលកាន់ផ្នួសបួសក្នុងធម្មវិន័យដែលតថាគតប្រកាសហើយ រមែងលះបង់នូវនាមនិងគោត្រដើមរបស់ខ្លួន ហើយដល់នូវកិរិយារាប់ថា ជាសមណសក្យបុត្តិយ៍តែម្យ៉ាង ប្រៀបដូចជាទន្លេធំៗទាំងឡាយ មានទន្លេគង្គា យមុនា អចិរវតី សរភូ មហី ជាដើម កាលបើទន្លេទាំងនោះ ហូរចូលទៅដល់មហាសមុទ្រហើយ តែងលះបង់នូវឈ្មោះរបស់ខ្លួនហើយដល់នូវកិរិយារាប់ថាជាមហាសមុទ្រតែម្យ៉ាងដូច្នោះឯង ។



ក្នុងបិដកលេខ ១៨ ទំព័រ ១៦៧ នៅក្នុង **អគ្គញ្ញសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្ដែងថា :

បណ្ដាវណ្ណៈទាំង ៤ នេះ បុគ្គលណាជាភិក្ខុអស់អាសវៈហើយ ប្រព្រឹត្តព្រហ្មចារ្យរួចស្រេចហើយ បានធ្វើកិច្ចស្រេចហើយ មានភារៈដាក់ចុះហើយ បានសម្រេចនូវប្រយោជន៍របស់ខ្លួនតាមលំដាប់ហើយ អស់គ្រឿងចងឱ្យនៅក្នុងភពហើយ មានចិត្តផុតស្រឡះហើយ ព្រោះបានដឹងដោយប្រពៃ បុគ្គលនោះឯង ប្រាកដជាអ្នកប្រសើរលើសជាងវណ្ណៈទាំងនោះ ដោយធម៌ពិត មិនមែនដោយអធម៌ទេ ។

ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុត ក្នុងប្រជុំជន ទាំងបច្ចុប្បន្ននិងបរលោក ។

# ការបដិបត្តិដើម្បីប្រយោជន៍សុខ
# ដល់ជនច្រើន

នៅពេលចេញវស្សាទី ១ របស់ព្រះដ៏មានព្រះភាគ ក្នុងកាលណោះ ព្រះអង្គទ្រង់ត្រាស់ទៅកាន់ព្រះអរហន្ត ៦០ អង្គ ដែលមានសេចក្ដីទាំងស្រុងក្នុងវិន័យបិដកលេខ ៦ ទំព័រ ៦៦ ដូចតទៅ:

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ហៅភិក្ខុទាំងឡាយមកហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតរួចហើយអំពីអន្ទាក់ទាំងអស់ ទោះបីជារបស់ទេវតាក្ដី ទោះបីជារបស់មនុស្សក្ដី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសោតក៏បានរួចហើយអំពីអន្ទាក់ទាំងអស់ដែរ ទោះបីរបស់ទេវតាក្ដី ទោះបីរបស់មនុស្សក្ដី ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រាច់ទៅកាន់ចារិក (គឺស្រុកនិងនិគម និងរាជធានី ហើយសំដែងធម៌ ) ដើម្បីជាប្រយោជន៍ និងសេចក្ដីសុខដល់ជនជាច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីជាប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ អ្នកទាំងឡាយកុំទៅពីរនាក់តាមផ្លូវមួយជាមួយ





គ្នាឡើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរសម្ដែងធម៌ ឱ្យពីរោះបទដើមបទកណ្ដាល និងបទចុង អ្នកទាំងឡាយចូរប្រកាសនូវព្រហ្មចរិយធម៌ដ៏បរិសុទ្ធប្រកបដោយអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌ទាំងអស់ សត្វទាំងឡាយដែលមានធូលីគឺរាគាទិក្កិលេសតិចក្នុងភ្នែកក៏មាន សត្វទាំងនោះនឹងសាបសូន្យ (ចាកមគ្គផល ) ព្រោះមិនបានស្ដាប់ធម៌ សត្វទាំងឡាយអ្នកបម្រុងត្រាស់ដឹងធម៌គង់នឹងមាន ម្នាលភិក្ខុទាំងឡាយ ចំណែកតថាគតក៏នឹងចូលទៅកាន់សេនានិគម ក្នុងឧរុវេលាប្រទេស ដើម្បីសម្ដែងធម៌ ។

ក្នុងបិដកលេខ ២៩ ទំព័រ ២៨៧ **ឧត្តិយបាសសូត្រ** មានសេចក្ដីផ្ដើមថា :

ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ។ កាលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីនោះ បានត្រាស់ហៅភិក្ខុទាំងឡាយថាម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយទទួលព្រះពុទ្ធ-ដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូចបានសរសេរហើយពីខាងដើម គឺទ្រង់ត្រាស់ឱ្យព្រះភិក្ខុនិមន្តទៅសម្ដែងព្រះធម៌ តាមផ្លូវមួយតែមួយអង្គ កុំទៅពីរអង្គតាមផ្លូវមួយជាមួយគ្នាឡើយ ។

ក្នុងបិដកលេខ ៤៣ ទំព័រ ១៣ **សុគតសូត្រ** មានសេចក្តីទាំងស្រុងដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ កាលព្រះសុគតក្តី វិន័យព្រះសុគតក្តី ប្រតិស្ឋាននៅក្នុងលោក ការនោះប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោកដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះព្រះសុគតដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតកើតឡើងក្នុងលោកនេះជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ព្រះអង្គមានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ត្រាស់ដឹងនូវចតុរារិយ-សច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ។ ម្នាលភិក្ខុទាំងឡាយនេះជាព្រះសុគត ។ ម្នាលភិក្ខុទាំងឡាយ ចុះវិន័យព្រះសុគតដូចម្តេច ។ ព្រះសុគតនោះ ទ្រង់សម្តែងធម៌ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកាសនូវព្រហ្មចរិយៈ ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ។ ម្នាលភិក្ខុ



ទាំងឡាយ នេះជាវិន័យព្រះសុគត ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះសុគតក្តី វិន័យព្រះសុគតក្តី ប្រតិស្ឋាននៅក្នុងលោកយ៉ាងនេះ ការនោះប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការនេះប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ធម៌ ៤ ប្រការគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ រៀនព្រះសូត្រដែលខ្លួនរៀនខុស ដោយបទនិងព្យញ្ជនៈដែលរៀបរៀងខុសលំដាប់ ម្នាលភិក្ខុទាំងឡាយ បទនិងព្យញ្ជនៈដែលរៀបរៀងខុសលំដាប់ រមែងយល់សេចក្តីបានដោយលំបាក ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុទាំងឡាយ ជាមនុស្សដែលគេប្រដៅបានដោយក្រ ប្រកបដោយធម៌ដែលឱ្យគេប្រដៅក្រ ជាអ្នកមិនចេះអត់ធន់ មិនទទួលពាក្យប្រៀនប្រដៅខាងស្តាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុទាំងឡាយណា ជាអ្នកមាន

សេចក្តីចេះដឹងច្រើន មានអាគមគឺនិកាយដ៏ស្ទាត់ ចងចាំនូវធម៌ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ មិនញុំាងបុគ្គលដទៃឱ្យរៀនព្រះសូត្រដោយគោរព លុះអំណើះទៅមុខ ព្រះសូត្ររបស់ភិក្ខុទាំងនោះក៏ដាច់មូលលែងប្រតិស្ឋាននៅ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុទាំងឡាយជាថេរៈជាអ្នកប្រតិបត្តិដើម្បីឱ្យកើតបច្ច័យច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាអ្នកដាក់ធុរៈក្នុងវិវេក មិនប្រារព្ធព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ប្រជុំនៃជនដែលកើតខាងក្រោយគឺ សទ្ធិវិហារិក និងអន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុជាថេរៈទាំងនោះ ប្រជុំនៃជនទាំងនោះឯង ជាអ្នកប្រតិបត្តិដើម្បីឱ្យកើតបច្ច័យច្រើន ប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាអ្នកដាក់ធុរៈក្នុងវិវេក មិនប្រារព្ធព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់



ធ្វើឱ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ យ៉ាងនេះឯងដែលប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសសាបសូន្យនៃព្រះសទ្ធម្ម ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ នេះប្រព្រឹត្តទៅ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឱ្យវិនាសសាបសូន្យទៅ ។ ធម៌ ៤ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ រៀនព្រះសូត្រដែលខ្លួនរៀនត្រូវ ដោយបទនិងព្យញ្ជនៈដែលរៀបរៀងត្រូវ ម្នាលភិក្ខុទាំងឡាយ បទនិងព្យញ្ជនៈដែលរៀបរៀងត្រូវ រមែងយល់សេចក្តីបានងាយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ១ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឱ្យវិនាសសាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយ ជាអ្នកប្រដៅងាយ ប្រកបដោយធម៌ធ្វើឱ្យជាអ្នកប្រដៅងាយ ជាអ្នកចេះអត់ធន់ ទទួលនូវពាក្យប្រៀនប្រដៅខាងស្តាំ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ២ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឱ្យវិនាសសាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីចេះដឹងច្រើន មានអាគមគឺនិកាយដ៏ស្ទាត់ ចងចាំនូវធម៌ ចងចាំនូវវិន័យ ចងចាំនូវមាតិកា ភិក្ខុទាំងនោះ

ញុំាងបុគ្គលដទៃឱ្យរៀនព្រះសូត្រដោយគោរព លុះអំណើះទៅមុខ ព្រះសូត្ររបស់ភិក្ខុទាំងនោះមិនបានដាច់ឫស តាំងនៅតៗគ្នា ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៣ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឱ្យវិនាសសាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុទាំងឡាយជាថេរៈមិនប្រតិបត្តិដើម្បីឱ្យកើតបច្ច័យច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ ដាក់ធុរៈចុះក្នុងការប្រតិបត្តិបន្ធូរបន្ថយចេញ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់សម្រេច ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ប្រជុំជនដែលកើតខាងក្រោយគឺ សទ្ធិវិហារិកនិងអន្តេវាសិក ក៏យកតម្រាប់តាមភិក្ខុទាំងនោះ ប្រជុំជនទាំងនោះឯង ជាអ្នកមិនប្រតិបត្តិឱ្យកើតបច្ច័យច្រើន មិនប្រតិបត្តិបន្ធូរបន្ថយ ជាអ្នកដាក់ធុរៈចុះក្នុងការប្រតិបត្តិបន្ធូរបន្ថយ ជាប្រធានក្នុងវិវេក ប្រារព្ធព្យាយាមដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់បានដល់ ដើម្បីសម្រេចគុណវិសេស ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឱ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់ធ្វើឱ្យជាក់ច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ទី ៤ ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិន





ឱ្យវិនាសសាបសូន្យទៅ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ យ៉ាងនេះឯង ដែលប្រព្រឹត្តទៅដើម្បីតាំងនៅនៃព្រះសទ្ធម្ម មិនឱ្យវិនាសសាបសូន្យទៅ ។

ក្នុងបិដកលេខ ១៦ ទំព័រ ២៥៣ នៅក្នុង **មហាបរិនិព្វាន-សូត្រ** ព្រះអង្គទ្រង់ណែនាំឱ្យរៀនសូត្រនិងបដិបត្តិ ដើម្បីឱ្យសាសនព្រហ្មចរិយៈឋិតនៅអស់កាលយូរ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ពពួកជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក មានសេចក្តីដូចតទៅ :

គ្រានោះ ព្រះមានព្រះភាគទ្រង់ស្តេចចូលទៅកាន់ឧបដ្ឋាន-សាលា លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្ម-ចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្តែងហើយដោយបញ្ញា ដ៏

ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើរឿយៗ ដោយប្រការដូច្នោះ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណាដែលតថាគតសម្តែងហើយដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើរឿយៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះតើដូចម្តេច ។ អ្វីខ្លះ។ គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ



ដោយប្រការណា ធម៌ទាំងឡាយណាដែលតថាគតសម្តែងហើយដោយបញ្ញាដ៏ឧត្តម អ្នកទាំងឡាយ គប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើរឿយៗ ។ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ យ៉ាងនេះឯង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយមានសេចក្តីវិនាសទៅជាធម្មតា អ្នកទាំងឡាយចូរញ៉ាំងកិច្ចទាំងពួងឱ្យសម្រេចដោយសេចក្តីមិនប្រមាទចុះ បរិនិព្វាននឹងមានដល់តថាគតមិនយូរឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ព្រះសុគតជាសាស្តាលុះទ្រង់មានព្រះបន្ទូលដូច្នេះហើយ ក៏ទ្រង់មានព្រះបន្ទូល ដូច្នេះតទៅទៀតថា :

ពួកជនណា ៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ ។ ភាជន៍ដី ដែលស្មូនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះមានកិរិយាបែកធ្លាយជាទីបំផុតយ៉ាងណា ជីវិតរបស់សត្វទាំងឡាយក៏យ៉ាងនោះដែរ ។

ព្រះសាស្តា ទ្រង់មានព្រះបន្ទូលដូច្នេះតទៅទៀតថា :

វ័យរបស់តថាគត ចាស់ហើយ ជីវិតរបស់តថាគតមានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយហើយទៅ ឯទីពឹងចំពោះខ្លួន តថាគតបានធ្វើទុកហើយ ។

**អប្បមត្តា សតីមន្តោ សុសីលា ហោថ ភិក្ខវោ**
**សុសមាហិតសង្កប្បា សចិត្តមនុរក្ខថ ។**
**យោ ឥមស្មឹ ធម្មវិនយេ អប្បមត្តោ វិហរិស្សតិ**
**បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតីតិ ។**

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អ មានតម្រិះតម្កល់នឹងល្អ ចូររក្សាចិត្តរបស់ខ្លួនឱ្យរឿយៗចុះ ។ ភិក្ខុណាមិនប្រមាទ ហើយនៅក្នុងធម្មវិន័យនេះ ភិក្ខុនោះ នឹងលះបង់នូវជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃកងទុក្ខបានមិនខានឡើយ ។

ក្នុងបិដកលេខ ១៨ ទំព័រ ២៥៨ នៅក្នុង **បាសាទិកសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីពោធិបក្ខិយធម៌ទាំង ៣៧ ប្រការ ចែកជា ៧ ពួក មានពួកសតិប្បដ្ឋាន ៤ ជាដើម ថាគួររួបរួមផ្ទៀងផ្ទាត់ នូវអត្ថ ដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈ ក្នុងធម៌នោះ ដែលជាហេតុឱ្យ ព្រហ្មចារ្យនេះ តាំងនៅមាំ ឋិតថេរអស់កាលយូរ ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន





ដើម្បីអនុគ្រោះដល់សត្វលោក ។

ក្នុងបិដកលេខ ៥៣ ទំព័រ ១៧ នៅក្នុង **មោទសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីសាមគ្គីរបស់សង្ឃ មានសេចក្តីដូចតទៅ :

**សុខា សង្ឃស្ស សាមគ្គី សមគ្គានញ្ចនុគ្គហោ**
**សមគ្គរតោ ធម្មដ្ឋោ យោគក្ខេមា ន ធំសតិ**
**សង្ឃំ សមគ្គំ កត្វាន កប្បំ សគ្គម្ហិ មោទតីតិ ។**

សេចក្តីព្រមព្រៀងនៃសង្ឃ ជាហេតុនាំសេចក្តីសុខមកឱ្យការអនុគ្រោះដល់បុគ្គលទាំងឡាយ ដែលមានសេចក្តីព្រមព្រៀងគ្នា (ជាហេតុនាំសេចក្តីសុខមកឱ្យ) បុគ្គលត្រេកអរ ក្នុងជនដែលព្រម-ព្រៀងគ្នា តាំងនៅក្នុងធម៌ រមែងមិនសាបសូន្យចាកធម៌ជាទីក្សេមចាកយោគៈ បុគ្គលធ្វើសង្ឃឱ្យព្រមព្រៀងគ្នា រមែងរីករាយក្នុងឋានសួគ៌អស់ ១ កប្ប ។

ក្នុងបិដកលេខ ២៦ ទំព័រ ៩៩ នៅក្នុង **សាមគ្គាមសូត្រ** ព្រះអង្គសម្តែងអំពីវិវាទមូល ៦ ប្រការ :

១.ច្រើនដោយក្រោធ និងការចងគំនុំ
២.ការរមិលគុណ និងការលើកខ្លួនវាយឫក
៣.ច្រណែន និងកំណាញ់
៤.អំនួតអួតអាង និងមាយាលាក់ពុត

៥.ការប្រាថ្នាអាក្រក់ និងការយល់ខុស

៦.ការស្ទាបអង្អែលនូវសីលព្វ័ត ហើយមានការប្រកាន់តាមទិដ្ឋិរបស់ខ្លួន និងការប្រកាន់មាំ លះបង់បានដោយកម្រ ។

ព្រះអង្គទ្រង់ត្រាស់សម្តែងថា :

ម្នាលអានន្ទ ភិក្ខុណា ជាអ្នកច្រើនដោយក្រោធ និងការចងគំនុំ (៥ ប្រការទៀតក៏ដូចគ្នា )ភិក្ខុនោះ ឈ្មោះថាមិនគោរព មិនកោតក្រែងចំពោះព្រះសាស្តាផង មិនគោរព មិនកោតក្រែងចំពោះព្រះធម៌ផង មិនគោរព មិនកោតក្រែងចំពោះព្រះសង្ឃផង មិនធ្វើឱ្យពេញលេញក្នុងសិក្ខាផង ។ ... ភិក្ខុនោះ ឈ្មោះថាបង្កើតវិវាទក្នុងសង្ឃ ។ វិវាទតែងប្រព្រឹត្តទៅដើម្បីមិនជាគុណដល់ជនច្រើន មិនជាសុខដល់ជនច្រើន មិនជាប្រយោជន៍ មិនជាសេចក្តីចម្រើនដល់ជនច្រើន ជាទុក្ខដល់ទេវតា និងមនុស្ស ទាំងឡាយ ។

ជាបន្តទៅព្រះអង្គទ្រង់ឱ្យលះបង់នូវវិវាទមូលទាំង ៦ ប្រការនោះ ។

ក្នុងវិន័យបិដកលេខ ១០ ទំព័រ ៦១ នៅក្នុង **សមថក្ខន្ធកៈ** អំពីមូលនៃវិវាទាធិករណ៍ ព្រះអង្គទ្រង់ត្រាស់សម្តែងមូលនៃវិវាទ ៦ ប្រការដូចគ្នាដែរ ។

មូលនៃវិវាទ ៦ ប្រការ មានក្នុងបិដកលេខ ១៩ ទំព័រ ១៩៨



នៅក្នុង **សង្គីតិសូត្រ** ពួក ៦ និងនៅក្នុងបិដកលេខ ៤៦ ទំព័រ ១១១ **ទិវាទមូលសូត្រ** ។

ក្នុងវិន័យបិដកលេខ ១៣ ទំព័រ ២០៤ **មហាសង្គាម** មានសម្តែងអំពីភិក្ខុជាវិន័យធរពួកខ្លះក្នុងសាសនានេះ លំអៀងដោយអគតិ ៤ យ៉ាងហើយពោលក្នុងវត្ថុ ១៨ ប្រការ គឺសម្តែងសភាវៈមិនមែនធម៌ ថាជាធម៌ សម្តែងនូវធម៌ថាមិនមែនជាធម៌ សម្តែងនូវសភាវៈមិនមែនវិន័យ ថាជាវិន័យ សម្តែងនូវវិន័យថាមិនមែនជាវិន័យជាដើម ។

ការសម្តែងវត្ថុ ១៨ ប្រការដោយអគតិឈ្មោះថា ប្រតិបត្តិដើម្បីមិនជាប្រយោជន៍ដល់ជនច្រើនគ្នា ដើម្បីមិនជាសុខដល់ជនច្រើនគ្នា ដើម្បីមិនមែនជាសេចក្តីចម្រើនដល់ជនច្រើនគ្នា ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ ។

ភិក្ខុជាវិន័យធរ កាលបើលុះក្នុងអគតិ មានឆន្ទាគតិជាដើមដោយវត្ថុទាំង ១៨ ប្រការ ឈ្មោះថារក្សាខ្លួន ដែលមានកុសលធម៌ជីកគាស់រំលើងចោលចេញផង ឈ្មោះថាជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង ឈ្មោះថារងនូវអកុសលកម្មដ៏ច្រើនផង ។

ក្នុងបិដកលេខ ៤៤ ទំព័រ ២៣៨ នៅក្នុង **ថេរសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីអ្នកដឹកនាំមានមិច្ឆាទិដ្ឋិ គឺយល់ខុសអំពីសេចក្តីពិតជាដើមដូចតទៅ ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាង ឈ្មោះថាជាអ្នកប្រតិបត្តិ មិនបានជាគុណដល់ជនច្រើន មិនបានសុខដល់ជនច្រើន មិនជាប្រយោជន៍ដល់ជនច្រើន មិនជាគុណជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាថេរៈ ដឹងរាត្រី បួសយូរ ១ មានឈ្មោះល្បីល្បាញ មានយស មានបរិវារច្រើន ទាំងគ្រហស្ថ ទាំងបព្វជិត ១ សម្បូណ៌ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ១ ជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយ ។ល។ ចាក់ធ្លុះល្អដោយប្រាជ្ញា ១ តែជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់ដ៏វិបរិត ១ ភិក្ខុនោះញុំាងជនច្រើន ឱ្យឃ្លាតចាកព្រះសទ្ធម្ម ឱ្យតម្កល់នៅក្នុងអសទ្ធម្ម ភិក្ខុដទៃដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ដឹងរាត្រី បួសយូរខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ គេដឹងស្គាល់ច្រើន ជាអ្នកមានយស មានបរិវារច្រើន ទាំងគ្រហស្ថ ទាំងបព្វជិតខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ សម្បូណ៌ដោយចីវរ





បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថាប្រតិបត្តិ ដើម្បីមិនបានជាគុណដល់ជនច្រើន មិនបានសុខដល់ជនច្រើន មិនជាប្រយោជន៍ដល់ជនច្រើន មិនជាគុណទេ ជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ដែលប្រកបដោយធម៌ ៥ យ៉ាង ជាអ្នកប្រតិបត្តិ ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីគុណនិងសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ៥ យ៉ាង តើអ្វីខ្លះ ។ គឺភិក្ខុជាថេរៈ ដឹងរាត្រី បួសយូរ ១ មានឈ្មោះល្បីល្បាញ មានយស មានជនជាបរិវារច្រើន ទាំងគ្រហស្ថទាំងបព្វជិត ១ ជាអ្នកសម្បូណ៌ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារ ១ ជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយ ។ល។ ចាក់ធ្លុះដោយប្រាជ្ញា ១ ជាសម្មាទិដ្ឋិ មានសេចក្តីយល់មិនវិបរិត ១ ភិក្ខុនោះញុំាងជនច្រើន ឱ្យឃ្លាតចាកអសទ្ធម្ម ឱ្យតម្កល់នៅក្នុងព្រះសទ្ធម្ម ពួកភិក្ខុដទៃដល់នូវទិដ្ឋានុគតិ

របស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ដឹងរាត្រី បួសយូរខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ គេដឹងស្គាល់ច្រើន មានយស មានជនជាបរិវារច្រើន ទាំងគ្រហស្ថ ទាំងបព្វជិតខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ សម្បូណ៌ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារខ្លះ ដល់នូវទិដ្ឋានុគតិរបស់ភិក្ខុនោះថា ភិក្ខុនេះជាថេរៈ ជាអ្នកដឹងឮច្រើន ចាំរបស់ដែលឮហើយ ចាំលែងភ្លេចនូវរបស់ដែលឮហើយខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាថេរៈ ប្រកបដោយធម៌ ៥ យ៉ាងនេះឯង ឈ្មោះថាប្រតិបត្តិ ដើម្បីគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីគុណ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។





# គុណសម្បត្តិរបស់កល្យាណមិត្ត

មនុស្សល្អ ពោលដោយលក្ខណៈផ្ទាល់ខ្លួន មានគុណសម្បត្តិផ្សេងៗ ដែលគួរជ្រាបដូចតទៅ :

**សប្បុរស** គឺមនុស្សល្អ មានធម៌របស់សប្បុរស ៧ ប្រការ :

១-**ធម្មញ្ញុតា** ដឹងគោលធម៌ដែលជាហេតុ

២-**អត្ថញ្ញុតា** ដឹងទិសដៅដែលជាផល

៣-**អត្តញ្ញុតា** ស្គាល់ខ្លួនឯងតាមសេចក្តីពិត

៤-**មត្តញ្ញុតា** ស្គាល់ប្រមាណក្នុងកិច្ចការសព្វគ្រប់

៥-**កាលញ្ញុតា** ស្គាល់កាលដែលត្រូវធ្វើអ្វីៗ

៦-**បរិសញ្ញុតា** ស្គាល់ប្រជុំជនមានសភាពយ៉ាងណាខ្លះ

៧-**បុគ្គលញ្ញុតា** ស្គាល់បុគ្គលដោយសភាពផ្សេងៗ ។

សប្បុរិសធម៌ ៧ ប្រការនេះមានក្នុង **សង្គីតិសូត្រ ឧសុត្តរៈ-សូត្រ** ពួក ៧ បិដកលេខ ១៩ និងមានសេចក្តីអធិប្បាយនៅក្នុង **ធម្មញ្ញូសូត្រ** មហាវគ្គ បិដកលេខ ៤៧ ។

ក្នុងបិដកលេខ ២៦ ទំព័រ ២០៩ នៅក្នុង **ចូឡបុណ្ណមសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែង នូវសប្បុរិសធម៌ ៨ ចំណុចដោយឡែក ផ្សេងទៀតមានដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ សប្បុរសរមែងប្រកបដោយព្រះសទ្ធម្ម ជាអ្នកមានការសេពគប់ជាសប្បុរស មានគំនិតជាសប្បុរស មានសេចក្តីប្រឹក្សាជាសប្បុរស មានវាចាជាសប្បុរស មានការងារជាសប្បុរស មានទិដ្ឋិជាសប្បុរស តែងឱ្យនូវទានជាសប្បុរស ។

ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស ប្រកបដោយព្រះសទ្ធម្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ ជាអ្នកមានសទ្ធា មានសេចក្តីខ្មាសបាប មានសេចក្តីខ្លាចបាប ជាអ្នកចេះដឹងច្រើន មានព្យាយាមមាំមួន មានស្មារតីតម្កល់ខ្ជាប់ខ្ជួន និងមានបញ្ញា ម្នាលភិក្ខុទាំងឡាយ សប្បុរស រមែងប្រកបដោយព្រះសទ្ធម្ម ៧ ប្រការយ៉ាងនេះ ឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានការសេពគប់ជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ពួកសមណព្រាហ្មណ៍ ដែលមានសទ្ធា មានសេចក្តីខ្មាសបាប មានសេចក្តីខ្លាចបាប ជាអ្នកចេះដឹងច្រើន មានព្យាយាមមាំមួន មានស្មារតីតម្កល់ខ្ជាប់ខ្ជួន និងមានបញ្ញា ពួកសមណព្រាហ្មណ៍នោះ





រមែងបានជាមិត្ត ជាសម្លាញ់ នៃសប្បុរសនោះ ម្នាលភិក្ខុទាំង-ឡាយ សប្បុរស មានការសេពគប់ជាសប្បុរស យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានគំនិតជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ មិនគិតដើម្បីបៀតបៀនខ្លួនឯង មិនគិតដើម្បីបៀតបៀនអ្នកដទៃ មិនគិតដើម្បីបៀតបៀនទាំងពីរខាង ម្នាលភិក្ខុទាំងឡាយ សប្បុរស មានគំនិតជាសប្បុរស យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានសេចក្តីប្រឹក្សាជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ មិនប្រឹក្សាដើម្បីបៀតបៀនខ្លួនឯង មិនប្រឹក្សាដើម្បីបៀតបៀនអ្នកដទៃ មិនប្រឹក្សាដើម្បីបៀតបៀនទាំងពីរខាង ម្នាលភិក្ខុទាំងឡាយ សប្បុរស មានសេចក្តីប្រឹក្សាជាសប្បុរស យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានវាចាជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ វៀរចាកពាក្យកុហក វៀរចាកពាក្យញុះញង់ វៀរចាកពាក្យទ្រគោះ វៀរចាកពាក្យរោយរាយឥតប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ សប្បុរស មានវាចាជាសប្បុរស យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានការងារជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ វៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ សប្បុរស មានការងារជាសប្បុរស យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានទិដ្ឋិជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ មានសេចក្តីយល់ឃើញ យ៉ាងនេះថា ទានដែលបុគ្គលឱ្យហើយ មានផល , ការបូជាធំមានផល , ការបូជាតូចមានផល , ផលវិបាកនៃកម្មដែលល្អនិងអាក្រក់មាន , លោកនេះមាន , លោកខាងមុខមាន , ការប្រតិបត្តិល្អអាក្រក់ក្នុងមាតាមានផល , ការប្រតិបត្តិល្អអាក្រក់ក្នុងបិតាមានផល , សត្វជាឱបបាតិកៈមាន , ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលប្រព្រឹត្តល្អ ប្រតិបត្តិល្អ ធ្វើឱ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម នៃខ្លួនឯង នូវលោកនេះផង លោកខាងមុខផង ហើយអាចនឹងប្រកាសបាន រមែងមាន។ ម្នាលភិក្ខុទាំងឡាយ សប្បុរស មានទិដ្ឋិជាសប្បុរស យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តែងឱ្យទានជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ





ឱ្យទានដោយគោរព ធ្វើនូវសេចក្តីកោតក្រែងហើយឱ្យទាន ឱ្យទានដ៏បរិសុទ្ធ មានសេចក្តីយល់ឃើញនូវផលហើយឱ្យទាន ម្នាលភិក្ខុទាំងឡាយ សប្បុរស តែងឱ្យទានជាសប្បុរស យ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ សប្បុរសនោះឯង ប្រកបដោយព្រះសទ្ធម្មយ៉ាងនេះ មានការសេពគប់ជាសប្បុរសយ៉ាងនេះ មានគំនិតជាសប្បុរសយ៉ាងនេះ មានសេចក្តីប្រឹក្សាជាសប្បុរសយ៉ាងនេះ មានវាចាជាសប្បុរសយ៉ាងនេះ មានការងារជាសប្បុរសយ៉ាងនេះ មានទិដ្ឋិជាសប្បុរសយ៉ាងនេះ ឱ្យទានជាសប្បុរសយ៉ាងនេះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ តែងទៅកើតក្នុងគតិរបស់សប្បុរស ម្នាលភិក្ខុទាំងឡាយ ចុះគតិរបស់សប្បុរស តើដូចម្តេច គតិរបស់សប្បុរសនោះ គឺសភាពជាទេវតាដ៏ស្តុកស្តម្ភ ឬ សភាពជាមនុស្សដ៏ស្តុកស្តម្ភ ។

ក្នុងបិដកលេខ ៥១ ទំព័រ ១៥៥ អង្គុត្តរនិកាយ ទសកនិបាត **សេដ្ឋវគ្គ** ព្រះអង្គទ្រង់ត្រាស់សម្តែងនូវ **កុសលកម្មបថ** ១០ ថាជាសប្បុរិសធម៌ ។

ក្នុងបិដកលេខ ៥១ ទំព័រ ៧៧ ព្រះអង្គទ្រង់ត្រាស់សម្តែង **អសេក្ខធម៌** ឬ **សម្មត្តធម៌** ១០ គឺសម្មាទិដ្ឋិ ។ល។ សម្មាសមាធិ សម្មាញាណ សម្មាវិមុត្តិ ថាជាសប្បុរិសធម៌ ។

ក្នុងបិដកលេខ ៣៧ ទំព័រ ៤៣ ព្រះអង្គទ្រង់ត្រាស់ថា :

ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរសតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកឃើញត្រូវ ។ល។ តម្កល់ចិត្តមាំត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សប្បុរស ។

ព្រះអង្គត្រាស់ហៅអ្នកដែលប្រកបដោយ **មគ្គអង្គ** ៨ នោះឯង ថាជាសប្បុរស ។

*បណ្ឌិត គឺមនុស្សឆ្លាតឬមនុស្សដែលមានដំណើរជីវិតដោយបញ្ញា ។ មានគុណសម្បត្តិដែលព្រះដ៏មានព្រះភាគទ្រង់បានសម្តែងទុកមក ច្រើនបែបច្រើនយ៉ាង មានដូចតទៅ :

ក្នុងបិដកលេខ ៤១ ទំព័រ ៣ **លក្ខណសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពី ពាលនិងបណ្ឌិតរមែងប្រាកដដោយកម្ម ដែលខ្លួនប្រព្រឹត្តមកហើយនោះឯង ព្រះអង្គទ្រង់ត្រាស់ថា :

ម្នាលភិក្ខុទាំងឡាយ ជនពាលមានកម្មជាលក្ខណៈ បណ្ឌិតក៏មានកម្មជាលក្ខណៈ ប្រាជ្ញាតែងមានសេចក្តីរុងរឿងក្នុងការប្រព្រឹត្តមិនដាច់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងគួរសំគាល់បានថាជាជនពាល ។ ធម៌ ៣ តើដូចម្តេច ។ គឺកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯងដែលគួរសំគាល់បាន





ថាជាជនពាល ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ គួរសំគាល់បានថាជាបណ្ឌិត ។ ធម៌ ៣ តើដូចម្តេច ។ គឺកាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ៣ នេះឯង ដែលគួរសំគាល់បានថាជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា បុគ្គលប្រកបដោយធម៌ ៣ ណាដែលគួរសំគាល់បានថាជាជនពាល បុគ្គលវៀរធម៌ទាំង ៣ នោះហើយប្រកបដោយធម៌ ៣ ណាដែលគួរសំគាល់បានថាជាបណ្ឌិត យើងទាំងឡាយនឹងសមាទានប្រព្រឹត្តធម៌ទាំង ៣ នោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះឯង ។

ក្នុងបិដកលេខ ៤១ ទំព័រ ៦ នៅក្នុង **អច្ចយសូត្រ** :

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ គប្បីដឹងបានថាជាបណ្ឌិត ។ ធម៌ ៣ តើដូចម្តេច ។ គឺបុគ្គលឃើញទោសរបស់ខ្លួនតាមទោស ១ លុះឃើញទោសតាមទោសហើយ ក៏សម្តែងទោសឱ្យសមគួរតាមធម៌ ១ កាលបុគ្គលដទៃសម្តែងទោសប្រាប់ហើយ ក៏ទទួលដោយសមគួរតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯង ដែលគប្បីដឹងបានថាជាបណ្ឌិត ។

ក្នុងបិដកលេខ ៤១ ទំព័រ ៧ នៅក្នុង **អយោនិសោសូត្រ** :

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ គួរស្គាល់បានថាជាបណ្ឌិត ។ ធម៌ ៣ តើដូចម្ដេច ។ គឺ ជាអ្នកគាក់តែងប្រស្នាដោយត្រូវទំនង ១ ជាអ្នកដោះស្រាយប្រស្នាដោយត្រូវទំនង ១ បើអ្នកដទៃដោះប្រស្នាដោយត្រូវទំនងហើយ ក៏សរសើរដោយបទ និងព្យញ្ជនៈជាបរិមណ្ឌលស្រួលបរិបូណ៌ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯង ដែលគួរស្គាល់បានថាជាបណ្ឌិត ។

ក្នុងបិដកលេខ ៤០ ទំព័រ ១៨៨ នៅក្នុង **ពាលវគ្គទី ៥** :

ម្នាលភិក្ខុទាំងឡាយជនពាលទាំងឡាយនេះមានពីរពួក ។ ជនពាលពីរពួក តើដូចម្ដេច។ គឺជនពាលតែងទទួលភារៈដែលមិនទាន់មកដល់[១] ១ ជនពាលតែងមិនទទួលភារៈដែលមកដល់ហើយ[២] ១។ ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយមានពីរពួកនេះឯង ។

១-បានដល់ភារៈទាំង ១០ គឺបោសរោងឧបោសថ ១ អុជប្រទីប ១ តម្កល់ទឹកឆាន់-ទឹកប្រើប្រាស់ ១ ក្រាលអាសនៈ ១ នាំឆន្ទៈ ១ នាំបារិសុទ្ធិ ១ ប្រាប់រដូវ ១ រាប់ចំនួនភិក្ខុ ១ ឱ្យឱវាទនាងភិក្ខុនី ១ សម្ដែងបាតិមោក្ខ ១ ជាភារៈរបស់ព្រះថេរៈ៦-មិនទាន់បានអារាធនាស្រាប់តែភិក្ខុថ្មីទៅធ្វើ ហៅថា នាំភារៈដែលមិនទាន់មកដល់ ។

២-បានដល់ភារៈទាំង ១០ របស់ព្រះថេរៈ ៦ មិនធ្វើខ្លួនឯង ឬមិនបង្គាប់អ្នកដទៃឱ្យធ្វើ ហៅថាមិននាំភារៈដែលមកដល់ហើយ ។





ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយនេះមានពីរពួក ។ បណ្ឌិតពីរពួក តើដូចម្ដេច ។ គឺបណ្ឌិតតែងទទួលភារៈដែលមកដល់ហើយ[១] ១ បណ្ឌិតមិនទទួលភារៈដែលមិនទាន់មកដល់[២] ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយមានពីរពួកនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ជនពាលនេះមានពីរពួក ។ ជនពាលពីរពួកតើដូចម្ដេច ។ គឺជនពាលមានសេចក្ដីសំគាល់ថាគួរក្នុងរបស់ដែលមិនគួរ[៣] ១ ជនពាលមានសេចក្ដីសំគាល់ថាមិនគួរក្នុងរបស់ដែលគួរ[៤] ១ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយមានពីរពួកនេះឯង ។

ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយនេះមានពីរពួក ។ បណ្ឌិតពីរពួកតើដូចម្ដេច ។ គឺបណ្ឌិតមានសេចក្ដីសំគាល់ថាមិនគួរក្នុងរបស់ដែលមិនគួរ ១ បណ្ឌិតមានសេចក្ដីសំគាល់ថាគួរក្នុងរបស់ដែលគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយមានពីរពួកនេះឯង ។

១-២-គ្រាន់តែផ្ទុយគ្នានឹងភិក្ខុពាលវិញប៉ុណ្ណោះ (ឧបោសថក្ខន្ធកៈ ) ។

៣-សំគាល់ក្នុងសាច់ទាំង ១០ យ៉ាងមានសាច់សីហៈជាដើម ដែលមិនគួរឆាន់ ថាសាច់គួរឆាន់វិញ ។

៤-សំគាល់ក្រៅពីសាច់ទាំង ១០ យ៉ាង មានសាច់ក្រពើ សាច់ឆ្មាជាដើមដែលគួរឆាន់បាន ថាមិនគួរឆាន់វិញ ។ (មើលសមុដ្ឋានវារៈ បរិវារៈ ពិស្ដារជាង ) ។

ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយនេះមានពីរពួក ។ ជនពាលពីរពួកតើដូចម្តេច ។ គឺជនពាលមានសេចក្តីសំគាល់ថាមានអាបត្តិក្នុងអនាបត្តិ ១ ជនពាលមានសេចក្តីសំគាល់ថាឥតមានអាបត្តិក្នុងអាបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយមានពីរពួកនេះឯង ។

ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយនេះមានពីរពួក ។ បណ្ឌិតពីរពួក តើដូចម្តេច ។ គឺបណ្ឌិតមានសេចក្តីសំគាល់ថាឥតមានអាបត្តិក្នុងអនាបត្តិ ១ បណ្ឌិតតែងសំគាល់ថា មានអាបត្តិក្នុងអាបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយមានពីរពួកនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយនេះមានពីរពួក ។ ជនពាលពីរពួកតើដូចម្តេច ។ គឺជនពាលមានសេចក្តីសំគាល់ថាធម៌ក្នុងអធម៌ ១ ជនពាលមានសេចក្តីសំគាល់ថាអធម៌ក្នុងធម៌ ១។ ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយមានពីរពួកនេះឯង ។

ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយនេះមានពីរពួក ។ បណ្ឌិតពីរពួក តើដូចម្តេច ។ គឺបណ្ឌិតមានសេចក្តីសំគាល់ថាអធម៌ក្នុងអធម៌ ១ បណ្ឌិតមានសេចក្តីសំគាល់ថាធម៌ក្នុងធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយមានពីរពួកនេះឯង ។





ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយនេះមានពីរពួក ។ ជនពាលពីរពួកតើដូចម្តេច ។ គឺជនពាលមានសេចក្តីសំគាល់ថាវិន័យក្នុងអវិន័យ ១ ជនពាលមានសេចក្តីសំគាល់ថា អវិន័យក្នុងវិន័យ ១ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលទាំងឡាយមានពីរពួកនេះឯង ។

ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយនេះមានពីរពួក ។ បណ្ឌិតពីរពួក តើដូចម្តេច ។ គឺបណ្ឌិតមានសេចក្តីសំគាល់ថាអវិន័យក្នុងអវិន័យ ១ បណ្ឌិតមានសេចក្តីសំគាល់ថាវិន័យក្នុងវិន័យ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតទាំងឡាយមានពីរពួកនេះឯង ។

ក្នុងបិដកលេខ ៤០ ទំព័រ ១៣១ :

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនេះមាន ២ ពួក ។ បុគ្គលពាលមាន ២ ពួក តើដូចម្តេច ។ គឺបុគ្គលមិនឃើញទោសតាមទោស ១ បុគ្គលកាលបើគេប្រាប់ទោស ក៏មិនព្រមទទួលទោសតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមាន ២ ពួកនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតនេះមាន ២ ពួក ។ បុគ្គលជាបណ្ឌិតមាន ២ ពួក តើដូចម្តេច ។ គឺបុគ្គលឃើញទោសតាមទោស ១ បុគ្គលកាលបើគេប្រាប់ទោស ក៏ព្រមទទួលទោសតាម

ធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតមាន ២ ពួកនេះឯង ។

នៅក្នុង **គាថាធម្មបទ** បិដកលេខ ៥២ ពាលវគ្គ ទំព័រ ៣៦ ព្រះអង្គទ្រង់សម្តែងប្រារព្ធចំពោះ **ព្រះសុធម្មត្ថេរ** :

**អសន្តំ ភាវមិច្ឆេយ្យ បុរេក្ខារញ្ច ភិក្ខុសុ**
**អាវាសេសុ ច ឥស្សរិយំ បូជា បរកុលេសុ ច ។**
**មមេវ កតមញ្ញន្តុ គិហិប្បព្វជិតា ឧភោ**
**មមេវ អតិវសា អស្សុ កិច្ចាកិច្ចេសុ កិស្មិញ្ចិ**
**ឥតិ ពាលស្ស សង្កប្បោ ឥស្សា មានោ ច វឌ្ឍតិ។**

ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរដែលមិនមានផង ចង់បានជាប្រមុខដឹកនាំក្នុងពួកភិក្ខុផង ចង់បាននូវភាពជាឥស្សរៈក្នុងអាវាសទាំងមូលផង និងចង់បានការបូជាទាំងឡាយក្នុងត្រកូលទាំងពួងដទៃទៀតផង ។

ភិក្ខុពាលតែងមានសេចក្តីត្រិះរិះថា គ្រហស្ថនិងបព្វជិតទាំងពីរពួក ចូរសំគាល់នូវកិច្ចដែលមនុស្សដទៃធ្វើហើយ ថាជាកិច្ចរបស់អាត្មាអញវិញ អំណាចដ៏ក្រៃលែងរបស់អាត្មាអញ ចូរមានក្នុងកិច្ចតូចក្តីធំក្តីឯណានីមួយ (កាលបើយ៉ាងនេះ ) ឥស្សា គឺការច្រណែន និងមានះ គឺការប្រកាន់ខ្លួន រមែងចម្រើន (ដល់ភិក្ខុពាលនោះ ) ។





## អដ្ឋកថាព្រះគាថាធម្មបទ

បណ្តាបទទាំងនោះ បទថា **អសន្តំ** មានសេចក្តីថាភិក្ខុពាលរមែងប្រាថ្នានូវការសរសើរដែលមិនមាន គឺភិក្ខុពាល មិនមានសទ្ធា ជាអ្នកទ្រុស្តសីល ស្តាប់ធម៌បានតិច មិនស្ងប់ស្ងាត់ ខ្ជិលច្រអូស មិនមានសតិតាំងមាំ មានចិត្តរវើរវាយ បញ្ញាទន់ខ្សោយ និងមិនមែនជាព្រះខីណាស្រព ប៉ុន្តែប្រាថ្នាការលើកតម្កើងដែលមិនមានយ៉ាងនេះថា «ធ្វើដូចម្តេចហ្ន៎ ពួកជនគប្បីស្គាល់យើងថា ភិក្ខុនេះមានសទ្ធា មានសីល ជាអ្នកចេះដឹងច្រើន ជាអ្នកស្ងប់ស្ងាត់ ប្រារព្ធនូវសេចក្តីព្យាយាម មានសតិតាំងមាំ មានចិត្តមិនរវើរវាយ មានបញ្ញា និងជាព្រះខីណាស្រព » ដោយន័យដែលលោកបានសម្តែងទុកនៅក្នុង **បាបិច្ឆតានិទ្ទេស** (អភិធម្ម វិភង្គ ) ថា «ភិក្ខុជាអ្នកមិនមានសទ្ធាឡើយ ប៉ុន្តែរមែងប្រាថ្នាថា ពួកជនចូរស្គាល់យើងថា ជាអ្នកមានសទ្ធា » ជាដើម (នេះជាការប្រាថ្នាបាបដ៏អាក្រក់លាមក ) ។

បទថា **បុរេក្ខារំ** អធិប្បាយថា ភិក្ខុពាលតាំងនៅក្នុងការប្រព្រឹត្តដោយអំណាចចំណង់យ៉ាងនេះថា «ធ្វើដូចម្តេចហ្ន៎ ទើប

ភិក្ខុក្នុងវិហារទាំងអស់ គប្បីមកចោមរោមយើងដើម្បីសួរនូវបញ្ហា (ជាដើម ) » នេះឈ្មោះថា ជាអ្នកប្រាថ្នានូវបរិវារក្នុងភិក្ខុទាំង-ឡាយ ។

បទថា **អាវាសេសុ** បានដល់ ក្នុងអាវាសដែលជារបស់សង្ឃ ។ អធិប្បាយថា ភិក្ខុពាល ចាត់សេនាសនៈប្រណីតក្នុងកណ្តាលវិហារដើម្បីភិក្ខុទាំងឡាយ មានភិក្ខុដែលជាមិត្តសម្លាញ់ជាដើមរបស់ខ្លួនដោយប្រាប់ថា« ពួកលោក ចូរនៅក្នុងសេនាសនៈនេះ »ចំណែកខ្លួនឯងជ្រើសរើសយកទីសេនាសនៈដែលល្អ ហើយចាត់ទីសេនាសនៈដែលអន់ៗ និងទីសេនាសនៈដែលអមនុស្សហួង-ហែង តាំងនៅជាយៗ ដើម្បីអាគន្តុកភិក្ខុទាំងឡាយផ្សេងទៀត ដោយប្រាប់ថា «ពួកលោក ចូរនៅក្នុងទីសេនាសនៈនេះ » នេះឈ្មោះថា ជាអ្នកប្រាថ្នាភាពជាធំក្នុងអាវាស ។

បាទព្រះគាថាថា **បូជា បរកុលេសុ ច** ដោយសេចក្តីថា ភិក្ខុពាលរមែងមិនប្រាថ្នាការបូជាដោយបច្ច័យ ៤ ក្នុងត្រកូលរបស់មាតា និងបិតាឡើយ ហើយត្រកូលពួកញាតិក៏មិនប្រាថ្នាដែរ គឺរមែងជាអ្នកប្រាថ្នាក្នុងត្រកូលនៃជនដទៃទាំងឡាយប៉ុណ្ណោះ ដោយគិតដូច្នេះថា «ធ្វើដូចម្តេចហ្ន៎ ពួកជនទាំងនេះ គប្បីប្រគេនដល់យើងតែម្នាក់ មិនគប្បីប្រគេនដល់ភិក្ខុទាំងនោះ » ។



បាទព្រះគាថាថា **មមេវ កតមញ្ញន្តុ** ដោយសេចក្តីថា សេចក្តីត្រិះរិះរមែងកើតឡើងដល់ភិក្ខុពាលថា « ពួកគ្រហស្ថ និងបព្វជិត ចូរសំគាល់កិច្ចដែលខ្លួនធ្វើហើយ គឺសម្រេចហើយព្រោះអាស្រ័យយើងប៉ុណ្ណោះ » ដោយមានបំណង យ៉ាងនេះថា « នវកម្មយ៉ាងណាមួយដែលគេធ្វើហើយក្នុងវិហារ ដោយអំណាចនៃការធ្វើនវកម្មមានរោងឧបោសថជាដើម នវកម្មនោះទាំងអស់ដែលព្រះថេរៈរបស់ពួកយើងធ្វើហើយ » (ចង់ឱ្យគេគិតថា អំពើអ្វីៗ ដែលអ្នកដទៃធ្វើក្នុងវត្ត សុទ្ធតែសម្រេចពីខ្លួនឯងជាព្រះថេរៈឬជាចៅអាវាសទាំងអស់ ) ។

បាទព្រះគាថាថា **មមេវ អតិវសា អស្សុ** ដោយសេចក្តីថា សេចក្តីត្រិះរិះរមែងកើតឡើងដល់ភិក្ខុពាលនោះថា « គ្រហស្ថនិងបព្វជិតទាំងអស់ ចូរប្រព្រឹត្តទៅក្នុងអំណាចរបស់យើងតែម្នាក់ គឺពាហនៈ និងគ្រឿងឧបករណ៍ទាំងឡាយ មានគោរទេះ កាំបិតពូថៅជាដើម រហូតដល់ទីបំផុត សូម្បីគ្រាន់តែការកម្តៅបបរហើយបរិភោគ ដែលគ្រហស្ថ និងបព្វជិតគប្បីធ្វើ គប្បីបានយ៉ាងណាក៏ដោយ ត្រូវឱ្យករណីយកិច្ចទាំងតូចទាំងធំនោះ នៅក្នុងអំណាចរបស់យើងតែប៉ុណ្ណោះ អធិប្បាយថា ចូរសួរយើងតែម្នាក់ប៉ុណ្ណោះហើយសឹមធ្វើ » ។

ពីរបទថា **ឥតិ ពាលស្ស** ដោយសេចក្តីថា ចំណង់នោះ និងការត្រិះរិះរបៀបបែបដូច្នេះ រមែងកើតឡើងដល់ភិក្ខុពាលណា វិបស្សនា មគ្គនិងផល រមែងមិនចម្រើនដោយពិតដល់ភិក្ខុពាលនោះ គឺមានតែតណ្ហាដែលកើតឡើងក្នុងទ្វារ ៦ និងមានះ ៩ យ៉ាងប៉ុណ្ណោះ ដែលរមែងចម្រើនដល់ភិក្ខុពាលនោះឯង ។

ព្រះ **គាថាធម្មបទ**បណ្ឌិតវគ្គ បិដកលេខ ៥២ ទំព័រ ៣៩:

**សព្វត្ថ វេ សប្បុរិសា វជន្តិ**

**ន កាមកាមា លបយន្តិ សន្តោ**

**សុខេន ផុដ្ឋា អថ វា ទុក្ខេន**

**ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ** ។

ពួកសប្បុរស តែងលះបង់នូវធម៌ទាំងពួង ពួកលោកអ្នកស្ងប់រមែងមិនពោលប្រស្រ័យ ព្រោះសេចក្តីប្រាថ្នាក្នុងកាមទេ ពួកបណ្ឌិត បើសេចក្តីសុខ ឬទុក្ខពាល់ត្រូវហើយ រមែងមិនសម្តែងអាការឡើងចុះឡើយ ។

**ន អត្តហេតុ ន បរស្ស ហេតុ**

**ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ**

**ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ**

**ស សីលវា បញ្ញវា ធម្មិកោ សិយា** ។



បណ្ឌិតមិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិនគួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នាបុត្រ មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរប្រាថ្នានូវសេចក្តីសម្រេចដើម្បីខ្លួនដោយហេតុមិនមែនជាធម៌ឡើយ បណ្ឌិតនោះគួរជាអ្នកមានសីលមានបញ្ញាប្រកបដោយធម៌ ។

ក្នុងបិដកលេខ ៣២ ទំព័រ ១៩៤ នៅក្នុង **លាភសក្ការសំយុត្ត** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីសប្បុរស ត្រេកអរចំពោះព្រះនិព្វានដែលជាទីក្ស័យនៃឧបាទាន មានគាថាព័ន្ធដូចតទៅ :

**យស្ស សក្ករិយមានស្ស អសក្ការេន ចូភយំ**

**សមាធិ ន វិកម្បតិ អប្បមាទវិហារិនោ** ។

**តំ ឈាយិនំ សាតតិកំ សុខុមទិដ្ឋិវិបស្សកំ**

**ឧបាទានក្ខយារាមំ អាហុ សប្បុរិសោ ឥតីតិ** ។

បុគ្គលណា ដែលគេធ្វើនូវសក្ការៈក៏ដោយ មិនធ្វើនូវសក្ការៈក៏ដោយ គេធ្វើនូវសក្ការៈ និងអសក្ការៈ ទាំងពីរក៏ដោយ រមែងមាននូវសមាធិមិនញាប់ញ័រ រស់នៅដោយសេចក្តីមិនប្រមាទ ជាអ្នកមានប្រក្រតី សម្លឹងពិនិត្យ មានព្យាយាមជាប់តគ្នាមិនដាច់ ជាអ្នកឃើញច្បាស់ដោយទិដ្ឋិដ៏សុខុម ត្រេកអរចំពោះព្រះនិព្វានដែលជាទីក្ស័យនៃឧបាទាន អ្នកប្រាជ្ញទាំងឡាយ ហៅនូវបុគ្គលនោះ

ថាជាសប្បុរស ។

**ព្រះគាថាធម្មបទ** បណ្ឌិតវគ្គ ប្រារព្ធ **បណ្ឌិតសាមណេរ**បាន សម្រេចអរហត្តផល :

**ឧទកញ្ហិ នយន្តិ នេត្តិកា   ឧសុការា នមយន្តិ តេជនំ**
**ទារុំ នមយន្តិ តច្ឆកា   អត្តានំ ទមយន្តិ បណ្ឌិតា ។**

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ ជាងធ្វើព្រួញ តែងពត់ព្រួញឱ្យត្រង់ ជាងឈើ តែងចាំងឈើ (ឱ្យទៅតាមសេចក្តីប្រាថ្នា ) ចំណែកឯបណ្ឌិតតែងអប់រំទូន្មានចិត្ត ។

ក្នុងបិដកលេខ ៣២ ទំព័រ ២៨៩ ព្រះអង្គទ្រង់ប្រារព្ធ **លកុណ្ឌកភទ្ទិយៈ** ជាបណ្ឌិតអ្នកប្រាជ្ញ សូម្បីរូបរាងកាយមិនស្អាតក៏ដោយ ព្រះអង្គទ្រង់ត្រាស់សម្តែងថា :

**ហំសា កុញ្ចា មយូរា ច   ហត្ថិយោ បសជមិគា**
**សព្វេ សីហស្ស ភាយន្តិ   នត្ថិ កាយស្មិ តុល្យតា ។**
**ឯវមេវ មនុស្សេសុ   ទហរោ ចេបិ បញ្ញវា**
**សោ ហិ តត្ថ មហា ហោតិ   នេវ ពាលោ សរីរវា ។**

ពួកហង្សក្តី ក្រៀលក្តី ក្ងោកក្តី ដំរីក្តី ម្រឹគក្តាន់ក្តី ពួកសត្វទាំងនោះ រមែងខ្លាចរាជសីហ៍ទាំងអស់ នឹងយករាងកាយទៅប្រៀបធៀបគ្នាមិនបានឡើយ មានឧបមាយ៉ាងណា មានឧបមេយ្យ





ដូចយ៉ាង ក្នុងពពួកមនុស្ស ទោះបីគេនោះនៅក្មេង ប៉ុន្តែបើគេមានប្រាជ្ញា គេរមែងបានជាធំ ក្នុងពពួកមនុស្សនោះ រីឯមនុស្សពាលមានតែសរីរៈ គឺមិនបានជាធំក្នុងពពួកមនុស្សឡើយ ។

**ព្រះគាថាធម្មបទ** ជរាវគ្គ ប្រារព្ធ **លោឡុទាយី** ដែលមានការចេះដឹងតិច ព្រះសម្មាសម្ពុទ្ធទ្រង់ប្រៀបដូចគោដែលគេឈប់ប្រើហើយលែងចោល ព្រះអង្គទ្រង់ត្រាស់សម្តែង ១ គាថា :

**អប្បស្សុតាយំ បុរិសោ   ពលិពទ្ទោវ ជីរតិ**
**មំសានិ តស្ស វឌ្ឍន្តិ   បញ្ញា តស្ស ន វឌ្ឍតិ ។**

បុរសអ្នកមិនមានការចេះដឹងនេះ រមែងចាស់ដូចគោបម្រើ សាច់របស់វាតែងចម្រើនឡើង តែប្រាជ្ញារបស់វាមិនចម្រើនឡើងឡើយ ។

**ព្រះគាថាធម្មបទ** ធម្មដ្ឋវគ្គ ប្រារព្ធ **ព្រះលកុណ្ឌកភទ្ទិយត្ថេរ** ដែលជាថេរៈ ព្រោះមាំមួនដោយការត្រាស់ដឹងនូវសច្ចៈ បាននូវលោកុត្តរធម៌ រស់នៅដោយព្រហ្មវិហារ មានសីល និងមានការសង្រួមឥន្ទ្រិយ ព្រះអង្គទ្រង់ត្រាស់សម្តែងថា :

**ន តេន ថេរោ ហោតិ   យេនស្ស បលិតំ សិរោ**
**បរិបក្កោ វយោ តស្ស   មោឃជិណ្ណោតិ វុច្ចតិ ។**
**យម្ហិ សច្ចញ្ច ធម្មោ ច   អហឹសា សញ្ញមោ ទមោ**

**ស វេ វន្តមលោ ធីរោ   សោ ថេរោតិ បវុច្ចតិ ។**

បុគ្គលមិនឈ្មោះថាថេរៈ ព្រោះមានសក់ស្កូវនៅលើក្បាលនោះទេ អ្នកដែលមានវ័យចាស់ហួសទៅហើយនោះ តថាគតហៅថា « ចាស់ទទេ » ។

លុះត្រាតែបុគ្គលណា មានសច្ចៈផង ធម្មៈផង ការមិនបៀតបៀនផង ការសង្រួមផង និងការអប់រំផង គឺជាអ្នកមានមន្ទិលខ្ជាក់ចោលហើយ ជាអ្នកប្រាជ្ញ ទើបតថាគតហៅបុគ្គលនោះថា « ថេរៈ» ។

ក្នុងបិដកលេខ ៥៤ ទំព័រ ២៤៥ នៅក្នុង **នាឡកសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងថា «ស្ទឹងតូចទាំងឡាយ ហូរទៅលាន់សូរ ឯស្ទឹងធំ តែងហូរទៅស្ងៀមៗ » ព្រះអង្គទ្រង់ត្រាស់បន្តថា :

**យទូនកំ តំ សនតិ   យំ បូរំ សន្តមេវ តំ**
**អឌ្ឍកុម្ភូបមោ ពាលោ   រហទោ បូរោវ បណ្ឌិតោ ។**

ទឹកណាដែលមិនពេញ ទឹកនោះតែងឮសូរ ទឹកណាដែលពេញ ទឹកនោះតែងស្ងប់ ជនពាលដូចទឹកកន្លះក្អម ឯជនជាបណ្ឌិតដូចអន្លង់ទឹកដ៏ពេញ ។

**ព្រះគាថាធម្មបទ** ពាលវគ្គ ប្រារព្ធ **គណ្ឋិភេទកចោរ** គឺចោរអ្នកទម្លាយបង្វិច ដោយសេចក្ដីផ្ដើមថា មានចោរពីរនាក់ជាសម្លាញ់





នឹងគ្នា បានចូលទៅកាន់វត្តជេតពន ។ ចោរម្នាក់ស្ដាប់ធម៌បានសម្រេចសោតាបត្តិផល ឯចោរម្នាក់ទៀតរង់ចាំតែឱកាសនឹងលួចទ្រព្យរបស់គេ ទីបំផុតក៏លួចបានមែន ហើយយកមកស៊ីចាយសប្បាយជាមួយនឹងប្រពន្ធរបស់ខ្លួន ។

ក្រោយមក ចោរបាននិយាយដៀមដាមចាក់ដោតនិងចំអកឡកឡាយ ឱ្យដល់សម្លាញ់របស់ខ្លួនដែលបានសម្រេចសោតាបត្តិ-ផលហើយនោះ ជាការនិយាយអួតខ្លួនឯងថាជាអ្នកឆ្លាត មានបញ្ញាជាបណ្ឌិត... រីឯសម្លាញ់ដែលបានសម្រេចនូវសោតាបត្តិផលនោះឯង បានចូលទៅក្រាបទូលដល់ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ថា :

**យោ ពាលោ មញ្ញតី ពាល្យំ បណ្ឌិតោ វាបិ តេន សោ**
**ពាលោ ច បណ្ឌិតមានី   ស វេ ពាលោតិ វុច្ចតិ ។**

បុគ្គលពាលណាដឹងខ្លួនឯងថា ជាអ្នកល្ងង់ខ្លៅ បុគ្គលពាលនោះ នឹងអាចក្លាយទៅជាបណ្ឌិតបាន ព្រោះហេតុតែការដឹងខ្លួននោះឯង ឯបុគ្គលពាលណា មានសេចក្ដីប្រកាន់ថា ខ្លួនជាបណ្ឌិតបុគ្គលពាលនោះ តថាគតហៅថា « ជាមនុស្សពាលដោយពិត » ។

ក្នុងបិដកលេខ ៣០ ទំព័រ ១៤៧ នៅក្នុង **ខោមទុស្សសូត្រ** ព្រះអង្គទ្រង់ត្រាស់ហៅបុគ្គលថាជាសប្បុរសព្រោះពោលនូវធម៌ :

**នេសា សភា យត្ថ ន សន្តិ សន្តោ**

**សន្តោ ន តេ យេ ន វទន្តិ ធម្មំ**

**រាគញ្ច ទោសញ្ច បហាយ មោហំ**

**ធម្មំ វទន្តា ច ភវន្តិ សន្តោតិ ។**

ពួកសប្បុរស មិនមានក្នុងទីណា ទីនោះមិនឈ្មោះថា សភាឡើយ ជនទាំងឡាយណា មិនពោលធម៌ ជនទាំងនោះមិនឈ្មោះថា សប្បុរសអ្នកស្ងប់រម្ងាប់ទេ លុះតែពួកជនបានលះបង់នូវរាគៈ ទោសៈ មោហៈ ទាំងពោលនូវធម៌ផង ទើបឈ្មោះថា សប្បុរស ។

ក្នុងបិដកលេខ ៦០ ទំព័រ ២៣៩ ពាក្យរបស់ **សរភង្គតាបស** ជាព្រះបរមពោធិសត្វ :

**យោ វេ កតញ្ញូ កតវេទិ ធីរោ**

**កល្យាណមិត្តោ ទឡ្ហភត្តិ ច ហោតិ**

**ទុក្ខិតស្ស សក្កច្ច ករោតិ កិច្ចំ**

**តថាវិធំ សប្បុរិសំ វទន្តិ ។**

បុគ្គលណា ជាកតញ្ញូកតវេទី មានប្រាជ្ញា មានមិត្តល្អ មានភក្តីមាំមួន ធ្វើនូវកិច្ចការដើម្បីអ្នកដែលដល់នូវសេចក្តីទុក្ខ ដោយគោរព បណ្ឌិតទាំងឡាយ ហៅនូវបុគ្គលបែបនោះថាជាសប្បុរស។

ក្នុងបិដកលេខ ៤២ ទំព័រ ២៩៧ **ឋានសូត្រ** ព្រះអង្គទ្រង់





ត្រាស់សម្តែងអំពីហេតុ ៤ យ៉ាង មិនជាទីគាប់ចិត្ត ២ យ៉ាង និងជាទីគាប់ចិត្ត ២ យ៉ាង រួចហើយព្រះអង្គទ្រង់ចែកក្នុង ២ យ៉ាងនោះ ១ មិនជាប្រយោជន៍ និង ១ ទៀតជាប្រយោជន៍ មានសេចក្តីទាំងស្រុងដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ ហេតុនេះមាន ៤ យ៉ាង ។ ហេតុ ៤ យ៉ាងដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុមិនជាទីគាប់ចិត្ត ហេតុដែលគួរធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនជាប្រយោជន៍ក៏មាន ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុមិនជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ក៏មាន ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ក៏មាន ម្នាលភិក្ខុទាំងឡាយ ការធ្វើនូវហេតុជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ក៏មាន ។

ម្នាលភិក្ខុទាំងឡាយ បណ្តាហេតុទាំង ៤ យ៉ាងនោះ ការធ្វើនូវហេតុណា មិនជាទីគាប់ចិត្ត ហេតុដែលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតរមែងសំគាល់នូវហេតុនោះ ថាជាហេតុដែលខ្លួនមិនត្រូវធ្វើទាំង ២

ប្រការ គឺ ការធ្វើនូវហេតុណា មិនជាទីគាប់ចិត្ត ក៏សំគាល់នូវហេតុនោះ ថាជាហេតុដែលខ្លួនមិនត្រូវធ្វើ ១ ហេតុណាដែលបុគ្គលធ្វើ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ក៏សំគាល់នូវហេតុនោះ ថាជាហេតុដែលខ្លួនមិនត្រូវធ្វើ ១ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតរមែងសំគាល់នូវហេតុនេះ ថាជាហេតុដែលខ្លួនមិនត្រូវធ្វើ ទាំង ២ ប្រការតែម្តង ។

ម្នាលភិក្ខុទាំងឡាយ បណ្តាហេតុទាំង ៤ យ៉ាងនោះ ការធ្វើនូវហេតុណា មិនជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ ជនជាពាលក្តី ជាបណ្ឌិតក្តី គប្បីដឹងច្បាស់ក្នុងហេតុនេះ គឺក្នុងកម្លាំងរបស់បុរស ក្នុងសេចក្តីព្យាយាមរបស់បុរស ក្នុងសេចក្តីប្រឹងប្រែងរបស់បុរស ម្នាលភិក្ខុទាំងឡាយ ជនពាលមិនពិចារណា ដូច្នេះថា ការធ្វើនូវហេតុមិនជាទីគាប់ចិត្តក៏ពិតមែនហើយ តែហេតុដែលធ្វើនេះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ជនពាលនោះ ទើបមិនធ្វើនូវហេតុនោះ ហេតុដែលជនពាលមិនធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកឯបណ្ឌិតរមែងពិចារណា ដូច្នេះថា ការធ្វើនូវហេតុមិនជាទីគាប់ចិត្តនេះក៏ពិតមែនហើយ តែថា ហេតុដែលធ្វើនេះ រមែងប្រព្រឹត្តទៅដើម្បី





ជាប្រយោជន៍ បណ្ឌិតនោះ ទើបធ្វើនូវហេតុនោះ ហេតុដែលបណ្ឌិតធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ។

ម្នាលភិក្ខុទាំងឡាយ បណ្តាហេតុ ៤ យ៉ាងនោះ ការធ្វើនូវហេតុណា ជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ ជនជាពាលក្តី ជាបណ្ឌិតក្តី គប្បីដឹងច្បាស់ក្នុងហេតុនេះ គឺក្នុងកម្លាំងរបស់បុរស ក្នុងសេចក្តីព្យាយាមរបស់បុរស ក្នុងសេចក្តីប្រឹងប្រែងរបស់បុរស ម្នាលភិក្ខុទាំងឡាយ ជនពាលមិនពិចារណា ដូច្នេះថា ការធ្វើនូវហេតុជាទីគាប់ចិត្តនេះ ក៏ពិតមែនហើយ តែហេតុដែលធ្វើនេះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ជនពាលនោះ ទើបធ្វើនូវហេតុនោះ ហេតុដែលជនពាលធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកឯបណ្ឌិតរមែងពិចារណា ដូច្នេះថា ការធ្វើនូវហេតុជាទីគាប់ចិត្តនេះក៏ពិតមែនហើយ តែថា ហេតុដែលធ្វើនេះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ទើបបណ្ឌិតនោះមិនធ្វើនូវហេតុនោះ ហេតុដែលបណ្ឌិតមិនធ្វើនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ។

ម្នាលភិក្ខុទាំងឡាយ បណ្តាហេតុទាំង ៤ យ៉ាងនោះ ការធ្វើនូវហេតុណា ជាទីគាប់ចិត្ត ហេតុដែលបុគ្គលធ្វើនោះ រមែង

ប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតរមែងសំគាល់ នូវហេតុនោះថាជាហេតុដែលខ្លួនត្រូវធ្វើទាំង ២ ប្រការ គឺការធ្វើនូវហេតុណា ជាទីគាប់ចិត្ត ក៏សំគាល់នូវហេតុនោះ ថាជាហេតុដែលខ្លួនត្រូវធ្វើ ១ ហេតុណាដែលខ្លួនធ្វើ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ក៏សំគាល់នូវហេតុនោះ ថាជាហេតុដែលខ្លួនត្រូវធ្វើ ១ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតសំគាល់នូវហេតុនេះ ថាជាហេតុដែលខ្លួនត្រូវធ្វើទាំង ២ ប្រការតែម្តង ។ ម្នាលភិក្ខុទាំងឡាយ ហេតុមាន ៤ យ៉ាងនេះឯង ។

## អដ្ឋកថាឋានសូត្រ

**ឋានៈគឺហេតុទី ១** បានដល់ បាបកម្មមានទុក្ខលំបាកយ៉ាកយ៉ាប់ ចង្អៀតចង្អល់ខ្វល់ក្នុងចិត្ត ដោយការគិតរកឧបាយដើម្បីសម្លាប់សត្វ ម្ល៉ោះហើយត្រូវធ្វើការនឿយហត់ ដូចជាត្រូវជីករណ្តៅដាក់ចម្រូងជាដើម ឬត្រូវធ្វើការលួចប្លន់ ទាំងមានការភ័យខ្លាចក្នុងចិត្ត ។ល។

**ឋានៈគឺហេតុទី ២** បានដល់ ការងារមានការជីកសំរាមចោល ឬក៏ធ្វើជាកម្មករផ្សេងៗ មានការសាងសង់ជាដើម រហូត





ដល់បោសសំរាមតាមថ្នល់ និងធ្វើអ្វីៗក្នុងទីមិនស្អាត ។ល។ នេះសម្រាប់គ្រហស្ថដែលចិញ្ចឹមជីវិតដោយប្រពៃ ។

**ឋានៈទី ៣** បានដល់ កម្មមានការបរិភោគសុរា ប្រដាប់រាងកាយដោយផ្កាកម្រង លាបគ្រឿងក្រអូប សប្បាយរីករាយក្នុងកាមគុណ និងការសម្លាប់សត្វបរិភោគប្រព្រឹត្តទៅដោយសេចក្តីត្រេកអរ សប្បាយនឹងស៊ី នឹងផឹកជាដើម ។

**ឋានៈទី ៤** បានដល់ កុសលកម្មដែលប្រកបដោយសោមនស្សក្នុងការដែលស្លៀកពាក់ស្អាតបាត កាន់ផ្កាកម្រងគ្រឿងក្រអូបជាដើមទៅក្នុងពេលស្តាប់ព្រះធម៌ ការក្រាបថ្វាយបង្គំព្រះចេតិយ ព្រះពោធិព្រឹក្ស ការស្តាប់ធម្មកថាដ៏ពីរោះ និងការសមាទានសីល ៥ ជាដើម ។

ក្នុងបិដកលេខ ៤៤ ទំព័រ ១៦៤ នៅក្នុង **បឋមវឌ្ឍិសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីសប្បុរស ដែលមាននូវសេចក្តីចម្រើន មានប្រាជ្ញា រមែងកាន់យកនូវសារៈក្នុងលោកនេះ ឱ្យដល់ខ្លួនឯងបាន ព្រះអង្គទ្រង់ត្រាស់សម្តែងថា :

**សទ្ធាយ សីលេន ច យោ បវឌ្ឍតិ**
**បញ្ញាយ ចាគេន សុតេន ចូភយំ**
**សោ តាទិសោ សប្បុរិសោ វិចក្ខណោ**

**អាទីយតិ សារមិច្ឆេទ អត្ថនោតិ ។**

បុគ្គលណា ចម្រើនដោយសទ្ធា ដោយសីល ដោយសុតៈ ដោយចាគៈ និង ដោយបញ្ញា បុគ្គលប្រាកដដូច្នោះ ឈ្មោះថាជាសប្បុរសមានប្រាជ្ញាជាគ្រឿងពិចារណា រមែងកាន់យកនូវប្រយោជន៍ទាំងពីរ (គឺប្រយោជន៍មានខ្លឹមសារ និងប្រយោជន៍ដ៏ឧត្តមខ្ពង់ខ្ពស់ក្រៃលែងឡើងទៀត ) អំពីលោកនេះឱ្យដល់ខ្លួនឯងបាន ។

ក្នុងបិដកលេខ ៤៣ ទំព័រ ២៤៧ **អានិសំសសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្ដែងអំពីអានិសង្ស ៤ ប្រការ កើតប្រាកដឡើងបាន ព្រោះអាស្រ័យសប្បុរស មានដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៤ ប្រការ កើតប្រាកដឡើងបាន ព្រោះអាស្រ័យសប្បុរស ។ អានិសង្ស ៤ ប្រការតើដូចម្ដេចខ្លះ ។ បុគ្គលអាស្រ័យសប្បុរស រមែងចម្រើនដោយសីលដ៏ប្រសើរ រមែងចម្រើនដោយសមាធិដ៏ប្រសើរ រមែងចម្រើនដោយបញ្ញាដ៏ប្រសើរ រមែងចម្រើនដោយវិមុត្តិដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៤ ប្រការនេះឯងកើតឡើងប្រាកដបាន ព្រោះអាស្រ័យសប្បុរស ។

ក្នុងបិដកលេខ ៤៣ ទំព័រ ៩៣ នៅក្នុង **ឧម្មគ្គសូត្រ** ព្រះអង្គ





ទ្រង់ត្រាស់ឆ្លើយតបបញ្ហា ដែលភិក្ខុមួយអង្គបានទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលជាបណ្ឌិតអ្នកមានប្រាជ្ញាច្រើន តើដោយហេតុដូចម្ដេច ?

ព្រះអង្គទ្រង់ត្រាស់ថា :

ម្នាលភិក្ខុ បុគ្គលជាបណ្ឌិតមានបញ្ញាច្រើននៅក្នុងសាសនានេះ រមែងមិនគិតដើម្បីបៀតបៀនខ្លួន រមែងមិនគិតដើម្បីបៀតបៀនអ្នកដទៃ រមែងមិនគិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃទាំងពីរខាង ។ កាលបើគិត រមែងគិតឱ្យជាប្រយោជន៍ដើម្បីទំនុកបម្រុងដល់ខ្លួន ដើម្បីទំនុកបម្រុងដល់អ្នកដទៃ ដើម្បីទំនុកបម្រុងដល់ខ្លួនឯងនិងអ្នកដទៃទាំងពីរខាង និងគិតឱ្យជាប្រយោជន៍ដើម្បីទំនុកបម្រុងដល់លោកទាំងមូល ។ ម្នាលភិក្ខុ បុគ្គលជាបណ្ឌិតមានប្រាជ្ញាច្រើន យ៉ាងនេះឯង ។

ក្នុងបិដកលេខ ៤៨ ទំព័រ ១៧៣ **បឋមសប្បុរិសសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្ដែងទានរបស់សប្បុរស ៨ យ៉ាង :

ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាននេះមាន ៨ យ៉ាង ។ សប្បុរិសទាន ៨ យ៉ាង តើដូចម្ដេចខ្លះ ។ គឺបុគ្គលឱ្យវត្ថុស្អាត ១ ឱ្យវត្ថុថ្លៃថ្លា ១ ឱ្យតាមកាល ១ ឱ្យវត្ថុគួរ ១ ជ្រើសរើសហើយទើបឱ្យ ១ ឱ្យទានរឿយៗ ១ កំពុងឱ្យញ៉ាំងចិត្តឱ្យជ្រះថ្លា ១ លុះឱ្យផុត

ហើយ រមែងមានសេចក្ដីពេញចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាន ៨ យ៉ាងនេះឯង ។

**សុចឹ បណីតំ កាលេន  កប្បិយំ បានភោជនំ**
**អភិណ្ហំ ទទាតិ ទានានិ  សុខេត្តេសុ ព្រហ្មចារិសុ**
**នេវ វិប្បដិសារិយំ  ចជិត្វា អាមិសំ ពហុំ**
**ឯវំ ទិន្នានិ ទានានិ  វណ្ណយន្តិ វិបស្សិនោ**
**ឯវំ យជិត្វា មេធាវី  សទ្ធោ មុត្តេន ចេតសា**
**អព្យាបជ្ឈំ សុខំ លោកំ  បណ្ឌិតោ ឧបបជ្ជតីតិ ។**

សប្បុរស រមែងឱ្យនូវទានទាំងឡាយគឺ ទឹកនិងភោជនដ៏ស្អាត ថ្លៃថ្លា តាមកាល វត្ថុដ៏គួរ រឿយៗចំពោះព្រហ្មចារីបុគ្គលទាំងឡាយ ដែលជាស្រែដ៏ល្អ ។ ពួកអ្នកប្រាជ្ញ រមែងសរសើរនូវទានទាំងឡាយដែលសប្បុរសលះបង់នូវអាមិសៈជាច្រើន ដែលមិនមានសេចក្ដីក្ដៅក្រហាយ ហើយឱ្យទៅយ៉ាងនេះ ។ អ្នកប្រាជ្ញមានបញ្ញា ជាអ្នកមានសទ្ធា បានលះបង់យ៉ាងនេះហើយ មានចិត្តរួចស្រឡះ រមែងចូលទៅកាន់លោក ដែលមិនមានការបៀតបៀន មានតែសេចក្ដីសុខ ។

ក្នុងបិដកលេខ ៤៨ ទំព័រ ១៧៤ **ទុតិយសប្បុរិសសុត្រ** ព្រះអង្គទ្រង់ត្រាស់សម្ដែងអំពី ការកើតឡើងនៃសប្បុរស រមែង





ប្រព្រឹត្តទៅដើម្បីប្រយោជន៍ :

ម្នាលភិក្ខុទាំងឡាយ សប្បុរស កាលកើតក្នុងត្រកូល រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខ ដល់មាតាបិតា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់បុត្រភរិយា ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់បុរសជាទាសកម្មករ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់មិត្តនិងអាមាត្យទាំងឡាយ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់ពួកញាតិដែលចែកឋានទៅកាន់បរលោក ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់ព្រះរាជា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់ពួកទេវតា ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើន ដើម្បីសេចក្ដីសុខដល់សមណព្រាហ្មណ៍ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មហាមេឃ កាលញ៉ាំងសំទូងទាំងឡាយ ឱ្យសម្រេចព្រម រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីចម្រើនដល់ជនច្រើន ។ល។ មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ សប្បុរស កាលកើតក្នុងត្រកូល រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍

ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់មាតានិងបិតាទាំងឡាយ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់បុត្រភរិយា ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់បុរសជាទាសកម្មករ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់មិត្តនិងអាមាត្យទាំងឡាយ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ពួកញាតិដែលចែកឋានទៅកាន់បរលោក ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ព្រះរាជា ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ពួកទេវតា ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់សមណព្រាហ្មណ៍ទាំងឡាយ ក៏មានឧបមេយ្យ ដូច្នោះដែរ ។

**ពហូនំ វត អត្ថាយ សប្បញ្ញោ ឃរមាវសំ**
**មាតរំ បិតរំ បុព្វេ រត្តិន្ទិវមតន្ទិតោ**
**បូជេតិ សហធម្មេន បុព្វេ កតមនុស្សរំ**
**អនាគារេ បព្វជិតេ អបចេ ព្រហ្មចារិនោ**





**និវិដ្ឋសទ្ធោ បូជេតិ ញត្វា ធម្មេ ច បេសលោ**
**រញ្ញោ ហិតោ ទេវហិតោ ញាតីនំ សខិនំ ហិតោ**
**សព្វេសំ សហិតោ ហោតិ សទ្ធម្មេ សុបតិដ្ឋិតោ**
**វិនេយ្យ មច្ឆេរមលំ សលោកំ ភជតេ សិវន្តិ ។**

សប្បុរសប្រកបដោយបញ្ញា កាលនៅគ្រប់គ្រងផ្ទះ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ពួកជនច្រើន ជាអ្នកមិនខ្ជិលច្រអូសក្នុងវេលាយប់និងថ្ងៃ កាលនឹករលឹកដល់បុព្វការគុណដែលមាតានិងបិតាធ្វើហើយ រមែងបូជាមាតាបិតាជាមុន ដោយហេតុប្រកបដោយធម៌ ។ សប្បុរស មានសទ្ធាតាំងមាំហើយ មានសីលជាទីស្រឡាញ់ បានជ្រាបនូវធម៌ហើយ រមែងបូជានូវបព្វជិតដែលជាអ្នកមិនគ្រប់គ្រងផ្ទះ មិនមានបាប ជាព្រហ្មចារីបុគ្គល ។ សប្បុរសណា ទំនុកបម្រុងនូវប្រយោជន៍ដល់ព្រះរាជា ដល់ទេវតា ដល់ពួកញាតិ ដល់មិត្តសម្លាញ់ តម្កល់ស៊ប់ក្នុងព្រះសទ្ធម្ម សប្បុរសនោះ ឈ្មោះថាមានប្រយោជន៍ដល់បុគ្គលទាំងអស់ ។ បុគ្គលណាកម្ចាត់បង់នូវមន្ទិល គឺសេចក្តីកំណាញ់ បុគ្គលនោះ រមែងជួបប្រទះនូវលោកដ៏ក្សេមក្សាន្ត ។

ក្នុងបិដកលេខ ៤៤ ទំព័រ ៩៤ ព្រះគាថានៅក្នុង **សប្បុរិសសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងខាងដើមនៃព្រះគាថា អំពីការ

កើតឡើងនៃសប្បុរសក្នុងត្រកូល រមែងកើតដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ជនច្រើនគ្នា គឺដល់មាតាបិតាទាំងឡាយ ដល់បុត្រនិងភរិយា ដល់បុរសជាទាសកម្មករ ដល់ពួកមិត្តអាមាត្យ និងដល់ពួកសមណព្រាហ្មណ៍ រួចទើបព្រះអង្គទ្រង់ត្រាស់សម្ដែងនូវព្រះគាថា :

**ហិតោ ពហុន្នំ បដិបជ្ជ ភោគេ**
**តំ ទេវតា រក្ខតិ ធម្មគុត្តំ**
**ពហុស្សុតំ សីលវតូបបន្នំ**
**ធម្មេ ឋិតំ ន វិជហាតិ កិត្តិ ។**

**ធម្មដ្ឋំ សីលសម្បន្នំ សច្ចវាទឹ ហិរីមនំ**
**នេក្ខំ ជម្ពោនទស្សេវ កោ តំ និន្ទិតុមរហតិ**
**ទេវាបិ នំ បសំសន្តិ ព្រហ្មុនាបិ បសំសិតោតិ ។**

សប្បុរសគ្រប់គ្រងនូវភោគទ្រព្យ ជាប្រយោជន៍ទំនុកបម្រុងដល់ពពួកជនច្រើន ទេវតារមែងរក្សានូវសប្បុរសដែលជាអ្នកគ្រប់-គ្រងធម៌នោះ ជាពហុស្សូត បរិបូណ៌ដោយសីល និងការប្រព្រឹត្តកិត្តិសព្ទរមែងមិនលះបង់នូវសប្បុរស ដែលជាអ្នកតាំងនៅក្នុងធម៌ឡើយ ។

អ្នកណាមួយអាចដើម្បីនិន្ទា បុគ្គលដែលឋិតនៅក្នុងធម៌





បរិបូណ៌ដោយសីល ពោលពាក្យសច្ចៈ មានចិត្តប្រកបដោយការខ្មាសខ្ពើមបាប បីដូចជាមាសជម្ពូនទៈនោះបាន សូម្បីតែពួកទេវតាក៏រមែងសរសើរនូវបុគ្គលនោះ ទាំងព្រហ្មក៏សរសើរនូវបុគ្គលនោះដែរ ។

ក្នុងបិដកលេខ ៤៧ ទំព័រ ៦០ **ទុតិយសក្ខាសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្ដែងអំពីគុណសម្បត្តិនៃមិត្តសម្លាញ់ :

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមិត្តប្រកបដោយធម៌ ៧ ប្រការ បុគ្គលអ្នកស្វែងមិត្ត ទោះបីលោកបណ្ដេញបំបរបង់ចេញ ក៏គួរតែសេពគប់ រាប់រក ចូលទៅអង្គុយជិត ។ ប្រកបដោយធម៌ ៧ ប្រការតើដូចម្ដេចខ្លះ ។ គឺភិក្ខុជាអ្នក (ធ្វើខ្លួន) ឲ្យជាទីស្រឡាញ់ និងជាទីគាប់ចិត្ត ១ គួរគោរព ១ គួរសរសើរ ១ ឧស្សាហ៍ប្រៀនប្រដៅ ១ អត់ធន់ចំពោះពាក្យ ១ ជាអ្នកនិយាយពាក្យជ្រៅ ១ មិនដឹកនាំក្នុងហេតុដែលមិនគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាមិត្តប្រកបដោយធម៌ ៧ ប្រការនេះឯង បុគ្គលអ្នកស្វែងមិត្ត បើទុកជាលោកបណ្ដេញបំបរបង់ចេញ ក៏គួរតែសេពគប់ រាប់រកចូលទៅអង្គុយជិត ។

**បិយោ ច គរុ ភាវនីយោ វត្តា ច វចនក្ខមោ**
**គម្ភីរញ្ច កថំ កត្តា នោ ចដ្ឋានេ និយោជយេ**

**យស្មឹ ឯតានិ ឋានានិ សំវិជ្ជន្តីធ បុគ្គលេ**
**សោ មិត្តោ មិត្តកាមេន អត្ថកាមានុកម្បតោ**
**អបិ នាសិយមានេន ភជិតព្វោ តថាវិធោតិ ។**

ភិក្ខុជាអ្នក (ធ្វើខ្លួន ) ឱ្យជាទីស្រឡាញ់ផង គួរគោរពផង គួរសរសើរផង ឧស្សាហ៍ប្រៀនប្រដៅផង អត់ធន់ចំពោះពាក្យផង ជាអ្នកនិយាយពាក្យជ្រៅផង ទាំងមិនដឹកនាំក្នុងហេតុដែលមិនគួរផង ហេតុទាំងនេះ មានក្នុងភិក្ខុណា ភិក្ខុនោះជាមិត្តពិត ។ ក្នុងលោកនេះ បុគ្គលជាអ្នកប្រាថ្នានូវប្រយោជន៍ ជាអ្នកធ្វើនូវសេចក្ដីអនុគ្រោះ មានសភាពដូច្នោះនោះ បុគ្គលអ្នកមានសេចក្ដីត្រូវការដោយមិត្ត ទោះបីជាលោកបណ្ដេញ ក៏គួរតែតាមសេពគប់នឹងលោកដែរ ។

នៅក្នុងសៀវភៅ **ពរ ៤ ប្រការ** ទំព័រ ៨១ ដល់ ៨៦ មានសេចក្ដីពន្យល់គោលធម៌ទាំង ៧ ចំណុច :

មាតាបិតាគប្បីឧស្សាហ៍ណែនាំកូន កុំឱ្យធ្វើនូវអំពើអាក្រក់ ឱ្យកូនចេះប្រព្រឹត្តធ្វើនូវអំពើល្អ និងឱ្យខំសិក្សារៀនសូត្រស្វែងរកចំណេះដឹងទូទៅ ។ លោកគ្រូអាចារ្យគប្បីឧស្សាហ៍ណែនាំសិស្សឱ្យល្អ ខំបង្រៀនចំណេះវិជ្ជាដោយការយកចិត្តទុកដាក់ ។ បព្វជិតក្នុងព្រះពុទ្ធសាសនាគប្បីហាមប្រាមគ្រហស្ថក្នុងត្រកូលកុំឱ្យធ្វើបាប





ណែនាំឱ្យតាំងនៅក្នុងសេចក្ដីល្អ អនុគ្រោះពុទ្ធបរិស័ទដោយទឹកចិត្តមេត្តា ឱ្យបានស្ដាប់ធម៌ដែលមិនធ្លាប់បានស្ដាប់ ឱ្យកាន់តែច្បាស់ឡើងនូវធម៌ដែលធ្លាប់បានស្ដាប់ហើយ និងបង្ហាញផ្លូវនៃជីវិតឱ្យបានជួបប្រសព្វសេចក្ដីសុខចម្រើន ។ បុគ្គលដែលមានតួនាទីជាអ្នកបង្រៀនសិស្ស គប្បីប្រកបដោយគុណសម្បត្តិ ៧ ប្រការគឺ

គុណសម្បត្តិប្រការទី ១. **បិយោ** ចេះធ្វើខ្លួនឱ្យជាទីស្រឡាញ់ចូលដល់ក្នុងចិត្តរបស់សិស្ស សាងនូវភាពជិតដិត ស្និទ្ធស្នាល ដើម្បីជាប្រយោជន៍ឱ្យសិស្សចូលចិត្តមករៀនជាមួយ និងហ៊ានប្រឹក្សាសាកសួរបញ្ហាផ្សេងៗ ។

គុណសម្បត្តិប្រការទី ២. **គរុ** ធ្វើខ្លួនឱ្យថ្លៃថ្នូរ គួរដល់ការគោរព និងកោតសរសើរអំពីសិស្សទាំងឡាយ មានការប្រព្រឹត្តដ៏សមគួរដល់ឋានៈ ធ្វើឱ្យកើតការកក់ក្ដៅ បានជាទីពឹង និងបានជាប្រយោជន៍ដល់សិស្សពិតប្រាកដ ។

គុណសម្បត្តិប្រការទី ៣. **ភាវនីយោ** អប់រំទូន្មានខ្លួនឱ្យមានការចម្រើនទៅដោយចំណេះដឹង ទ្រទ្រង់នូវភូមិបញ្ញាពិតប្រាកដ ( ការទូន្មានខ្លួន ជាកន្លែងកើតនៃបញ្ញា )ជាអ្នកហ្វឹកហាត់ថែបំប៉នចិត្ត ដោយមាននូវស្មារតីជាអចិន្ត្រៃយ៍ គួរជាទីលើកតម្កើងនិងជាទីសង្ឃឹមកក់ក្ដៅក្នុងចិត្ត រីករាយក្នុងចិត្តនៅពេលដែលសិស្សមានការ

នឹករលឹកឃើញទៅដល់លោកគ្រូ ព្រមទាំងយកជាគំរូទៀតផង ។

គុណសម្បត្តិប្រការទី ៤. **វត្តា** ចេះនិយាយឱ្យបានផល គឺចេះពន្យល់ឱ្យសិស្សយល់ ដឹងថាពេលណាគួរនិយាយអ្វី ហើយនិយាយយ៉ាងណា និងព្យាយាមរឿយៗ ក្នុងការពន្យល់ណែនាំរំលឹកដាស់តឿន ព្រមទាំងជាទីប្រឹក្សាដែលល្អ ។

គុណសម្បត្តិប្រការទី ៥. **វចនក្ខមោ** អត់ធន់ចំពោះសម្ដីនៃអ្នកដទៃ គឺព្រមពេលដែលបានស្ដាប់ពាក្យប្រឹក្សាសាកសួរឥតប្រយោជន៍ គ្រាន់តែជាការរំខានក្ដី ពាក្យរបស់អ្នកដទៃពោលបង្អាប់ ឬចាក់រុកអុជអាលក្ដី សូម្បីពាក្យពោលរំលឹកដាស់តឿនអំពីអ្នកដទៃដែលគេបានឃើញនូវកំហុសត្រង់ណាមួយក្ដី រមែងអាចអត់ទ្រាំស្ដាប់បាន ដោយមិនថ្នាំងថ្នាក់អាក់អន់ចិត្ត ឬខូចចិត្តអ្វីឡើយ និងចេះឃើញកំហុសរបស់ខ្លួន ចេះសុំខមាទោសព្រមទាំងចេះកែនូវកំហុសតាមវិស័យនៃអ្នកកសាងខ្លួនទៀតផង ។

គុណសម្បត្តិប្រការទី ៦. **គម្ភីរញ្ច កថំ កត្តា** ពោលពាក្យមានជម្រៅ ជ្រៅធម៌ ជ្រៅសេចក្ដី គឺពោលចង្អុលធម៌ផ្សេងៗក្នុងជីវិត ឱ្យឃើញមានជម្រៅទៅតាមសេចក្ដីពិតនៃសច្ចធម៌និងពោលនូវពាក្យណាដែលជ្រៅលំបាក ឱ្យមកជារាក់ដូចបើករបស់ដែលកំបាំង ឬផ្ងាររបស់ដែលផ្កាប់ ដើម្បីឱ្យអ្នកស្ដាប់បានយល់ប្រាកដ





ក្នុងចិត្តព្រមទាំងពោលតាមលំដាប់ មិនស្រូតកាត់ឱ្យខូចសេចក្ដី ជាការជម្រាលសេចក្ដីទៅរកជម្រៅ ទន់ទេរទៅដូចជាច្រាំងនៃមហាសមុទ្រ ។

គុណសម្បត្តិប្រការទី ៧. **នោ ចដ្ឋានេ និយោជយេ** មិនដឹកនាំទៅរកផ្លូវនៃសេចក្ដីវិនាស ឬផ្លូវដែលមិនមែនជាហេតុនៃសេចក្ដីចម្រើន របៀបដូចជាអាចារ្យដើមរបស់អង្គុលិមាលនោះឡើយ ។ អង្គុលិមាល កាលដើម ជាទីស្រឡាញ់របស់គ្រូរហូតដល់សិស្សដទៃមានការច្រណែន ហើយបានញុះញង់គ្រូឱ្យមានការភ័យខ្លាចថា អង្គុលិមាលក្បត់ចិត្ត ។ ហេតុតែគ្រូល្ងង់ហើយខ្វះនូវគុណសម្បត្តិទី ៧ នេះ ក៏បានដឹកនាំបញ្ឆោតឱ្យអង្គុលិមាលទៅសម្លាប់មនុស្សមួយពាន់នាក់ ដើម្បីប្រកបនូវមន្តវិជ្ជាពិសេស ក្នុងបំណងឱ្យគេសម្លាប់អង្គុលិមាល ដែលជាមនុស្សអាក្រក់ បានជាភ្លេចថា ខ្លួនឯងជាគ្រូបានប្រព្រឹត្តដូចនេះវាអាក្រក់ជាងអង្គុលិមាលទៅទៀត ។

ពុទ្ធគាថាអំពីគុណសម្បត្តិរបស់គ្រូ ៧ យ៉ាងដែលបានអធិប្បាយរួចហើយ :

**បិយោ ច គរុ ភាវនីយោ វត្តា ច វចនក្ខមោ**
**គម្ភីរញ្ច កថំ កត្តា នោ ចដ្ឋានេ និយោជយេ ។**

គ្រូអាចារ្យធ្វើខ្លួន ឱ្យជាទីស្រឡាញ់ផង គួរគោរពផង គួរ

សរសើរផង ឧស្សាហ៍ប្រៀនប្រដៅផង អត់ធន់ចំពោះពាក្យផង ជាអ្នកនិយាយពាក្យជ្រៅផង ទាំងមិនដឹកនាំក្នុងហេតុដែលមិនគួរផង ។

គុណធម៌ទាំងនេះ មានក្នុងគ្រូអាចារ្យណា ក្នុងលោកនេះ គ្រូអាចារ្យនោះជាមិត្តពិតប្រាកដ ជាអ្នកប្រាថ្នាអនុគ្រោះនូវប្រយោជន៍ ។ បុគ្គលណាដែលមានសេចក្តីត្រូវការដោយមិត្ត គួរសេពគប់នូវមិត្ត ដែលមានសភាពបែបនេះ ទោះបីជាត្រូវលោកពោលបណ្តេញដោយប្រការណាក៏ដោយ ។





## សេចក្តីសំខាន់នៃការមានកល្យាណមិត្ត

ក្នុងបិដកលេខ ៣៧ ទំព័រ ៦៣ នៅក្នុង **បឋមកល្យាណ-មិត្តសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងថា «ការមានមិត្តល្អ ជាបុព្វ-និមិត្តនៃអរិយមគ្គ» មានសេចក្តីផ្តើមដូចតទៅ :

សាវត្ថីនិទាន ។ ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណនេះជាប្រធាន នេះជាបុព្វនិមិត្ត (គ្រឿងកំណត់មុន )នៃព្រះអាទិត្យដែលរះឡើង ។ ម្នាលភិក្ខុទាំងឡាយ ការមានមិត្តល្អ នេះជាប្រធាន នេះជាបុព្វនិមិត្ត ប្រព្រឹត្តទៅដើម្បីញុំាងអរិយមគ្គប្រកបដោយអង្គ ៨ ឱ្យកើតឡើងដល់ភិក្ខុ ដោយប្រការយ៉ាងនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនេះជាទីសង្ឃឹមរបស់ភិក្ខុដែលមានមិត្តល្អ ភិក្ខុនោះនឹងចម្រើនអរិយមគ្គប្រកបដោយអង្គ ៨ និងធ្វើអរិយ-មគ្គប្រកបដោយអង្គ ៨ ឱ្យច្រើនឡើង ។

ក្នុងបិដកលេខ ៣៧ ទំព័រ ៣ **ឧបឌ្ឍសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីភាពនៃបុគ្គល ដែលមានមិត្តល្អ ចាត់ជាព្រហ្ម-

ចរិយធម៌ទាំងមូល មិនមែនពាក់កណ្ដាលដូចព្រះអានន្ទបានពោលនោះឡើយ សេចក្ដីនេះមានដូចតទៅ :

ខ្ញុំបានស្ដាប់មកយ៉ាងនេះ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងសក្ករនិគមរបស់ពួកសក្យៈ ក្នុងដែនសក្យៈ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គុណជាតឯណា គឺការមានមិត្តល្អ ការមានសម្លាញ់ល្អ និងការមានភ្លើល្អ គុណជាតនេះ ចាត់ជាពាក់កណ្ដាលនៃព្រហ្មចរិយធម៌ ។

ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលអានន្ទអ្នកកុំពោលយ៉ាងនេះឡើយ ម្នាលអានន្ទ គុណជាតឯណា គឺការមានមិត្តល្អ ការមានសម្លាញ់ល្អ និងការមានភ្លើល្អ គុណជាតនេះឯងចាត់ជាព្រហ្មចរិយធម៌ទាំងមូល ។ ម្នាលអានន្ទ ព្រហ្មចរិយធម៌នេះឯង ប្រាកដដល់ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានភ្លើល្អ និងចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ និងធ្វើឱ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។

ម្នាលអានន្ទ ចុះភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានភ្លើល្អ



ចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឱ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ តើដូចម្ដេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសម្មាទិដ្ឋិ ដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្ដីនឿយណាយ អាស្រ័យនូវសេចក្ដីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់ ចម្រើននូវសម្មាសង្កប្បៈដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ ។ល។ ចម្រើននូវសម្មាវាចា ។ល។ ចម្រើននូវសម្មាកម្មន្តៈ ។ល។ ចម្រើននូវសម្មាអាជីវៈ ។ល។ ចម្រើននូវសម្មាវាយាមៈ ។ល។ ចម្រើននូវសម្មាសតិ ។ល។ ចម្រើននូវ សម្មាសមាធិ ដែលអាស្រ័យនូវសេចក្ដីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្ដីនឿយណាយ អាស្រ័យនូវសេចក្ដីរលត់ មានកិរិយាបង្អោនទៅដើម្បីលះបង់។ ម្នាលអានន្ទ ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានភ្លើល្អ ចម្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ធ្វើឱ្យច្រើននូវមគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ យ៉ាងនេះឯង ។

ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្ដីនោះដោយបរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការមានសម្លាញ់ល្អ និងការមានភ្លើល្អ ។ ម្នាលអានន្ទ ព្រោះអាស្រ័យតថាគតដែលជាមិត្តល្អ បានជាពួកសត្វដែលមានជាតិជាធម្មតា រួចស្រឡះចាកជាតិទៅបាន ពួកសត្វដែលមានជរាជាធម្មតា រួច

ស្រឡះចាកជរាទៅបាន ពួកសត្វដែលមានមរណៈជាធម្មតា រួចស្រឡះចាកមរណៈទៅបាន ពួកសត្វដែលមានសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តជាធម្មតា រួចស្រឡះចាកសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទៅបាន ។ ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្តីនុ៎ះដោយបរិយាយនេះចុះថា នេះជាព្រហ្មចរិយធម៌ទាំងមូល គឺការមានមិត្តល្អ ការមានសម្លាញ់ល្អ និងការមានភ្លើល្អ ។

ក្នុងបិដកលេខ ៣៧ ទំព័រ ២០៣ នៅក្នុង **បឋមសុរិយូបមសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងថា «ការមានមិត្តល្អ ជាបុព្វនិមិត្តនៃពោជ្ឈង្គ ៧» មានសេចក្តីផ្តើមដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណនុ៎ះឯងជាប្រធាន ជាបុព្វនិមិត្ត នៃព្រះអាទិត្យដែលរះឡើង (យ៉ាងណា ) ភាវៈនៃកល្យាណមិត្តនុ៎ះឯង ជាប្រធាន ជាបុព្វនិមិត្តនៃការញ៉ាំងពោជ្ឈង្គទាំង ៧ ឱ្យកើតឡើងដល់ភិក្ខុ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ ភិក្ខុដែលនឹងចម្រើននូវពោជ្ឈង្គទាំង ៧ ធ្វើឱ្យរឿយៗ នូវពោជ្ឈង្គទាំង ៧ (នោះ ) គួរប្រាថ្នានូវភិក្ខុដែលជាកល្យាណមិត្ត (កុំខាន ) ។



ក្នុងបិដកលេខ ៤០ ទំព័រ ២៦ នៅក្នុង **កល្យាណមិត្តតាទិវគ្គទី ៨** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីប្រយោជន៍ដ៏សំខាន់ ព្រោះមកអំពីមានកល្យាណមិត្ត មានសេចក្តីផ្តើមដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈ ១ ដែលញ៉ាំងពួកកុសលធម៌ មិនទាន់កើតឡើងឱ្យកើតឡើងបានក្តី ពួកអកុសលធម៌ ដែលកើតឡើងហើយ ឱ្យសាបសូន្យទៅក្តី ដូចការមានកល្យាណមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានកល្យាណមិត្ត ពួកកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ ដែលកើតឡើងហើយ រមែងសាបសូន្យទៅផង ។

ក្នុងបិដកលេខ ៤០ ទំព័រ ៣៣ នៅក្នុង **បមាទាទិវគ្គទី ៩** ព្រះអង្គទ្រង់ត្រាស់សម្តែង អំពីប្រយោជន៍ដ៏ច្រើន ព្រោះមកអំពីមានកល្យាណមិត្ត មានដូចតទៅ :

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើនដូចការមានកល្យាណមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការមាននូវកល្យាណមិត្តនេះឯង ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

ក្នុងបិដកលេខ ៤០ ទំព័រ ៤២ ក្នុង **វគ្គទី ១០** ព្រះអង្គទ្រង់ត្រាស់សម្តែងថា :

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែ ១ ដែលប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននូវព្រះសទ្ធម្ម ដូចការមានកល្យាណមិត្តនេះសោះឡើយ។ ម្នាលភិក្ខុទាំងឡាយ មានតែការមាននូវកល្យាណមិត្តនេះឯង ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាននូវព្រះសទ្ធម្ម ។

ក្នុងបិដកលេខ ៤០ ទំព័រ ៣៧ ក្នុង **វគ្គទី ១០** ព្រះអង្គទ្រង់ត្រាស់សម្តែងថា :

ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញនូវអង្គដទៃដែលជាអង្គខាងក្រៅ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ច្រើន ដូចការមានកល្យាណមិត្តនេះសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានតែ ការមាននូវកល្យាណមិត្តនេះឯង ទើប (ជាអង្គខាងក្រៅ) ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

ក្នុងបិដកលេខ ៥៣ ទំព័រ ១៥ **ទុតិយសេក្ខសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីព្រះសេក្ខៈ ជាអ្នកមានសេចក្តីចម្រើនព្រោះមានកល្យាណមិត្ត ខ្លឹមសារមានទាំងស្រុងដូចតទៅ :

ខ្ញុំបានស្តាប់មកថា ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ





ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុជាសេក្ខៈ មិនទាន់សម្រេចអរហត្តផលនៅឡើយ ហើយប្រាថ្នាធម៌ជាទីក្សេមចាកយោគៈដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើបច្ច័យខាងក្រៅឱ្យជាហេតុហើយ មិនឃើញហេតុដទៃ សូម្បីតែហេតុមួយ ដែលមានឧបការៈច្រើនយ៉ាងនេះ ឱ្យដូចជាភាពនៃបុគ្គលមានកល្យាណមិត្តនេះឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកល្យាណមិត្ត ទើបលះបង់អកុសល ចម្រើនកុសលបាន ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងព្រះសូត្រនោះថា :

**កល្យាណមិត្តោ យោ ភិក្ខុ សប្បតិស្សោ សគារវោ**
**ករំ មិត្តានំ វចនំ សម្បជានោ បតិស្សតោ**
**បាបុណេ អនុបុព្វេន សព្វសំយោជនក្ខយន្តិ ។**

ភិក្ខុណា មានកល្យាណមិត្ត មានសេចក្តីកោតក្រែងប្រកបដោយសេចក្តីគោរព ធ្វើតាមពាក្យរបស់កល្យាណមិត្តទាំងឡាយ ជាអ្នកមានសេចក្តីដឹងខ្លួន មានស្មារតី ភិក្ខុនោះ ទើបគួរដល់នូវកិរិយាអស់សំយោជនៈទាំងពួង ដោយលំដាប់បាន ។ សេចក្តីនេះ ព្រះដ៏មានព្រះភាគ បានត្រាស់ទុកហើយ ខ្ញុំបានស្តាប់មកហើយដូច្នេះឯង ។

ក្នុងបិដកលេខ ៤៩ ទំព័រ ៤ នៅក្នុង **សម្ពោធិសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្ដែងអំពីពួកធម៌ជាចំណែកនៃការត្រាស់ដឹង ៥ យ៉ាង រួចហើយព្រះអង្គទ្រង់ត្រាស់សម្ដែងអំពីអានិសង្សនៃការមាន មិត្តល្អ ៤ យ៉ាងជាបន្ត :

១.ម្នាលភិក្ខុទាំងឡាយ ហេតុនេះរមែងកើតប្រាកដដល់ភិក្ខុ អ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹង បានជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយ អាចារៈ និងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ សូម្បី បន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។

២.ម្នាលភិក្ខុទាំងឡាយ ហេតុនេះរមែងកើតប្រាកដដល់ភិក្ខុ អ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹង បានជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយងាយ នូវកថាមានសភាពយ៉ាងនេះ ដែលជាកថាផ្លូវផង់ ជាទីសប្បាយ ទូលាយចិត្ត គឺអប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វិរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ។

៣.ម្នាលភិក្ខុទាំងឡាយ ហេតុនេះរមែងកើតប្រាកដដល់ភិក្ខុ អ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹង





បានជាអ្នកប្រារព្ធនូវសេចក្ដីព្យាយាម ដើម្បីលះបង់នូវពួកអកុសល-ធម៌ចេញ ដើម្បីញុំាងពួកកុសលធម៌ឱ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្ដីប្រឹងប្រែង ខ្ជាប់ខ្ជួន មិនដាក់ធុរៈចោល ក្នុងកុសលធម៌ ទាំងឡាយ ។

៤.ម្នាលភិក្ខុទាំងឡាយ ហេតុនេះរមែងកើតប្រាកដដល់ភិក្ខុ អ្នកមានមិត្តល្អ មានសម្លាញ់ល្អ សមគប់នឹងមិត្តល្អ គឺភិក្ខុនោះនឹង បានជាអ្នកមានបញ្ញា ប្រកបដោយបញ្ញា ដែលអាចកំណត់នូវការ កើតឡើង និងការវិនាសទៅ (នៃខន្ធបញ្ចកៈ) ជាគ្រឿងទម្លាយ នូវកិលេសដ៏ប្រសើរ ជាធម្មជាតិដល់នូវកិរិយាអស់ទៅនៃទុក្ខដោយ ប្រពៃ ។

* អានិសង្សនៃការមានមិត្តល្អទាំង ៤ យ៉ាងនេះ សុទ្ធតែជា ពួកធម៌ជាចំណែកនៃការត្រាស់ដឹង រួមនឹងការមានមិត្តល្អ មាន សម្លាញ់ល្អ សមគប់នឹងមិត្តល្អមួយទៀតដែលជាប្រធាន ទើបបាន ពួកធម៌ជាចំណែកនៃការត្រាស់ដឹងត្រូវជា ៥ ។

ជាចុងបញ្ចប់នៃព្រះសូត្រ ព្រះអង្គទ្រង់ត្រាស់សម្ដែងថា :

ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុនោះតាំងនៅក្នុងធម៌ ទាំង ៥ នេះហើយ គប្បីចម្រើន នូវធម៌ ៤ យ៉ាងតទៅទៀត គឺ

១.ចម្រើនអសុភ ដើម្បីលះរាគៈ

២.ចម្រើនមេត្តា ដើម្បីលះព្យាបាទ

៣.ចម្រើនអានាបានស្សតិ ដើម្បីផ្តាច់ផ្តិលនូវវិតក្ក

៤.ចម្រើនអនិច្ចសញ្ញា ដើម្បីដកចោលនូវអស្មិមានះ ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីសំគាល់ថា មិនមែនខ្លួន រមែងប្រាកដដល់ភិក្ខុអ្នកមានសេចក្តីសំគាល់ថាមិនទៀង ។ ភិក្ខុអ្នកមានសេចក្តីសំគាល់ថា មិនមែនខ្លួន រមែងដល់នូវព្រះនិព្វានជាគ្រឿងដកចោលនូវអស្មិមានះក្នុងបច្ចុប្បន្ន ។

ក្នុងបិដកលេខ ៤៨ ទំព័រ ២៤៤ នៅក្នុង **ទីឃជាណុសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងការមានមិត្តល្អ គឺបានសន្ទនាធម៌ជាមួយនឹងអ្នកមានសទ្ធា សីល ចាគៈ បញ្ញា នាំឱ្យបានសម្រេចនូវប្រយោជន៍បច្ចុប្បន្ន ។

ក្នុងបិដកលេខ ១៩ ទំព័រ ៧២ នៅក្នុង **សិង្គាលកសូត្រ** ព្រះអង្គទ្រង់សម្តែងអំពីអបាយមុខ គឺប្រធាននៃសេចក្តីវិនាស ក្នុងនោះមានការសេពគប់បាបមិត្តមួយផងដែរ ។ ក្នុងបិដកលេខ ៤៨ ទំព័រ ២៤៧ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីបាបមិត្តនាំឱ្យមាននូវសេចក្តីវិនាសដូចគ្នា ។

ក្នុងបិដកលេខ ១៩ ទំព័រ ៧៨ នៅក្នុង **សិង្គាលកសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងឱ្យចេះជ្រើសរើសមនុស្ស ដើម្បីសេពគប់





គឺមិត្តដូចម្តេចជាមិត្តពិត មិត្តដូចម្តេចជាមិត្តប្លម ។

ក្នុងបិដកលេខ ១៩ ទំព័រ ២៦៣ នៅក្នុង **ឧសុត្តរសូត្រ** ពួក ៤ មានធម៌សម្តែង អំពីការសេពគប់នឹងសប្បុរស គឺជាធម៌មួយក្នុងចក្កធម៌ ៤ ប្រការ ។ ចក្កធម៌គឺជាធម៌ដែលនាំជីវិតឆ្ពោះទៅរកសេចក្តីចម្រើនរុងរឿង ដូចកង់នាំរថទៅកាន់ទិសដៅ និងម្យ៉ាងទៀត ចក្កធម៌ ៤ ប្រការនេះមានឧបការគុណដ៏ក្រៃលែង ។ ចក្កធម៌ ៤ ប្រការគឺ ១.ការនៅក្នុងប្រទេសដ៏សមគួរ ២.ការសេពគប់នឹងសប្បុរស ៣.ការតម្កល់ខ្លួនដោយប្រពៃ ៤.ភាពជាអ្នកបានធ្វើបុណ្យទុកក្នុងកាលមុន ។ ក្នុងបិដកលេខ ៤២ ទំព័រ ៧៩ ព្រះអង្គទ្រង់ត្រាស់សម្តែង **ចក្កសូត្រ** មានធម៌ ៤ យ៉ាងនេះឯង ។

ក្នុងបិដកលេខ ៤៣ ទំព័រ ២៦២ និង ២៦៣ ព្រះអង្គទ្រង់ត្រាស់សម្តែងនូវធម៌ ៤ គឺ ១.ការសេពគប់សប្បុរស ២.ការស្តាប់ធម៌របស់សប្បុរស ៣.ការយកចិត្តទុកដាក់ដោយឧបាយ ៤.ប្រតិបត្តិធម៌ដ៏សមគួរតាមធម៌ ។ ធម៌ទាំង ៤ ប្រការនេះគឺនៅក្នុង **បញ្ញាវុឌ្ឍិសូត្រ** ទ្រង់ត្រាស់ថាជាធម៌នាំឱ្យចម្រើននូវបញ្ញា និងនៅក្នុង **ពហុការសូត្រ** ទ្រង់ត្រាស់ថា ជាធម៌មានឧបការៈច្រើនដល់មនុស្ស ។

ក្នុងបិដកលេខ ៣៩ ទំព័រ ៧៣ នៅក្នុង **ទុតិយសារីបុត្តសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងថា ការសេពគប់នឹងសប្បុរស ជា **សោតាបត្តិយង្គ ១** ។ **សោតាបត្តិយង្គ** គឺជាគុណសម្បត្តិដែលនឹងធ្វើឱ្យបានជាសោតាបន្នបុគ្គល មាន ៤ យ៉ាង បានដល់បញ្ញាវុឌ្ឍិធម៌ ឬឧបការធម៌ហ្នឹងឯង ។

ក្នុងបិដកលេខ ៥០ ទំព័រ ៥១ ព្រះអង្គទ្រង់ត្រាស់សម្តែងនូវ **នាថករណធម៌ ១០ យ៉ាង** ក្នុង ១០ យ៉ាងនោះ មានការមាននូវកល្យាណមិត្តមួយផងដែរ ជាធម៌ដែលធ្វើឱ្យមនុស្សពឹងខ្លួនឯងបាន ។ ក្នុងបិដកលេខ ១៩ នៅក្នុង **សង្គីតិសូត្រ** និងនៅក្នុង **ទសុត្តរសូត្រ** ពួក ១០ មាននាថករណធម៌ដូចគ្នាដែរ ។

ក្នុងបិដកលេខ ៥៤ ទំព័រ ៨៥ នៅក្នុង **មង្គលសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងថា :

**អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា**
**បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ** ។

ការមិនសេពគប់បុគ្គលពាលទាំងឡាយ ១ ការសេពគប់បណ្ឌិតទាំងឡាយ ១ ការបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ នេះជាមង្គលដ៏ឧត្តម ។ ក្នុងបិដកលេខ ៥២ ទំព័រ ៤ ក៏មាន **មង្គលសូត្រ** ដែរ ។





# គួរយល់ដឹងការពិតអំពីវិញ្ញាណ

ក្នុងបិដកលេខ ២២ ទំព័រ ១៥០ នៅក្នុង **មហាតណ្ហាសង្ខយសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីការកើតឡើងនៃវិញ្ញាណ ព្រោះអាស្រ័យបច្ច័យ មានសេចក្តីខាងដើមនៃព្រះសូត្រដូចតទៅ :

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់សម្រេចសម្រាន្តព្រះឥរិយាបថ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុឈ្មោះសាតិជាកូននៃព្រានសំណាញ់ មានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណាអាត្មាអញក៏បានដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ យ៉ាងនោះដែរ ។ ពួកភិក្ខុជាច្រើនរូបបានឮដំណឹងថា សាតិភិក្ខុកេវដ្តបុត្តមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់នូវ

ធម៌ដែលព្រះមានព្រះភាគសម្តែងហើយ យ៉ាងនោះដែរ ។ ទើបភិក្ខុទាំងនោះ ចូលទៅរកសាតិភិក្ខុកេវដ្តបុត្ត លុះចូលទៅដល់ហើយ បានសួរសាតិភិក្ខុកេវដ្តបុត្តដូច្នេះថា ម្នាលអាវុសោសាតិ បានឮថា អ្នកមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ យ៉ាងនោះដែរ ដូច្នេះមែនឬ ។ សាតិភិក្ខុកេវដ្តបុត្តឆ្លើយតបថា ម្នាលអាវុសោទាំងឡាយ វិញ្ញាណរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃ យ៉ាងណា ខ្ញុំក៏បានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ យ៉ាងនោះដែរ ដូច្នេះមែន ។ គ្រានោះ ភិក្ខុទាំងនោះមានបំណងនឹងដោះសាតិ-ភិក្ខុកេវដ្តបុត្តឱ្យរួចចាកទិដ្ឋិអាក្រក់នុ៎ះ ទើបនិយាយពន្យល់ ដាស់តឿន ក្រើនរំលឹកថា ម្នាលអាវុសោសាតិ អ្នកកុំនិយាយយ៉ាងនេះឡើយ អ្នកកុំនិយាយបង្កាច់ព្រះមានព្រះភាគ ព្រោះថា ការដែលពោលបង្កាច់ព្រះមានព្រះភាគមិនប្រពៃទេ ដ្បិតព្រះមានព្រះភាគព្រះអង្គមិនមានបន្ទូលយ៉ាងនេះឡើយ ម្នាលអាវុសោសាតិ ព្រះ-មានព្រះភាគ សម្តែងហើយដោយអនេកបរិយាយថា វិញ្ញាណកើតឡើងព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើត





ឡើងនៃវិញ្ញាណក៏មិនមាន ។ សាតិភិក្ខុកេវដ្តបុត្តកាលបើពួកភិក្ខុទាំងនោះ និយាយពន្យល់ ដាស់តឿន ក្រើនរំលឹក យ៉ាងនេះហើយ ក៏នៅតែចូលចិត្តប្រកាន់ទិដ្ឋិអាក្រក់នោះដដែល ហើយនិយាយប្រកែកតាមកម្លាំងដូច្នេះថា ម្នាលអាវុសោទាំងឡាយ វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា ខ្ញុំក៏បានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះឯង ។

កាលដែលភិក្ខុទាំងនោះ មិនអាចនឹងដោះសាតិភិក្ខុកេវដ្ត-បុត្ត ឱ្យរួចចាកទិដ្ឋិអាក្រក់នុ៎ះបានហើយ ទើបភិក្ខុទាំងអម្បាលនោះ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ក្រាបថ្វាយបង្គំនូវព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះ-មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សាតិភិក្ខុកេវដ្តបុត្តមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសម្តែងហើយ ក៏យ៉ាងនោះដែរ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះយើងខ្ញុំព្រះអង្គបាននាំគ្នាចូលទៅរកសាតិភិក្ខុកេវដ្តបុត្ត លុះចូលទៅដល់

ហើយ បានសួរសាតិភិក្ខុកេវដ្តបុត្តដូច្នេះថា ម្នាលអាវុសោសាតិ បានឮថា អ្នកមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះ រមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា អាត្មាអញក៏បានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគ សម្តែងហើយក៏យ៉ាងនោះ ដូច្នេះ ពិតមែនឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលយើងខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ សាតិភិក្ខុ-កេវដ្តបុត្តក៏បាននិយាយតបមកនឹងយើងខ្ញុំព្រះអង្គដូច្នេះថា ម្នាលអាវុសោទាំងឡាយ វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា ខ្ញុំក៏បានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែន ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះយើងខ្ញុំព្រះអង្គមានបំណងនឹងដោះសាតិភិក្ខុកេវដ្តបុត្ត ឱ្យរួចចាកទិដ្ឋិអាក្រក់នោះ ទើបនាំគ្នានិយាយពន្យល់ដាស់តឿនក្រើនរំលឹកថា ម្នាលអាវុសោសាតិ អ្នកកុំនិយាយយ៉ាងនេះឡើយ អ្នកកុំនិយាយបង្កាច់ព្រះមាន-ព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះមានព្រះភាគមិនប្រពៃទេ ដ្បិតព្រះមានព្រះភាគទ្រង់មិនមានបន្ទូលយ៉ាងនេះឡើយ ។ ម្នាលអាវុសោសាតិ ព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយអនេក-បរិយាយថា វិញ្ញាណកើតឡើង ព្រោះអាស្រ័យបច្ច័យ បើវៀរចាក





បច្ច័យហើយ ការកើតឡើងនៃវិញ្ញាណក៏មិនមាន។បពិត្រព្រះអង្គដ៏ចម្រើន សាតិភិក្ខុកេវដ្តបុត្តកាលបើយើងខ្ញុំព្រះអង្គបាននិយាយពន្យល់ដាស់តឿនក្រើនរំលឹក យ៉ាងនេះហើយ ក៏នៅតែចូលចិត្តប្រកាន់ទិដ្ឋិអាក្រក់នោះដដែល ហើយនិយាយប្រកែកតាមកម្លាំងថា ម្នាលអាវុសោទាំងឡាយ វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា ខ្ញុំក៏បានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែន ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលយើងខ្ញុំព្រះអង្គមិនអាចនឹងដោះសាតិភិក្ខុកេវដ្តបុត្ត ឱ្យរួចចាកទិដ្ឋិអាក្រក់នេះបានហើយ ទើបយើងខ្ញុំព្រះអង្គយកសេចក្តីនេះមកក្រាបបង្គំទូលព្រះ-មានព្រះភាគ ។

គ្រានោះ ព្រះមានព្រះភាគ ត្រាស់ហៅនូវភិក្ខុ ១ រូបមកថា ម្នាលភិក្ខុ ចូរអ្នកមកអាយ ចូរអ្នកទៅហៅនូវសាតិភិក្ខុកេវដ្តបុត្តតាមពាក្យនៃតថាគតថា ម្នាលអាវុសោសាតិ ព្រះសាស្តាទ្រង់ត្រាស់ហៅលោក ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ករុណាព្រះអង្គ ដូច្នេះហើយ ក៏ចូលទៅរកសាតិភិក្ខុកេវដ្តបុត្តលុះចូលទៅដល់ហើយ បាននិយាយទៅនឹងសាតិភិក្ខុកេវដ្តបុត្តដូច្នេះថា ម្នាលអាវុសោសាតិ ព្រះសាស្តាត្រាស់ហៅលោក ។

សាតិភិក្ខុកេវដ្តបុត្តទទួលពាក្យភិក្ខុនោះថា ករុណា អាវុសោ ដូច្នេះហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ កាលបើសាតិភិក្ខុកេវដ្តបុត្តអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមាន-ព្រះភាគទ្រង់ត្រាស់សួរថា ម្នាលសាតិ បានឮថាអ្នកមានទិដ្ឋិអាក្រក់កើតឡើងយ៉ាងនេះថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា ខ្ញុំបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែនឬ ។ សាតិភិក្ខុកេវដ្តបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ យ៉ាងណា ខ្ញុំព្រះអង្គបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ក៏យ៉ាងនោះដែរ ដូច្នេះមែន ។ ព្រះអង្គត្រាស់សួរថា ម្នាលសាតិ វិញ្ញាណនោះតើដូចម្តេច ។ សាតិភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន សភាវៈណា ដែលនិយាយបាន អាចទទួលអារម្មណ៍បាន បុគ្គលរមែងសោយវិបាកនៃកម្មទាំងឡាយល្អ និងអាក្រក់ព្រោះសភាវៈនោះ សភាវៈនោះ (ហៅថាវិញ្ញាណ) ។ ព្រះអង្គត្រាស់ថា ម្នាលមោឃបុរស អ្នកដឹងច្បាស់នូវធម៌ ដែលតថាគតសម្តែងហើយ





យ៉ាងនេះ ដល់បុគ្គលណា ម្នាលមោឃបុរស ក្រែងតថាគតបានសម្តែងហើយ ដោយអនេកបរិយាយថា វិញ្ញាណកើតឡើងអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃវិញ្ញាណក៏មិនមានមិនដូច្នោះទេឬ ម្នាលមោឃបុរស ហេតុដូចម្តេចក៏បានជាអ្នក ពោលបង្កាច់តថាគត ដោយគំនិតដែលខ្លួនប្រកាន់ខុសវិញ អ្នកឈ្មោះថាគាស់រំលើងនូវខ្លួនឯងផង ឈ្មោះថាសោយនូវអកុសលដ៏ច្រើនផង ម្នាលមោឃបុរស ព្រោះថា គំនិតដែលប្រកាន់ខុសរបស់អ្នកនោះ នឹងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ដើម្បីសេចក្តីទុក្ខ អស់កាលយូរអង្វែង ។

គ្រានោះឯង ព្រះមានព្រះភាគត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះថាដូចម្តេច សាតិភិក្ខុកេវដ្តបុត្តនេះ ឈ្មោះថាធ្វើឱ្យកក់ក្តៅក្នុងធម្មវិន័យនេះបានឬទេ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធ្វើដូចម្តេចនឹងបាន បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះមិនមែនដូច្នោះទេ ។ កាលដែលពួកភិក្ខុនិយាយយ៉ាងនេះហើយ សាតិភិក្ខុកេវដ្តបុត្តក៏នៅស្ងៀម អៀនខ្មាស ឱនកចុះ សំយុងមុខចុះ អង្គុយសញ្ជប់សញ្ជឹង មិនមានប្រាជ្ញា ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបសាតិភិក្ខុកេវដ្តបុត្ត នៅស្ងៀម អៀនខ្មាស ឱនកចុះ

សំយុងមុខចុះ អង្គុយសញ្ជប់សញ្ជឹង មិនមានប្រាជ្ញាហើយ ទើប ត្រាស់ទៅកាន់សាតិភិក្ខុកេវដ្តបុត្តថា ម្នាលមោឃបុរស អ្នក នឹងប្រាកដជា ប្រកាន់ខ្ជាប់ដោយទិដ្ឋិអាក្រក់របស់ខ្លួននេះតែម្យ៉ាង តថាគតនឹងសាកសួរពួកភិក្ខុដែលនៅក្នុងទីនេះ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ សាតិភិក្ខុកេវដ្តបុត្តនេះ ពោលបង្កាច់តថាគត ដោយគំនិតដែលខ្លួន ប្រកាន់ខុសផង ឈ្មោះថាគាស់រំលើងនូវខ្លួនឯងផង ឈ្មោះថា ទទួលនូវអកុសលដ៏ច្រើនផង យ៉ាងណា ចំណែកអ្នកទាំងឡាយ នឹងយល់ច្បាស់នូវធម៌ ដែលតថាគតសម្តែងហើយ យ៉ាងនោះដែរ ឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំ ព្រះអង្គមិនបានយល់ដូច្នោះទេ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគ បានសម្តែងប្រោសយើងខ្ញុំព្រះអង្គដោយអនេកបរិយាយថា វិញ្ញាណកើតឡើង ព្រោះអាស្រ័យបច្ច័យ បើវៀរចាក បច្ច័យហើយ ការកើតឡើងនៃវិញ្ញាណ ក៏មិនមាន ។ ព្រះអង្គ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាក្យអ្នកទាំងឡាយនោះត្រូវពិត ហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយយល់ច្បាស់នូវធម៌ ដែល តថាគតសម្តែងហើយយ៉ាងនេះ ជាការប្រពៃពិត ម្នាលភិក្ខុ ទាំងឡាយ ព្រោះតថាគតបានសម្តែងហើយ ដោយអនេកបរិយាយ





ថា វិញ្ញាណកើតឡើង ព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យ ហើយ ការកើតឡើងនៃវិញ្ញាណក៏មិនមាន បើដូច្នោះសាតិភិក្ខុ កេវដ្តបុត្តនេះ ពិតជាពោលបង្កាច់តថាគតដោយគំនិតដែលខ្លួន ប្រកាន់ខុសផង ឈ្មោះថាគាស់រំលើងនូវខ្លួនផង ឈ្មោះថាទទួល នូវអកុសលដ៏ច្រើនផង ព្រោះថាការប្រកាន់ខុសរបស់មោឃបុរស នោះ នឹងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់ កាលយូរអង្វែង ។

ម្នាលភិក្ខុទាំងឡាយ វិញ្ញាណកើតឡើងព្រោះអាស្រ័យ បច្ច័យណាៗ ក៏ដល់នូវកិរិយារាប់តាមបច្ច័យនោះៗ ដូចវិញ្ញាណ កើតឡើងព្រោះអាស្រ័យភ្នែកនិងរូប ក៏ដល់នូវកិរិយារាប់ថាចក្ខុវិញ្ញាណ (ការដឹងដោយសារភ្នែក ) វិញ្ញាណកើតឡើង ព្រោះ អាស្រ័យត្រចៀកនិងសំឡេង ក៏ដល់នូវកិរិយារាប់ថាសោតវិញ្ញាណ (ការដឹងដោយសារត្រចៀក ) វិញ្ញាណកើតឡើងព្រោះអាស្រ័យ ច្រមុះនិងក្លិន ក៏ដល់នូវកិរិយារាប់ថាឃានវិញ្ញាណ (ការដឹងដោយ សារច្រមុះ ) វិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាតនិងរស ក៏ដល់នូវកិរិយារាប់ថា ជិវ្ហាវិញ្ញាណ (ការដឹងដោយសារអណ្តាត ) វិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ ក៏ដល់នូវ កិរិយារាប់ថា កាយវិញ្ញាណ (ការដឹងដោយសារកាយ ) វិញ្ញាណ

កើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ក៏ដល់នូវកិរិយារាប់ថា មនោវិញ្ញាណ (ការដឹងដោយសារចិត្ត ) ។ ម្នាលភិក្ខុទាំងឡាយ ដូចជាភ្លើងឆេះ អាស្រ័យនឹងវត្ថុណា១ ក៏ដល់នូវកិរិយារាប់តាមវត្ថុនោះ១ ដូចជាភ្លើងឆេះ ព្រោះអាស្រ័យអុស ក៏ដល់នូវកិរិយារាប់ថា ភ្លើងអុស ភ្លើងឆេះ ព្រោះអាស្រ័យប៉ុយ ក៏ដល់នូវកិរិយារាប់ថា ភ្លើងប៉ុយ ភ្លើងឆេះ ព្រោះអាស្រ័យស្មៅ ក៏ដល់នូវកិរិយារាប់ថា ភ្លើងស្មៅ ភ្លើងឆេះ ព្រោះអាស្រ័យអាចម៍គោ ក៏ដល់នូវកិរិយារាប់ថា ភ្លើងអាចម៍គោ ភ្លើងឆេះ ព្រោះអាស្រ័យអង្កាម ក៏ដល់នូវកិរិយារាប់ថា ភ្លើងអង្កាម ភ្លើងឆេះ ព្រោះអាស្រ័យសំរាម ក៏ដល់នូវកិរិយារាប់ថា ភ្លើងសំរាម យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ វិញ្ញាណកើតឡើង ព្រោះអាស្រ័យនឹងបច្ច័យណា១ ក៏ដល់នូវកិរិយារាប់តាមបច្ច័យនោះ១ ដូចជាវិញ្ញាណកើតឡើងព្រោះអាស្រ័យភ្នែកនិងរូប ក៏ដល់នូវកិរិយារាប់ថាចក្ខុវិញ្ញាណ វិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀកនិងសំឡេង ក៏ដល់នូវកិរិយារាប់ថាសោតវិញ្ញាណ វិញ្ញាណកើតឡើង ព្រោះអាស្រ័យច្រមុះនិងក្លិន ក៏ដល់នូវកិរិយារាប់ថា ឃានវិញ្ញាណ វិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាតនិងរស ក៏ដល់នូវកិរិយារាប់ថាជិវ្ហាវិញ្ញាណ វិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយនិង





ផោដ្ឋព្វៈ ក៏ដល់នូវកិរិយារាប់ថាកាយវិញ្ញាណ វិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ក៏ដល់នូវកិរិយារាប់ថាមនោវិញ្ញាណយ៉ាងនោះដែរ។

* សេចក្តីនៃព្រះសូត្រនៅមានវែងតទៅទៀត ។ អ្នកសិក្សាគប្បីដឹងថា អ្វី ១ ទាំងអស់ក្នុងលោក គ្រាន់តែជាអារម្មណ៍របស់វិញ្ញាណប៉ុណ្ណោះ ឯចំណែកវិញ្ញាណវិញនោះ បានដឹងនូវអារម្មណ៍ហើយ ក៏រលត់ទៅ ។ អារម្មណ៍ដែលវិញ្ញាណបានដឹងជារបស់ខាងក្រៅ បើមិនប្រាថ្នានូវអារម្មណ៍នោះ១ទេ កង្វល់ទាំងឡាយរមែងមិនមាន ស្ងប់ពិត ប្រណីតពិត នេះជាទីពឹងក្នុងវដ្តសង្សារ ជាទីពឹងដែលនាំឱ្យរួចផុតចាកទុក្ខទាំងពួង ។

# ព្រះអរហន្តបរិនិព្វាន

ក្នុងបិដកលេខ ៣៣ ទំព័រ ២៥១ នៅក្នុង **យមកសូត្រ** ភិក្ខុយមកៈបានយល់ខុសថា ព្រះអរហន្តក្រោយអំពីអស់ជីវិតទៅសូន្យ ដល់ព្រះសារីបុត្តសាកសួរដេញដោលរកសត្វបុគ្គល រកព្រះអរហន្តក្នុងបញ្ចក្ខន្ធជាបច្ចុប្បន្នទៅ ស្រាប់តែរកមិនឃើញ ។ តាមពិត ព្រះអរហន្តគឺជាបុគ្គលប្បញ្ញត្តិ ព្រោះអាស្រ័យបញ្ចក្ខន្ធតែប៉ុណ្ណោះ លុះដល់បរិនិព្វានហើយ បញ្ចក្ខន្ធមិនមាន ទើបមិនមានពាក្យនិយាយ ថាព្រះអរហន្តយ៉ាងដូចម្តេចក្នុងព្រះនិព្វាននោះឯង។

មានសេចក្តីខាងដើមនៃព្រះសូត្រដូចតទៅ :

សម័យមួយ ព្រះសារីបុត្តមានអាយុ គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក៏សម័យនោះឯង ភិក្ខុឈ្មោះយមកៈ កើតទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយថា ភិក្ខុជាខីណា-ស្រពតែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។ ភិក្ខុទាំងឡាយច្រើនរូប បានឮ





ថា យមកភិក្ខុ កើតទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយថា ភិក្ខុជាខីណា-ស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។ លំដាប់នោះ ភិក្ខុអម្បាលនោះចូលទៅរកយមកភិក្ខុមានអាយុ លុះចូលទៅដល់ហើយ ក៏រាក់ទាក់ជាមួយនឹងយមកភិក្ខុមានអាយុ លុះបញ្ចប់ពាក្យគួររីករាយ និងពាក្យដែលគួររលឹកហើយ ទើបពោលនឹងយមកភិក្ខុមានអាយុដូច្នេះថា ម្នាលអាវុសោយមកៈ ឮថាលោកកើតទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀត ដូច្នេះពិតឬ ។ យមកភិក្ខុមានអាយុ ឆ្លើយថា ម្នាលអាវុសោ យ៉ាងហ្នឹងមែនហើយ ខ្ញុំយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។ ម្នាលអាវុសោយមកៈ លោកកុំពោលយ៉ាងនេះឡើយ លោកកុំពោលបង្កាច់ព្រះមានព្រះ-ភាគឡើយ ការពោលបង្កាច់ព្រះមានព្រះភាគ មិនល្អទេ ព្រោះព្រះមានព្រះភាគ មិនមែនត្រាស់យ៉ាងនេះថា ភិក្ខុជាខីណាស្រព

តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យមិនកើតទៀត យ៉ាងនេះទេ ។ កាលភិក្ខុអម្បាលនោះ ពោល (ហាមឃាត់ ) យ៉ាងនេះហើយ យមកភិក្ខុមានអាយុក៏នៅតែកួចកាន់ ស្ទាបអង្អែលទិដ្ឋិអាក្រក់នោះ ដូច្នោះដដែល ហើយពោលថា ខ្ញុំយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។ កាលបើភិក្ខុនោះ មិនអាចរំដោះយមកភិក្ខុមានអាយុ ចាកទិដ្ឋិអាក្រក់នេះបាន ទើបភិក្ខុអម្បាលនោះ ក្រោកចាកអាសនៈ ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលនឹងព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត យមកភិក្ខុកើតទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ សូមព្រះសារីបុត្តមានអាយុ និមន្តចូលទៅរកយមកភិក្ខុ ដើម្បីធ្វើនូវសេចក្តីអនុគ្រោះ ។ ព្រះសារីបុត្តមានអាយុ ក៏ទទួលដោយតុណ្ហីភាព ។

លំដាប់នោះ ព្រះសារីបុត្តមានអាយុ ចេញអំពីទីសម្ងំក្នុង





សាយណ្ហសម័យ ហើយចូលទៅរកយមកភិក្ខុមានអាយុ លុះចូលទៅដល់ ក៏ពោលពាក្យរាក់ទាក់ជាមួយនឹងយមកភិក្ខុមានអាយុ ។ល។ លុះព្រះសារីបុត្តមានអាយុ គង់ក្នុងទីសមគួរហើយ ក៏ពោលនឹងយមកភិក្ខុមានអាយុ ដូច្នេះថា ម្នាលអាវុសោយមកៈ ឮថា លោកកើតទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះថា អញយល់ច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀត ដូច្នេះមែនឬ ។ យមកភិក្ខុមានអាយុឆ្លើយថា យ៉ាងហ្នឹងមែនហើយ ម្នាលអាវុសោ ខ្ញុំយល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសម្តែងហើយ ថាភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យទៅ មិនកើតទៀតទេ ។ ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ អាវុសោ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណទៀងឬមិនទៀង។ មិនទៀងទេ អាវុសោ ។ ព្រោះហេតុនោះ អរិយសាវ័កក្នុងសាសនានេះ ។ល។ ឃើញយ៉ាងនេះ ។ល។ ក៏ដឹងច្បាស់ថា មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្តីនោះដូចម្តេច លោកពិចារណាឃើញរូប ថាជាសត្វឬ។ មិនដូច្នោះទេ អាវុសោ។ ព្រះសារីបុត្តសួរថា លោកពិចារណាឃើញវេទនា ថាជាសត្វឬ ។ មិនដូច្នោះទេ អាវុសោ ។ សញ្ញា ។ សង្ខារទាំងឡាយ ។ លោកពិចារណាឃើញវិញ្ញាណ ថាជាសត្វឬ ។ មិនដូច្នោះទេ អាវុសោ ។

ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្តីនោះដូចម្តេច លោកពិចារណាឃើញ ថាសត្វមានក្នុងរូបឬ ។ មិនដូច្នោះទេ អាវុសោ ។ លោកពិចារណាឃើញ ថាសត្វផ្សេងពីរូបឬ ។ មិនដូច្នោះទេ អាវុសោ ។ ក្នុងវេទនា ។ល។ ផ្សេងពីវេទនា ។ល។ ក្នុងសញ្ញា ។ ផ្សេងពីសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ផ្សេងពីសង្ខារទាំងឡាយ ។ លោកពិចារណាឃើញ ថាសត្វមានក្នុងវិញ្ញាណឬ ។ មិនដូច្នោះទេ អាវុសោ ។ លោកពិចារណាឃើញ ថាសត្វផ្សេងពីវិញ្ញាណឬ ។ មិនដូច្នោះទេ អាវុសោ ។

ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្តីនោះដូចម្តេច លោកពិចារណាឃើញរូប។ វេទនា។ សញ្ញា។ សង្ខារទាំងឡាយ ។ វិញ្ញាណ ថាជាសត្វឬ ។ មិនដូច្នោះទេ អាវុសោ ។

ម្នាលអាវុសោយមកៈ លោកសំគាល់សេចក្តីនោះដូចម្តេច លោកពិចារណាឃើញសត្វនេះថា មិនមានរូប មិនមានវេទនា





មិនមានសញ្ញា មិនមានសង្ខារ មិនមានវិញ្ញាណឬ ។ មិនដូច្នោះទេ អាវុសោ ។ ម្នាលអាវុសោយមកៈ ក្នុងស្ថាននេះ ក្នុងបច្ចុប្បន្ននេះឯង លោករកសត្វ ដោយពិតដោយប្រាកដ មិនបាន គួរឬ ការព្យាកររបស់លោកនោះ ថាអញយល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគសម្តែងហើយថា ភិក្ខុជាខីណាស្រព តែទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងដាច់សូន្យបាត់ទៅ មិនកើតទៀត ។ ម្នាលអាវុសោសារីបុត្ត កាលពីដើម ខ្ញុំមិនដឹងថា ទិដ្ឋិរបស់ខ្ញុំនោះ ជាទិដ្ឋិអាក្រក់ ឥឡូវនេះ ខ្ញុំលះបង់ទិដ្ឋិអាក្រក់នោះហើយ ព្រោះបានស្តាប់ធម្មទេសនារបស់ព្រះសារីបុត្តមានអាយុនេះ មួយទៀត ខ្ញុំក៏បានសម្រេចធម៌វិសេសហើយ ។

ម្នាលអាវុសោយមកៈ បើជនទាំងឡាយសួរលោកយ៉ាងនេះថា ម្នាលអាវុសោយមកៈ ភិក្ខុណាជាអរហន្តខីណាស្រព ភិក្ខុនោះទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅនឹងកើតទៀតឬ ម្នាលអាវុសោយមកៈ កាលបើគេសួរយ៉ាងនេះ លោកគប្បីព្យាករ (ឆ្លើយ ) ដូចម្តេចទៅ ។ ម្នាលអាវុសោ បើគេសួរខ្ញុំយ៉ាងនេះថា ម្នាលអាវុសោយមកៈ ភិក្ខុណាជាអរហន្តខីណាស្រព ភិក្ខុនោះ លុះទម្លាយកាយហើយ ខាងមុខអំពីសេចក្តីស្លាប់ទៅ នឹងកើតទៀតឬ ម្នាលអាវុសោ កាលបើគេសួរយ៉ាងនេះហើយ ខ្ញុំគប្បីព្យាករយ៉ាង

នេះថា ម្នាលអាវុសោ រូបមិនទៀងទេ រូបណា មិនទៀង រូបនោះ ជាទុក្ខ រូបណា ជាទុក្ខ រូបនោះរលត់ទៅ ដល់នូវសេចក្តីវិនាស ទៅ ។ វេទនា ។ សញ្ញា ។ សង្ខារទាំងឡាយ ។ វិញ្ញាណ មិនទៀងទេ វិញ្ញាណណាមិនទៀង វិញ្ញាណនោះជាទុក្ខ វិញ្ញាណ ណាជាទុក្ខ វិញ្ញាណនោះរលត់ទៅ ដល់នូវសេចក្តីវិនាសទៅ ម្នាល អាវុសោ កាលបើគេសួរយ៉ាងនេះ ខ្ញុំគប្បីព្យាករយ៉ាងនេះឯង ។

ម្នាលអាវុសោយមកៈ ប្រពៃហើយ ប្រពៃហើយ ។ល។





## ព្រះអរហន្តអស់ជីវិតដូចភ្លើងរលត់

ក្នុងបិដកលេខ ២៤ ទំព័រ ១៦ នៅក្នុង **អគ្គិវច្ឆគោត្តសូត្រ** ក្នុងចំណែកពាក់កណ្តាលចុងក្រោយនៃព្រះសូត្រ ។ យើងគួរសិក្សា ប្រកបផ្សំនឹង **យមកសូត្រ** ដើម្បីបានយល់ដឹងនូវព្រះពុទ្ធសាសនា កាន់តែប្រសើរឡើង :

បពិត្រព្រះគោតមដ៏ចម្រើន ចុះភិក្ខុដែលមានចិត្តរួចស្រឡះ ហើយយ៉ាងនេះ នឹងកើតទៀតក្នុងទីណា ។ ម្នាលវច្ឆៈ ពាក្យថា កើតទៀត ដូច្នេះមិនគួរទេ ។ បពិត្រព្រះគោតមដ៏ចម្រើន បើ ដូច្នោះមានតែមិនកើតទៀតទេឬ ។ ម្នាលវច្ឆៈ ពាក្យថា មិនកើត ទៀតដូច្នេះ ក៏មិនគួរ ។ បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះ មានតែកើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះឬ ។ ម្នាលវច្ឆៈ ពាក្យ ថា កើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះក៏មិនគួរ ។ បពិត្រ ព្រះគោតមដ៏ចម្រើន បើដូច្នោះមានតែកើតទៀតក៏មិនមែន មិន កើតទៀតក៏មិនមែនដូច្នេះឬ ។ ម្នាលវច្ឆៈ ពាក្យថា កើតទៀតក៏មិន មែន មិនកើតទៀតក៏មិនមែន ដូច្នេះក៏មិនគួរ ។

កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន ចុះភិក្ខុដែលមានចិត្តរួចស្រឡះហើយយ៉ាងនេះ នឹងកើតទៀតក្នុងទីណា ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថាកើតទៀតដូច្នេះមិនគួរទេ ។ កាលខ្ញុំទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះមានតែមិនកើតទៀតទេឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថា មិនកើតទៀតដូច្នេះ ក៏មិនគួរ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះមានតែកើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថា កើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះក៏មិនគួរ ។ កាលខ្ញុំសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះមានតែកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថា កើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែនដូច្នេះក៏មិនគួរ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គដល់នូវសេចក្តីមិនដឹងក្នុងដំណើរនេះ ដល់នូវសេចក្តីងេងងោង ក្នុងដំណើរនេះ សូម្បីតែសេចក្តីជ្រះថ្លារបស់ខ្ញុំ ដែលបានមានហើយ ព្រោះវាចាដែលព្រះគោតមដ៏ចម្រើនត្រាស់ពីខាងដើម ឥឡូវនេះបាត់ទៅអស់ហើយ ។

ម្នាលវច្ឆៈ គួរតែអ្នកមិនដឹង គួរតែអ្នកងេងងោង ម្នាលវច្ឆៈ ព្រោះធម៌នេះជាធម៌ដ៏ជ្រៅ ជាធម៌ដែលបុគ្គលឃើញបានដោយ





កម្រ ជាធម៌ត្រាស់ដឹងបានដោយកម្រ ជាធម៌ដ៏ស្ងប់រម្ងាប់ ជាធម៌ថ្លៃថ្លា មិនជាទីត្រាច់ចុះនៃវិតក្កបាន ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ធម៌នោះខ្លួនអ្នកដែលមានទិដ្ឋិដទៃ មានសេចក្តីពេញចិត្តដទៃ មានសេចក្តីគាប់ចិត្តដទៃ មានសេចក្តីព្យាយាមក្នុងទីដទៃ មានអាចារ្យក្នុងទីដទៃ រមែងដឹងបានដោយកម្រ ។ ម្នាលវច្ឆៈ បើដូច្នោះ តថាគតនឹងត្រឡប់សួរអ្នកក្នុងដំណើរនេះវិញ ដំណើរនោះគួរដល់អ្នកយ៉ាងណា អ្នកគប្បីដោះស្រាយនូវដំណើរនោះយ៉ាងនោះចុះ ម្នាលវច្ឆៈ អ្នកសំគាល់នូវដំណើរនោះដូចម្តេច បើភ្លើងឆេះក្នុងទីចំពោះមុខអ្នក អ្នកគប្បីដឹងថា ភ្លើងនេះឆេះក្នុងទីចំពោះមុខអាត្មាអញដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន បើភ្លើងឆេះក្នុងទីចំពោះមុខខ្ញុំ ខ្ញុំគប្បីដឹងថា ភ្លើងនេះឆេះ ក្នុងទីចំពោះមុខអាត្មាអញ ។ ម្នាលវច្ឆៈ បើគេសួរអ្នកយ៉ាងនេះ ថាភ្លើងណាឆេះ ក្នុងទីចំពោះមុខអ្នក ភ្លើងនេះឆេះ ព្រោះអាស្រ័យអ្វី ម្នាលវច្ឆៈ បើគេសួរយ៉ាងនេះ អ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះគោតមដ៏ចម្រើន បើគេសួរខ្ញុំយ៉ាងនេះថា ភ្លើងណាឆេះក្នុងទីចំពោះមុខអ្នក ភ្លើងនេះឆេះព្រោះអាស្រ័យអ្វី បពិត្រព្រះគោតមដ៏ចម្រើន បើគេសួរយ៉ាងនេះ ខ្ញុំគប្បីដោះស្រាយយ៉ាងនេះថា ភ្លើងណាឆេះក្នុងទីចំពោះមុខខ្ញុំ ភ្លើងនេះឆេះឡើង ព្រោះ

អាស្រ័យនូវកំញមគឺស្មៅនិងអុស ។ ម្នាលវច្ឆៈ បើភ្លើងនោះរលត់ទៅក្នុងទីចំពោះមុខ (អ្នក ) អ្នកគប្បីដឹងថា ភ្លើងនេះរលត់ហើយក្នុងទីចំពោះមុខអាត្មាអញដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន បើភ្លើងនោះរលត់ទៅក្នុងទីចំពោះមុខខ្ញុំ ខ្ញុំគប្បីដឹងថា ភ្លើងនេះរលត់ហើយ ក្នុងទីចំពោះមុខអាត្មាអញ ។ ម្នាលវច្ឆៈ ចុះបើគេសួរយ៉ាងនេះថា ភ្លើងណា ដែលរលត់ហើយក្នុងទីចំពោះមុខអ្នក ភ្លើងនោះទៅអំពីនេះទៅហើយ ទៅកាន់ទិសណា ខាងកើតឬខាងលិចខាងជើងឬខាងត្បូង ម្នាលវច្ឆៈ បើគេសួរយ៉ាងនេះតើអ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រព្រះគោតមដ៏ចម្រើន មិនគួរនឹងដោះស្រាយបានទេ បពិត្រព្រះគោតមដ៏ចម្រើន ដ្បិតថាភ្លើងនោះ ឆេះព្រោះអាស្រ័យនូវកំញមគឺស្មៅនិងអុសណា ដល់នូវកិរិយារាប់ថារលត់ទៅមិនមានអាហារដូច្នេះ ព្រោះអស់ទៅនៃកំញមគឺស្មៅនិងអុសនោះផង ព្រោះមិនមានកិរិយានាំចូលទៅជិតនូវវត្ថុដទៃផង ។

ម្នាលវច្ឆៈ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយរូបណា រូបនោះតថាគត លះបង់ហើយ កាត់ឫសចោលហើយ ធ្វើឱ្យដូចជាត្នោតកំបុតកហើយ ដល់នូវកិរិយាមិនមាន ជារូបមានកិរិយាមិនកើតឡើងតទៅទៀតជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយចាកចំណែកនៃរូប ជាអ្នកជ្រៅ (ដោយគុណ )មានប្រមាណ





មិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រដូចមហាសមុទ្រអ៊ីចឹងឯង នឹងថា កើតទៀតក៏មិនគួរ ថាមិនកើតទៀតទេក៏មិនគួរ ថាកើតទៀតខ្លះមិនកើតទៀតខ្លះក៏មិនគួរ ថាកើតទៀតក៏មិនមែនមិនកើតទៀតក៏មិនមែនក៏មិនគួរ ។ បុគ្គលកាលបញ្ញត្តនូវសត្វគប្បីបញ្ញត្តដោយវេទនាណា វេទនានោះតថាគត លះបង់ហើយកាត់ឫសចោលហើយ ធ្វើឱ្យដូចជាត្នោតកំបុតកហើយ ដល់នូវកិរិយាមិនមាន ជាវេទនាមានកិរិយា មិនកើតទៀតតទៅជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយ ចាកចំណែកនៃវេទនា ជាអ្នកជ្រៅមានប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រដូចមហាសមុទ្រ នឹងថា កើតទៀតក៏មិនគួរ ថាមិនកើតទៀតក៏មិនគួរ ថាកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មិនគួរ ថាកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មិនគួរ ។ បុគ្គលកាលបញ្ញត្តនូវសត្វគប្បីបញ្ញត្តដោយសញ្ញាណា សញ្ញានោះតថាគត លះបង់ហើយកាត់ឫសចោលហើយ ធ្វើឱ្យដូចជាត្នោតកំបុតកហើយ ដល់នូវកិរិយាមិនមាន ជាសញ្ញាមានកិរិយា មិនកើតទៀតតទៅជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយ ចាកចំណែកនៃសញ្ញា ជាអ្នកជ្រៅមានប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រដូចមហាសមុទ្រ នឹងថា កើតទៀតក៏មិនគួរ ថាមិនកើតទៀតក៏មិន

គួរ ថាកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មិនគួរ ថាកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មិនគួរ ។ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយសង្ខារទាំងឡាយណា សង្ខារទាំងឡាយនោះ តថាគតលះបង់ហើយ កាត់ឫសចោលហើយ ធ្វើឱ្យដូចជាត្នោតកំបុតកហើយ ដល់នូវកិរិយាមិនមាន ជាសង្ខារមានកិរិយាមិនកើតទៀតតទៅជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយ ចាកចំណែកនៃសង្ខារ ជាអ្នកជ្រៅមានប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រ ដូចមហាសមុទ្រ នឹងថា កើតទៀតក៏មិនគួរ ថាមិនកើតទៀតក៏មិនគួរ ថាកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មិនគួរ ថាកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មិនគួរ ។ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយវិញ្ញាណណា វិញ្ញាណនោះ តថាគតលះបង់ហើយ កាត់ឫសចោលហើយ ធ្វើឱ្យដូចជាត្នោតកំបុតកហើយ ដល់នូវកិរិយាមិនមាន ជាវិញ្ញាណមានកិរិយាមិនកើតទៀតតទៅជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយ ចាកចំណែកនៃវិញ្ញាណ ជាអ្នកជ្រៅមានប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រ ដូចមហាសមុទ្រ នឹងថា កើតទៀតក៏មិនគួរ ថាមិនកើតទៀតក៏មិនគួរ ថាកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មិនគួរ ថាកើតទៀតក៏មិនមែន មិនកើត





ទៀតក៏មិនមែនក៏មិនគួរ ។

លុះព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ វច្ឆគោត្ត-បរិព្វាជក ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ដើមរាំងភ្នំធំ (ដុះនៅ) ក្នុងទីជិតនៃស្រុកក្តី និគមក្តី មែកនិងស្លឹកនៃដើមរាំងភ្នំធំនោះ ក៏វិនាសទៅដោយភាវៈមិនទៀង សំបកនិងក្រមរទាំងឡាយវិនាសទៅ ស្រាយក៏វិនាសទៅ សម័យខាងក្រោយមក ដើមរាំងភ្នំធំនោះ ក៏ប្រាសចាកមែកនិងស្លឹក ប្រាសចាកសំបកនិងក្រមរ ប្រាសចាកស្រាយឋិតនៅតែខ្លឹមដ៏ស្អាត យ៉ាងណាមិញ ឯពាក្យជាប្រធាន (ធម្មវិន័យ) របស់ព្រះគោតមដ៏ចម្រើន ក៏ប្រាសចាកមែកនិងស្លឹក ប្រាសចាកសំបកនិងក្រមរ ប្រាសចាកស្រាយ ឋិតនៅចំពោះខ្លឹមដ៏ស្អាតយ៉ាងនោះដែរ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់ប្រកាសហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចជាបុគ្គលផ្ងារឡើងនូវវត្ថុដែលផ្កាប់ ឬបើកនូវវត្ថុដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់មនុស្សវង្វេងផ្លូវ ពុំនោះសោតដូចគេទ្រោលប្រទីបក្នុងទីងងឹតដោយគិតថា មនុស្សអ្នកមានភ្នែក (ភ្លឺ) រមែងបានឃើញរូបទាំងឡាយដូច្នោះដែរ ខ្ញុំព្រះអង្គសូមដល់

នូវព្រះគោតមមានព្រះភាគព្រមទាំងព្រះធម៌ ទាំងព្រះភិក្ខុសង្ឃជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមរៀងទៅ ។

នៅក្នុង**មហាវច្ឆគោត្តសូត្រ** វច្ឆគោត្តបរិព្វាជក បានទូលសួរព្រះអង្គអំពីកុសលធម៌ និងអកុសលធម៌ ។ ក្រោយមកបានឧបសម្បទាក្នុងព្រះពុទ្ធសាសនា ហើយក៏បានជាព្រះអរហន្តមួយអង្គ សម្រេចនូវវិជ្ជា ៣ ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន។

ក្នុងបិដកលេខ ៣៦ ទំព័រ ៤៣២ នៅក្នុង**កុតូហលសាលា-សូត្រ** មានព្រះពុទ្ធដីកាដែលគួរសិក្សាបន្ថែម ព្រះអង្គទ្រង់ត្រាស់សម្តែងថា :

ម្នាលវច្ឆៈ តថាគតបញ្ញត្តនូវកំណើតនៃសត្វដែលមានឧបា-ទាន មិនបញ្ញត្តនូវកំណើតនៃសត្វ ដែលមិនមានឧបាទានឡើយ (មានឧបាទានទើបកើត មិនមានឧបាទានរមែងមិនកើត ) ។ ម្នាលវច្ឆៈ ដូចភ្លើងដែលមានគ្រឿងសម្រាប់ឱ្យឆេះ ក៏ឆេះភ្លឺរុងរឿង មិនមានគ្រឿងសម្រាប់ឱ្យឆេះទេ ក៏មិនឆេះទៅហ្នឹងឯង ។

បិដកលេខ ៥៤ ទំព័រ ៧៧ នៅក្នុង **រតនសូត្រ** ក៏មានសម្តែងអំពីព្រះអរហន្តអស់ជីវិតទៅដូចប្រទីបរលត់ដែរ ។ ព្រះអង្គ





ទ្រង់ត្រាស់សម្តែងថា :

**ខីណំ បុរាណំ នវំ នត្ថិ សម្ភវំ**
**វិរត្តចិត្តាយតិកេ ភវស្មឹ**
**តេ ខីណពីជា អវិរុឡ្ហិឆន្ទា**
**និព្វន្តិ ធីរា យថាយម្បទីបោ ។**

កម្មចាស់អស់ហើយ កម្មថ្មីរមែងមិនកើតប្រាកដ អរិយ-បុគ្គលទាំងឡាយណា មានចិត្តនឿយណាយក្នុងភពតទៅ អរិយ-បុគ្គលទាំងនោះ មានពូជអស់ហើយ មានឆន្ទៈ គឺសេចក្តីប៉ុនប៉ងក្នុងចិត្តមិនដុះឡើងឡើយ ជាអ្នកមានប្រាជ្ញា តែងរលត់ទៅ ដូចជាប្រទីប (ដែលរលត់ដូច្នោះឯង ) ។

ក្នុងបិដកលេខ ៥២ ទំព័រ ៣៥២ នៅក្នុង **បឋមទព្វសូត្រ** ព្រះអង្គទ្រង់ឧទាន ប្រារព្ធចំពោះការបរិនិព្វានរបស់ព្រះទព្វមល្ល-បុត្តត្ថេរថា :

**អភេទិ កាយោ និរោធិ សញ្ញា វេទនាសីតិភវឹសុ សព្វា**
**វូបសមឹសុ សង្ខារា វិញ្ញាណំ អត្ថមាគមាតិ។**

រូបកាយ (របស់ទព្វមល្លបុត្ត ) បែកធ្លាយហើយ សញ្ញាក៏រលត់ វេទនាទាំងអស់ក៏ត្រជាក់ សង្ខារទាំងឡាយក៏ស្ងប់រម្ងាប់ វិញ្ញាណក៏ដល់នូវការតាំងនៅមិនបានដែរ ។

ក្នុងបិដកលេខ ៥២ ទំព័រ ៣៥៣ នៅក្នុង **ទុតិយទព្វសូត្រ** ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលទព្វមល្លបុត្ត ហោះទៅឯអាកាស អង្គុយពែនភ្នែនក្នុងអាកាសដ៏ស្រឡះ ចូលកាន់តេជោធាតុ ចេញហើយបរិនិព្វាន សរីរៈក៏ត្រូវភ្លើងឆាបឆេះ ទាំងផេះក៏មិនប្រាកដ ទាំងកម្ទេចធាតុក៏មិនប្រាកដ.. រួចហើយព្រះអង្គទ្រង់ឧទាន :

**អយោឃនហតស្សេវ ជលតោ ជាតវេទស្ស**
**អនុបុព្វូបសន្តស្ស យថា ន ញាយតេ គតិ**
**ឯវំ សម្មាវិមុត្តានំ កាមពន្ធោឃតារិនំ**
**បញ្ញាបេតុំ គតិ នត្ថិ បត្តានំ អចលំ សុខន្តិ** ។

បុគ្គលរមែងមិនដឹងនូវគតិ (ទីទៅ) របស់ភ្លើង ដែលឆេះនៅនឹងដុំដែក ដែលជាងដែកកំពុងដំ ហើយភ្លើងនោះក៏រលត់ទៅដោយលំដាប់ៗ យ៉ាងណាមិញ គតិរបស់ព្រះអរហន្ត អ្នករួចស្រឡះចាកកិលេសដោយប្រពៃ ជាអ្នកឆ្លងនូវអន្លង់ដែលមានកាមជាគ្រឿងចង ដល់នូវសេចក្តីសុខ មិនញាប់ញ័រ ក៏មិនមានបញ្ញត្តិយ៉ាងនោះដែរ ។





## ខន្ធ៥ បៀតបៀនសត្វលោក

ក្នុងបិដកលេខ ៣៤ ទំព័រ ៧១ **មារសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីបញ្ចក្ខន្ធដែលបៀតបៀនសត្វលោក ។ ពាក្យថា សត្វលោក គឺបញ្ញត្តចំពោះក្រសែនៃបញ្ចក្ខន្ធដែលមិនមានទីបំផុតពីខាងដើមមកហ្នឹងឯង ដូច្នេះបើពោលដោយបរមត្ថធម៌សុទ្ធ គឺ **ទុក្ខសច្ច** ។

* បញ្ចក្ខន្ធចងសត្វលោកឱ្យជាប់នឹងទុក្ខលំបាក ចងឱ្យជាប់នឹងការងារចិញ្ចឹមជីវិត។ល។ បញ្ចក្ខន្ធជាចំណងរបស់មច្ចុរាជ មានសេចក្តីទាំងស្រុងដូចតទៅ :

ក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរាធៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាធៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថា មារ មារ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា មារ តើដោយហេតុយ៉ាងណា ។

ម្នាលរាធៈ កាលបើរូបមាន សេចក្តីស្លាប់ក្តី សត្វដែលត្រូវគេសម្លាប់ក្តីក៏មានដែរ ឬសត្វណាតែងស្លាប់ (សត្វនោះក៏មានដែរ ) ម្នាលរាធៈ ហេតុដូច្នេះ អ្នកចូរឃើញនូវរូបថាជាមារ ឃើញថាជាសត្វដែលត្រូវគេសម្លាប់ ឃើញថា រមែងស្លាប់ ឃើញថាជារោគ ឃើញថាជាបូស ឃើញថាជាសរ ឃើញថាជាទុក្ខ ឃើញថាជារបស់មានទុក្ខ ពួកជនណា ឃើញនូវរូបនោះយ៉ាងនេះ ពួកជននោះ ឈ្មោះថាឃើញប្រពៃ ។ កាលបើវេទនាមាន ។ កាលបើសញ្ញាមាន ។ កាលបើសង្ខារទាំងឡាយមាន ។ កាលបើវិញ្ញាណមាន សេចក្តីស្លាប់ក្តី សត្វដែលត្រូវគេសម្លាប់ក្តី ក៏មានដែរឬ សត្វណាតែងស្លាប់ (សត្វនោះក៏មានដែរ ) ម្នាលរាធៈ ហេតុដូច្នោះ អ្នកចូរឃើញនូវវិញ្ញាណថាជាមារ ឃើញថា ជាសត្វដែលត្រូវគេសម្លាប់ ឃើញថារមែងស្លាប់ ឃើញថាជារោគ ឃើញថាជាបូស ឃើញថាជាសរ ឃើញថាជាទុក្ខ ឃើញថាជារបស់មានទុក្ខ ពួកជនណា ឃើញនូវវិញ្ញាណនោះយ៉ាងនេះ ពួកជននោះ ឈ្មោះថាឃើញប្រពៃ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការឃើញប្រពៃ តើមានប្រយោជន៍អ្វី ។ ម្នាលរាធៈ ការឃើញប្រពៃមានប្រយោជន៍ឱ្យកើតសេចក្តីនឿយណាយ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះសេចក្តីនឿយណាយ មានប្រយោជន៍អ្វី។ ម្នាលរាធៈ សេចក្តីនឿយណាយ





មានប្រយោជន៍ឱ្យកើតការប្រាសចាកតម្រេក ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការប្រាសចាកតម្រេក មានប្រយោជន៍អ្វី ។ ម្នាលរាធៈ ការប្រាសចាកតម្រេក មានប្រយោជន៍ ឱ្យកើតការផុតស្រឡះ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះការផុតស្រឡះ មានប្រយោជន៍អ្វី ។ ម្នាលរាធៈ ការផុតស្រឡះ មានប្រយោជន៍ឱ្យបានព្រះនិព្វាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះនិព្វាន មានអ្វីជាប្រយោជន៍ ។ ម្នាលរាធៈ អ្នកប្រព្រឹត្តកន្លង គឺសួរហួសបញ្ហា មិនអាចកាន់យកនូវទីបំផុតនៃបញ្ហាបានឡើយ ។ ម្នាលរាធៈ ព្រោះថា ការប្រព្រឹត្តនូវព្រហ្មចរិយៈ មានព្រះនិព្វានជាទីពឹង មានព្រះនិព្វានជាទីបំផុត ។

# សត្វលោកជាប់ក្នុងឧបាទានក្ខន្ធទុក្ខ

ក្នុងបិដកលេខ ៣៤ ទំព័រ ៧៣ **សត្តសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីការជាប់ជំពាក់របស់សត្វលោក ។ សត្វលោកកើតមកទាំងចំណង ចាស់ទាំងចំណង ស្លាប់ទាំងចំណង ទៅកាន់បរលោកក៏ទាំងចំណងដែរ ។ កិលេសបានចងសត្វលោកឱ្យជាប់នឹងទីកន្លែង ជាប់នឹងភព ជាប់នឹងឧបាទានក្ខន្ធ៥ ដែលឧបាទានក្ខន្ធ ៥ នេះជាប្រភពនៃបញ្ហាគ្រប់យ៉ាង ។

* ទ្រព្យសម្បត្តិពេញណែនក្នុងផ្ទះ និងនៅខាងក្រៅផ្ទះទៀត មិនមែនព្រោះមកពីមានឧបាទានក្ខន្ធ ៥ នេះទេឬ ? បើមិនមានឧបាទានក្ខន្ធ ៥ ទេ តើមានអ្វីដែលត្រូវការចាំបាច់នឹងស្វែងរកយកមកបរិភោគប្រើប្រាស់ តែព្រោះសត្វលោកត្រូវអវិជ្ជាបិទបាំង ទើបសត្វលោកបែរទៅជាត្រេកអរជាមួយនឹងអ្វីៗដែលបានមក ហើយប្រកាន់ឧបាទានក្ខន្ធ ៥ ថាជាតួខ្លួន ដោយមិនបានកំណត់ដឹងនូវឧបាទានក្ខន្ធ ៥ ថាជាទុក្ខឡើយ ។ សេចក្តីនៃសត្តសូត្រមានដូចតទៅ :

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន



របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរាធៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះរាធៈមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលហៅថាសត្វ សត្វ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា សត្វតើដោយហេតុដូចម្តេច ។ ម្នាលរាធៈ សេចក្តីពេញចិត្តណាសេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ក្នុងរូប បុគ្គលដែលជាប់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ ជំពាក់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ លោកហៅថា សត្វ។ សេចក្តីពេញចិត្តណា សេចក្តីត្រេកអរណា សេចក្តីរីករាយណា សេចក្តីប្រាថ្នាណា ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ក្នុងវិញ្ញាណ បុគ្គលដែលជាប់នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ ជំពាក់ នៅក្នុងសេចក្តីពេញចិត្តជាដើមនោះ លោកហៅថា សត្វ ។ ម្នាលរាធៈ ដូចពួកកុមារក្តី ពួកកុមារីក្តី នាំគ្នាលេងកូនផ្ទះធ្វើពីអាចម៍ដី មិនទាន់ប្រាសចាកសេចក្តីត្រេកអរ មិនទាន់ប្រាសចាកសេចក្តីពេញចិត្ត មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីឆ្អែឆ្អា

មិនទាន់ប្រាសចាកសេចក្តីប្រាថ្នា ក្នុងកូនផ្ទះធ្វើពីអាចម៍ដីទាំងនោះ កំណត់ត្រឹមណា តែងអាល័យ តែងប្រកាន់លេង តែងប្រកាន់ថាជាទ្រព្យ ប្រកាន់ថាជារបស់ខ្លួន ចំពោះកូនផ្ទះធ្វើពីអាចម៍ដី កំណត់ត្រឹមនោះ ម្នាលរាធៈ កាលណាបើពួកកុមារក្តី ពួកកុមារីក្តី លែងត្រេកអរ លែងពេញចិត្ត លែងស្រឡាញ់ លែងស្រេកឃ្លាន លែងឆ្អេឆ្អា លែងប្រាថ្នាក្នុងកូនផ្ទះធ្វើពីអាចម៍ដីទាំងនោះហើយ យកដៃនិងជើងទៅកម្ទាយចោល ឈ្ងួសចោល កម្ចាត់ចោល នូវកូនផ្ទះធ្វើពីអាចម៍ដីទាំងនោះ ធ្វើឱ្យជារបស់លេងមិនកើតក្នុងកាលនោះយ៉ាងណាមិញ ។ ម្នាលរាធៈ អ្នកទាំងឡាយ ចូរកម្ទាយចោល ឈ្ងួសចោល កម្ចាត់ចោល នូវរូប ចូរធ្វើឱ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីអស់ទៅនៃតណ្ហា ចូរកម្ទាយចោល ឈ្ងួសចោល កម្ចាត់ចោលនូវវេទនា ចូរធ្វើឱ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីអស់ទៅនៃតណ្ហា ។ ចូរកម្ទាយចោល ឈ្ងួសចោល កម្ចាត់ចោលនូវសញ្ញា ។ នូវសង្ខារទាំងឡាយ ចូរធ្វើឱ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីអស់ទៅនៃតណ្ហា ចូរកម្ទាយចោល ឈ្ងួសចោល កម្ចាត់ចោល នូវវិញ្ញាណ ចូរធ្វើឱ្យជារបស់លេងមិនកើត ចូរប្រតិបត្តិដើម្បីអស់ទៅនៃតណ្ហា យ៉ាងនោះឯង ។ ម្នាលរាធៈ ព្រោះថា ការអស់ទៅនៃតណ្ហា ឈ្មោះថាព្រះនិព្វាន ។





# ជីវិតសត្វលោកជាប់ចំណងកម្ម

* បើមើលដោយល្ងង់ខ្លៅ រមែងឃើញសត្វលោកមានឥស្សរៈសេរីភាព នឹងនៅកន្លែងណា នឹងធ្វើអ្វី ក៏ចេះតែបានទាំងអស់ ។

* ក្នុងវិន័យរបស់ព្រះអរិយៈ គឺទៅតាមការកំណត់ដឹងដោយបញ្ញារបស់ព្រះអរិយបុគ្គល បានកំណត់ថា គ្រប់ជីវិតមិនមានឥស្សរភាពឡើយ ព្រោះបញ្ចក្ខន្ធ ព្រោះកិលេស និងព្រោះកម្ម សត្វលោករមែងជាប់ចំណង ។

* បញ្ចក្ខន្ធ ដែលជាភារៈដ៏ធ្ងន់នេះឯង ជាតួហេតុសំខាន់ ចងសត្វលោកឱ្យជាប់នឹងការងារចិញ្ចឹមជីវិត ជាប់នឹងទ្រព្យសម្បត្តិ ធ្វើឱ្យមិនមានសេរីភាព មានតែរវល់នឹងការថែរក្សាបញ្ចក្ខន្ធដែលជាភារៈដ៏ធ្ងន់នេះរហូត ។

* កិលេស មានតណ្ហា មានះ ទិដ្ឋិជាដើម របស់សត្វលោកខ្លួនឯង ក៏រមែងចងខ្លួនឯងឱ្យជាប់នឹងការកើត ចាស់ ឈឺ ស្លាប់ ដដែលៗក្នុងវដ្តសង្សារ ជាប់នឹងទុក្ខលំបាក ជាប់នឹងបញ្ហា ជាប់នឹងការភ័យខ្លាចសព្វបែបសព្វយ៉ាង ។

* កម្មជាកុសល និងអកុសល ក៏ជារបស់សត្វលោកខ្លួនឯងដែរ រមែងជាបច្ច័យញ៉ាំងសត្វ ឱ្យជាប់ចំណងនៅក្នុងភពផ្សេង ៗ សូម្បីស្ថានសួគ៌ និងរូបព្រហ្ម អរូបព្រហ្មក៏ជាទីឃុំឃាំងដាក់សត្វលោកដែរ ។ កាលបើនៅជាបុថុជ្ជនហើយ ក៏រមែងត្រូវទ្រុងអវិជ្ជាឃាំងជាប់ អស់បុណ្យពេលណា ក៏ត្រូវត្រឡប់មកទទួលបញ្ហា ដូចជាមនុស្សយើងសព្វថ្ងៃដដែលទៀត ។

* មនុស្សយើងដែលនៅមានកិលេស រមែងជាប់នឹងទីកន្លែងផ្ទះសម្បែង ទោះជាលំនៅឋានតូចធំ ក្នុងក្រុង ឬជនបទណា ៗ គឺសុទ្ធតែជាទីឃុំឃាំងទាំងអស់ សត្វលោកត្រូវជាប់ចំណងក្នុងស្ថានទីនោះ ៗ រហូតដល់អស់ជីវិត (ជាប់គុកមួយជីវិត) សូម្បីចេញពីភពមួយ ត្រូវទៅកាន់ភពមួយទៀត គឺត្រូវទៅទាំងចំណង ។

ក្នុងបិដកលេខ ៣៤ ទំព័រ ១៧ **ពន្ធនសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីចំណងមានទាំងស្រុងដូចតទៅ :

ក្រុងសាវត្ថី ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ ។ល។ មិនបានសិក្សាក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ នូវខ្លួនថាមានរូបខ្លះ នូវរូបថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងរូបខ្លះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុថុជ្ជនអ្នកមិនចេះដឹង





ជាប់ដោយចំណងគឺរូប ជាប់ដោយចំណងទាំងខាងក្នុង ទាំងខាងក្រៅ ជាអ្នកមិនឃើញនូវឆ្នេរគឺវដ្តៈ មិនឃើញនូវត្រើយគឺព្រះនិព្វាន រមែងចាស់ទាំងជាប់ចំណង ស្លាប់ទាំងជាប់ចំណង ចេញចាកលោកនេះទៅកាន់លោកខាងមុខ ទាំងជាប់ចំណង ។ ពិចារណាឃើញនូវវេទនាថាជាខ្លួនខ្លះ ។ល។ នូវខ្លួនថាមានក្នុងវេទនាខ្លះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុថុជ្ជនអ្នកមិនចេះដឹង ជាប់ដោយចំណង គឺវេទនា ជាប់ដោយចំណងទាំងខាងក្នុង ទាំងខាងក្រៅ មិនឃើញនូវឆ្នេរ មិនឃើញនូវត្រើយ រមែងចាស់ទាំងជាប់ចំណង ស្លាប់ទាំងជាប់ចំណង ចេញចាកលោកនេះ ទៅកាន់លោកខាងមុខ ទាំងជាប់ចំណង ។ ពិចារណាឃើញនូវសញ្ញា ។ នូវសង្ខារទាំងឡាយ ។ នូវវិញ្ញាណថាជាខ្លួន ។ល។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុថុជ្ជនអ្នកមិនចេះដឹង ជាប់ដោយចំណងគឺវិញ្ញាណ ជាប់ដោយចំណងទាំងខាងក្នុង ទាំងខាងក្រៅ មិនឃើញនូវឆ្នេរ មិនឃើញនូវត្រើយ រមែងចាស់ទាំងចំណង ស្លាប់ទាំងចំណង ចេញចាកលោកនេះទៅកាន់លោកខាងមុខទាំងជាប់ចំណង ។

ម្នាលភិក្ខុទាំងឡាយ ចំណែកខាងអរិយសាវ័កជាអ្នកចេះដឹង បានឃើញពួកព្រះអរិយៈ ។ល។ បានសិក្សាក្នុងធម៌របស់សប្បុរស

មិនពិចារណាឃើញនូវរូបថាជាខ្លួនខ្លះ នូវខ្លួនថាមានរូបខ្លះ នូវរូបថាមានក្នុងខ្លួនខ្លះ នូវខ្លួនថាមានក្នុងរូបខ្លះឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អរិយសាវក័អ្នកចេះដឹង មិនជាប់ដោយចំណងគឺរូប មិនជាប់ដោយចំណងទាំងខាងក្នុង ទាំងខាងក្រៅ ឃើញនូវឆ្នេរ ឃើញនូវត្រើយ តថាគតពោលថា អរិយសាវក័នោះផុតស្រឡះចាកទុក្ខ ។ល។ មិនពិចារណា ឃើញនូវសញ្ញា ។ មិនពិចារណាឃើញនូវសង្ខារទាំងឡាយ ។ មិនពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន ។ល។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អរិយ-សាវក័អ្នកចេះដឹង មិនជាប់ដោយចំណង គឺវិញ្ញាណ មិនជាប់ដោយចំណងទាំងខាងក្នុង ទាំងខាងក្រៅ ឃើញនូវឆ្នេរ ឃើញនូវត្រើយ តថាគតពោលថា អរិយសាវក័នោះផុតស្រឡះចាកទុក្ខ ។

ក្នុងបិដកលេខ ៥៦ ទំព័រ ១៦២ **សមិតិគុត្តត្ថេរគាថា** ព្រះ-សមិតិគុត្តៈ បានពោលអំពីការកាត់ចំណងកម្ម ។ នៅក្នុងអដ្ឋកថាបានសម្តែងប្រវត្តិរបស់លោកដូចតទៅ :

ព្រះសមិតិគុត្តៈមានអធិការបានធ្វើទុកហើយក្នុងព្រះពុទ្ធអង្គមុន១ សន្សំបុណ្យទុកក្នុងភពនោះ១ បានយ៉ាងច្រើន ។ ក្នុងសម័យកាលនៃព្រះវិបស្សីសម្មាសម្ពុទ្ធ បានបូជាផ្កាម្លិះដល់ព្រះដ៏មានព្រះ-ភាគដោយចិត្តជ្រះថ្លា ។



ដោយបុញ្ញកម្មនោះ លោកកើតនៅក្នុងភពណា១ ក៏បានតាំងនៅក្នុងឋានៈ ដែលមានកុលសម្បត្តិ រូបសម្បត្តិ និងបរិវារ-សម្បត្តិ លើអ្នកដទៃនៅក្នុងភពនោះ១ ទាំងធ្លាប់បានធ្វើជាស្តេចចក្រពត្តិ ៣៤ ជាតិទៀតផង ។

នៅក្នុងអត្តភាពមួយ ក្នុងកាលណោះ លោកបានឃើញព្រះបច្ចេកពុទ្ធមួយអង្គនិមន្តបិណ្ឌបាត លោកបានគិតថា សមណៈត្រងោលរូបនេះ ប្រាកដជាកើតរោគឃ្លង់ហើយ បានជាសមណៈរូបនេះ យកសំពត់មកឃ្លុំខ្លួនដូច្នេះ រួចហើយបានស្តោះទឹកមាត់ដាក់ព្រះបច្ចេកពុទ្ធ ហើយក៏ដើរចេញទៅ ។

ដោយបាបកម្មនោះ លោកបានធ្លាក់ទៅឆេះក្នុងនរក អស់កាលដ៏យូរ ទើបបានត្រឡប់មកកើតក្នុងមនុស្សលោក ក្នុងកាលនៃការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធកស្សបទសពល ។ លោកបានបួសជាបរិព្វាជក បានឃើញឧបាសកម្នាក់ដែលសម្បូណ៏ទៅដោយសីលាចារវត្ត ហើយបានក្រោធខឹងនឹងឧបាសកនោះ ថែមទាំងបានជេរថា « អ្នកឯងជាមនុស្សកើតឃ្លង់ » ទៀតផង មិនត្រឹមតែប៉ុណ្ណោះ លោកបានវាយកម្ទេចនូវគ្រឿងសម្រាប់កក់ខ្លួនងូតទឹកដែលមនុស្សទាំងឡាយទុកនៅកំពង់ទឹកទៀតផងដែរ ។

ដោយកម្មនោះ លោកត្រូវកើតក្នុងនរកទៀត សោយទុក្ខ

អស់កាលយូរ ហើយបានមកកើតជាបុត្ររបស់ព្រាហ្មណ៍ម្នាក់ ក្នុងនគរសាវត្ថី នាសម័យពុទ្ធុប្បាទកាលនេះ លោកបាននាមថា **សមិតិគុត្តៈ** ។ លោកចម្រើនវ័យឡើង បានស្តាប់ព្រះធម៌ទេសនារបស់ព្រះបរមសាស្តា មានសទ្ធាជ្រះថ្លា បួសហើយជាភិក្ខុមានសីលបរិសុទ្ធហ្មត់ចត់ល្អ ។ ដោយបាបកម្មចាស់របស់លោកនៅមាន រោគឃ្លង់ក៏បានកើតឡើងក្នុងរូបរាងកាយរបស់លោក ។ រោគឃ្លង់នោះបានធ្វើឱ្យអវយវៈរាងកាយរបស់លោកបែកសាច់ជាដំបៅ មានទឹកពណ៌លឿងហូរចេញ ។ លោកបានស្នាក់នៅសាលាសម្រាប់ភិក្ខុអាពាធ ។

ថ្ងៃមួយ **ព្រះធម្មសេនាបតី** បាននិមន្តទៅសួរអំពីអាពាធនៃភិក្ខុទាំងឡាយ ដែលមានអាពាធនៅទីសាលានោះ ឃើញភិក្ខុនោះហើយ ប្រាប់ព្រះកម្មដ្ឋានក្នុងវេទនានុបស្សនាថា «ម្នាលអាវុសោ ដរាបណា បញ្ចក្ខន្ធនៅតែប្រព្រឹត្តទៅ ក៏ត្រូវសោយទុក្ខទាំងពួងដរាបនោះ លុះតែបញ្ចក្ខន្ធមិនមាន ទើបទុក្ខអស់ទៅបាន » រួចហើយ **ព្រះធម្មសេនាបតី** ក៏និមន្តចេញទៅ ។ **ព្រះសមិតិគុត្តត្ថេរ** តាំងនៅក្នុងឱវាទនោះហើយ ចម្រើនវិបស្សនា បានសម្រេចនូវអភិញ្ញា ៦ ជាព្រះអរហន្ត ។

ព្រះសមិតិគុត្តត្ថេរ បានសម្រេចនូវអភិញ្ញា ៦ ហើយ ក៏បាន





រលឹកដល់បាបកម្មដែលខ្លួនបានធ្វើហើយក្នុងជាតិមុនៗ... លោកបានពោលនូវគាថាដូច្នេះថា :

**យំ មយា បកតំ បាបំ បុព្វេ អញ្ញាសុ ជាតិសុ**
**ឥធេវ តំ វេទនីយំ វត្ថុ អញ្ញំ ន វិជ្ជតីតិ ។**

អំពើលាមកណា ដែលខ្ញុំបានធ្វើហើយ ក្នុងជាតិទាំងឡាយដទៃៗ ក្នុងកាលមុន អំពើលាមកនោះ ខ្ញុំគប្បីទទួលត្រឹមតែជាតិនេះឯង វត្ថុដទៃមិនមានឡើយ ។

* ចាកការសិក្សារឿងរ៉ាវជីវិតដែលប្រព្រឹត្តទៅតាមកម្ម ជាប់ដោយចំណងកិលេស ក៏នាំមកនូវការគិតពិចារណាថា តាមតែការប្រកាន់ខ្លួនរបស់មនុស្សយើងម្នាក់ៗ សមតែថាមានអ្វីពិសេសខ្លាំងណាស់ តែការពិត កើតមកហើយត្រូវធ្វើការ ហើយបរិភោគ បន្ទាប់មកត្រូវមានកូន មានចៅ ហើយក៏ចាស់ ចាស់ហើយក៏ស្លាប់ ។ នេះឬដែលជាសារៈសំខាន់ខ្លាំងណាស់នៃជីវិតនោះ ទើបបានជាម្នាក់ៗ ប្រកាន់ហួងហែងខ្លួនឯងខ្លាំងម្ល៉េះ រហូតដល់ឈ្លោះទាស់ទែងគ្នាជាដើម ?

# អារម្មណ៍ជារបស់ខាងក្រៅ

នៅក្នុងបិដកលេខ ៥២ ទំព័រ ១២៦ **ពាហិយសូត្រ** ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីអារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម ដែលវិញ្ញាណបានដឹង ។

* តាមពិត អារម្មណ៍ជារបស់ខាងក្រៅ ឯវិញ្ញាណដែលដឹងអារម្មណ៍ ជាសភាវៈខាងក្នុង ។ វិញ្ញាណដឹងនូវអារម្មណ៍ហើយក៏រលត់ទៅ មិនត្រូវការអារម្មណ៍អ្វីណាឡើយ កាលណា ពុទ្ធបរិស័ទកំណត់ដឹងដូច្នេះ សេចក្តីសុខស្ងប់រមែងកើតឡើងនៅក្នុងចិត្ត ។

*ពុទ្ធបរិស័ទត្រូវកំណត់ដឹងអារម្មណ៍ខាងក្រៅឱ្យបានរឿយៗ កំណត់ទាល់តែបានដឹងច្បាស់ដោយខ្លួនឯងថា មិនចាំបាច់បាននូវអ្វីៗឡើយ អ្វីៗនោះសូមឱ្យនៅជារបស់ខាងក្រៅទៅតាមធម្មតាចុះ ព្រោះនៅក្នុងលោក ៦ មានលោកភ្នែកជាដើមនេះ មិនមានអ្វីត្រូវការអ្វីទេ មានតែកើតហើយរលត់ទៅវិញតែប៉ុណ្ណោះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងព្រះកម្មដ្ឋានដូចតទៅ :

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ





ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ។ សម័យនោះឯង ពាហិយទារុចីរិយបុរស (អ្នកស្លៀកដណ្តប់សំពត់សម្បកឈើឈ្មោះពាហិយៈ ) អាស្រ័យនៅទៀបឆ្នេរសមុទ្រឈ្មោះសុប្បារកៈ ជាអ្នកដែលគេធ្វើ សក្ការៈ គោរព រាប់អាន បូជា កោតក្រែង បាននូវចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ។ កាលពាហិយទារុចីរិយបុរស ពួនសម្ងំក្នុងទីស្ងាត់ ស្រាប់តែមានសេចក្តីត្រិះរិះកើតឡើងក្នុងចិត្តយ៉ាងនេះថា ពួកជនណាមួយក្នុងលោកជាព្រះអរហន្ត ឬសម្រេចអរហត្តមគ្គ បណ្តាអរហន្តទាំង-នោះ ខ្លួនអញក៏ជាអរហន្តមួយដែរ ។ លំដាប់នោះ ទេវតាដែលជាសាលោហិតអំពីដើមរបស់ពាហិយទារុចីរិយបុរស ជាអ្នកអនុគ្រោះប្រាថ្នាប្រយោជន៍ បានដឹងច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្តរបស់ពា-ហិយទារុចីរិយបុរសដោយចិត្ត បានចូលទៅរកពាហិយទារុចីរិយ-បុរស លុះចូលទៅដល់ហើយ ក៏និយាយនឹងពាហិយទារុចីរិយបុរសយ៉ាងនេះថា នែពាហិយៈអ្នកមិនមែនជាព្រះអរហន្តទេ ទាំងមិនទាន់សម្រេចអរហត្តទេ ខ្លួនអ្នកមិនមានបដិបទាដែលនាំឱ្យបានជាព្រះអរហន្ត ឬសម្រេចអរហត្តទេ ។ ពាហិយទារុចីរិយៈ សួរថាបើដូច្នោះក្នុងកាលឥឡូវនេះ ក្នុងលោកព្រមទាំងទេវលោក តើជនណា ជាអរហន្ត ឬបានសម្រេចអរហត្តមគ្គ មានដែរឬ ។ ទេវតា

ឆ្លើយថា ម្នាលពាហិយៈ មាន ខាងជនបទឯជើង មានក្រុងមួយឈ្មោះសាវត្ថី ឥឡូវនេះព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់គង់នៅក្នុងក្រុងសាវត្ថីនោះ ។ ម្នាលពាហិយៈ ព្រះមានព្រះភាគអង្គនោះឯង ជាព្រះអរហន្តផង ទ្រង់សម្តែងធម៌ ដើម្បីអរហត្តផង ។ លំដាប់នោះ ពាហិយទារុចីរិយបុរសដែលទេវតានោះធ្វើឱ្យតក់ស្លុត ក៏ស្រាប់តែគេចចេញអំពីឆ្នេរសមុទ្រឈ្មោះសុប្បារកៈក្នុងខណៈនោះភ្លាម ដោយការនៅតែក្នុងផ្លូវទាំងពួងអស់ ១ យប់ ក៏បានទៅដល់ព្រះមានព្រះភាគ ដែលកំពុងគង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

សម័យនោះ គាប់ចួនភិក្ខុច្រើនរូប កំពុងដើរចង្ក្រមក្នុងទីវាល ។ លំដាប់នោះ ពាហិយទារុចីរិយបុរស ក៏ឆៀងចូលទៅរកពួកភិក្ខុ លុះចូលទៅដល់ហើយ ក៏បានសួរភិក្ខុទាំងនោះដូច្នេះថា បពិត្រលោកដ៏ចម្រើនទាំងឡាយ ឥឡូវនេះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធគង់នៅទីណា យើងមានបំណងនឹងចូលទៅដើម្បីជួបព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ពួកភិក្ខុតបថា ម្នាលពាហិយៈ ព្រះមានព្រះភាគចូលកាន់ចន្លោះភូមិដើម្បីបិណ្ឌបាតទៅហើយ ។ លំដាប់នោះ ពាហិយទារុចីរិយបុរសក៏មានដំណើរម្នីម្នាចេញពីវត្តជេតពន ចូលទៅនគរសាវត្ថី បាន



ឃើញព្រះមានព្រះភាគ កំពុងនិមន្តបិណ្ឌបាត ក្នុងក្រុងសាវត្ថី ជាទីនាំមកនូវសេចក្តីជ្រះថ្លា គួរជ្រះថ្លា មានឥន្ទ្រិយស្ងប់ មានព្រះទ័យស្ងប់ ទ្រង់បានដល់នូវការហាត់ពត់ និងការស្ងប់រម្ងាប់ដ៏ឧត្តម ទ្រង់បានទូន្មាន គ្រប់គ្រង សង្រួមឥន្ទ្រិយ ជាពុទ្ធនាគ គឺជាព្រះពុទ្ធដ៏ប្រសើរ លុះឃើញហើយ ក៏ចូលទៅរកព្រះមានព្រះភាគ មានសិរ្សឱនចុះទៀបព្រះបាទ នៃព្រះមានព្រះភាគ ហើយអារាធនាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគសម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង ដល់ខ្ញុំព្រះអង្គឱ្យទាន ។

កាលពាហិយទារុចីរិយបុរស អារាធនា យ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពាហិយទារុចីរិយបុរស ដូច្នេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះជាកាលមិនគួរ ដ្បិតតថាគតចូលទៅកាន់ចន្លោះភូមិបិណ្ឌបាត ។ ពាហិយទារុចីរិយបុរស ទូលព្រះមានព្រះភាគ ជាគម្រប់ពីរដងយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយ របស់ព្រះមានព្រះភាគ ឬជីវិតន្តរាយរបស់ខ្ញុំព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះ-អង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ប្រោសខ្ញុំព្រះអង្គ

សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង ដល់ខ្ញុំព្រះអង្គឱ្យទាន ។ ព្រះមានព្រះភាគ បានត្រាស់នឹងទារុចីរិយបុរស អស់វារៈពីរដង ដូច្នេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះ ជាកាលមិនគួរ ដ្បិតតថាគត ចូលទៅកាន់ចន្លោះភូមិ បិណ្ឌបាតសិន ។ ពាហិយទារុចីរិយបុរស ទូលព្រះមានព្រះភាគ អស់វារៈ ៣ ដង យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយ របស់ព្រះមានព្រះភាគ ឬជីវិតន្តរាយ របស់ខ្ញុំព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង ដល់ខ្ញុំព្រះអង្គឱ្យទាន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា **តស្មាតិហ តេ ពាហិយ ឯវំ សិក្ខិតព្វំ** ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកត្រូវសិក្សា យ៉ាងនេះថា **ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ សុតេ សុតមត្តំ ភវិស្សតិ មុតេ មុតមត្តំ ភវិស្សតិ វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតីតិ** រូបារម្មណ៍ដែលឃើញហើយ គ្រាន់តែជារូបារម្មណ៍ដែលឃើញហើយ សទ្ទារម្មណ៍ដែលឮហើយ គ្រាន់តែជាសទ្ទារម្មណ៍ដែលឮហើយ គន្ធៈរសៈផោដ្ឋព្វារម្មណ៍ ដែលប៉ះពាល់ហើយ គ្រាន់តែ





ជាអារម្មណ៍ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ ដែលដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ដែលដឹងហើយ **ឯវញ្ហិ តេ ពាហិយ សិក្ខិតព្វំ** ម្នាលពាហិយៈ អ្នកគប្បីសិក្សាយ៉ាងនេះឯង ។ **យតោ ខោ តេ ពាហិយ ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ សុតេ សុតមត្តំ ភវិស្សតិ មុតេ មុតមត្តំ ភវិស្សតិ វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតិ** ម្នាលពាហិយៈ ក្នុងកាលណា រូបារម្មណ៍ដែលអ្នកឃើញហើយ គ្រាន់តែជារូបារម្មណ៍ ដែលឃើញហើយ សទ្ទារម្មណ៍ដែលអ្នកឮហើយ គ្រាន់តែជាសទ្ទារម្មណ៍ដែលឮហើយ គន្ធៈរសៈផោដ្ឋព្វារម្មណ៍ដែល អ្នកប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ ដែលដឹងហើយ **តតោ ត្វំ ពាហិយ នត្ថិ** ម្នាលពាហិយៈ ក្នុងកាលនោះ អ្នករមែងមិនមាន **យតោ ត្វំ ពាហិយ នេវត្ថិ** ម្នាលពាហិយៈ ក្នុងកាលណា អ្នករមែងមិនមាន **តតោ ត្វំ ពាហិយ នេវិធ ន ហុរំ ន ឧភយមន្តរេ** ម្នាលពាហិយៈ ក្នុងកាលនោះ អ្នករមែងមិនមានក្នុងលោកនេះ អ្នករមែងមិនមានក្នុងលោកខាងមុខ អ្នករមែងមិនមានក្នុងចន្លោះនៃលោកទាំងពីរ **ឯសេវន្តោ ទុក្ខស្សាតិ** នេះឯងជាទីបំផុតនៃទុក្ខ ។

គ្រានោះ ចិត្តនៃពាហិយទារុចីរិយបុរសបានផុតស្រឡះចាក

អាសវៈទាំងឡាយ ព្រោះមិនមានឧបាទាន ក្នុងខណៈនោះឯង ដោយធម្មទេសនាសង្ខេប របស់ព្រះមានព្រះភាគនេះ ។ លុះព្រះមានព្រះភាគទ្រង់ទូន្មាន ពាហិយទារុចីរិយបុរស ដោយឱវាទសង្ខេបនេះហើយ ស្តេចចៀសចេញទៅ ។

កាលដែលព្រះមានព្រះភាគ ស្តេចចេញផុតទៅមិនយូរប៉ុន្មាន មេគោមានកូនខ្ចី បុះផ្តួលពាហិយទារុចីរិយបុរស ឱ្យដាច់ចាកជីវិតទៅ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាច់បិណ្ឌបាតក្នុងនគរសាវត្ថី រួចត្រឡប់អំពីបិណ្ឌបាត វេលាខាងក្រោយភត្ត ចេញអំពីនគរជាមួយភិក្ខុច្រើនរូប បានទតឃើញពាហិយទារុចីរិយបុរសធ្វើមរណភាព លុះទតឃើញហើយ ទើបត្រាស់ប្រាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរយកសរីរៈពាហិយទារុចីរិយបុរស លើកដាក់លើគ្រែនាំទៅដុតផង ធ្វើស្តូបដល់សរីរៈនោះផង ម្នាលភិក្ខុទាំងឡាយ (ព្រោះថា ) សព្រហ្មចារីរបស់អ្នកទាំងឡាយ ធ្វើមរណភាពហើយ ។ ពួកភិក្ខុទាំងនោះទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយលើកសរីរៈពាហិយទារុចីរិយបុរស ដាក់លើគ្រែតូច នាំទៅរំលាយ ទាំងធ្វើស្តូបដល់សរីរៈនោះ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ





អង្គុយក្នុងទីសមគួរ ហើយបានទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សរីរៈពាហិយទារុចីរិយបុរស រំលាយហើយ ទាំងស្តូបសម្រាប់បញ្ចុះសរីរៈនោះក៏ធ្វើហើយ គតិរបស់គាត់ តើដូចម្តេច ដំណើរក្នុងលោកខាងមុខ តើដូចម្តេច ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាហិយទារុចីរិយបុរស ជាបណ្ឌិតបានប្រតិបត្តិធម៌គួរដល់ព្រះនិព្វានហើយ មិនបៀតបៀនតថាគតព្រោះហេតុសម្តែងធម៌ទេ ម្នាលភិក្ខុទាំងឡាយ ពាហិយទារុចីរិយ-បុរស បរិនិព្វានហើយ ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនុ៎ះហើយ ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា

**យត្ថ អាបោ ច បឋវី តេជោ វាយោ ន គាធតិ**
**ន តត្ថ សុក្កា ជោតន្តិ អាទិច្ចោ នប្បកាសតិ**
**ន តត្ថ ចន្ទិមា ភាតិ តមោ តត្ថ ន វិជ្ជតិ ។**
**យទា ច អត្តនាវេទិ មុនិ មោនេន ព្រាហ្មណោ**
**អថ រូបា អរូបា ច សុខទុក្ខា បមុច្ចតីតិ ។**

ទឹក ដី ភ្លើង ខ្យល់ រមែងមិនតាំងនៅក្នុងនិព្វានធាតុណាពួកផ្កាយមាននាមថា សុក្កៈ (មានពន្លឺ ) រមែងមិនភ្លឺ ទាំងព្រះ-អាទិត្យក៏មិនរុងរឿង ក្នុងនិព្វានធាតុនោះ ព្រះចន្ទក៏មិនមានពន្លឺក្នុងព្រះនិព្វានធាតុនោះ ទាំងងងឹតក៏មិនមាន ក្នុងនិព្វានធាតុនោះ

ដែរ ។ ព្រាហ្មណ៍មាននាមថាមុនី ព្រោះមោនប្បដិបត្តិ ដឹងច្បាស់នូវព្រះនិព្វានដោយខ្លួនឯង ក្នុងកាលណា រមែងរួចចាករូបផងអរូបផង សុខទុក្ខផង ក្នុងកាលនោះ ។

**ដំណឹងអនុមោទនា**

ចំនួនគម្ពីរព្រះត្រ័យបិដកដែលពុទ្ធបរិស័ទជូនមកសម្រាប់ធ្វើជាធម្មទាន
តម្កល់ទុកតាមវត្តនានា ចាប់ពី ព.ស.២៥៤៥ មកមានចំនួន ១៥៩ ចប់ ។
ចាប់ពីថ្ងៃ ១ រោច ខែអស្សុជ ព.ស.២៥៤៨ មកដល់
ថ្ងៃ ៧កើត ខែជេស្ឋ ព.ស.២៥៤៩ (រយៈពេល ៧ ខែ ២២ ថ្ងៃ)
ក្រៅអំពីពេលរៀននៅវត្តឧណ្ណាលោម និងវត្តសំពៅមាស
ខ្ញុំព្រះករុណា ខ្ញុំបាទ សម្តែងព្រះធម៌ទេសនាបាន ៤៤៥ បុណ្យ
បានប្រាក់បូជាព្រះធម៌ចំនួន ៣៤៦.៦៨០.០០០៛
(បីរយសែសិបប្រាំមួយលាន ប្រាំមួយរយប៉ែតសិបពាន់រៀល)
និង ១២.៣៤៨ ដុល្លារអាមេរិក
សរុបទាំងអស់ត្រូវជា ៩៩.០១៨ ដុល្លារអាមេរិក
ក្នុងនោះបានបន្ថែមប្រាក់បច្ច័យបួនចំនួន
៤៤.៦៦០.០០០ ៛ + ៧៣០ ដុល្លារអាមេរិក ។
ដោយឡែក ប្រាក់បច្ច័យបួន ចេញថ្លៃយានជំនិះព្រះសង្ឃ ដែលនិមន្តមក
រៀនព្រះធម៌ នៅវត្តឧណ្ណាលោម និងវត្តសំពៅមាស ក្នុងឆ្នាំនេះ អស់ចំនួន
៦.០៧៥ ដុល្លារអាមេរិក ។





# ព្រះពុទ្ធ

ព្រះសម្មាសម្ពុទ្ធ គឺជាបុគ្គល ដែលបានត្រាស់ដឹងនូវធម៌ (ធម្ម = ធម្មជាតិ) ស្រាវជ្រាវរាវរក ហើយបានជួបនូវផ្លូវទៅកាន់ទីមិនមានទុក្ខ (ឃើញការកើតឡើងនៃលោកនេះតាមហេតុ តាមបច្ច័យ) មានប្រាជ្ញារកទីបំផុតគ្មាន ។ បំពេញខ្លួនព្រះអង្គជាកល្យាណមិត្តអង្គដំបូង ទ្រង់ប្រៀនប្រដៅធម៌ ចង្អុលប្រាប់ផ្លូវដែលព្រះអង្គរកឃើញហើយនោះឱ្យដល់សត្វលោក ម្យ៉ាងទៀត ព្រះអង្គជាតួយ៉ាង ដែលសម្រាប់អះអាងដល់សមត្ថភាព និងសេចក្តីល្អដ៏ខ្ពង់ខ្ពស់ ដែលអាចហ្វឹកហាត់ឱ្យសម្រេចបានក្នុងភាពជាមនុស្ស ។

១.សេពគប់នឹងសប្បុរស = មានកល្យាណមិត្ត
= **ពុទ្ធំ សរណំ គច្ឆាមិ** (អង្គប្រកបខាងក្រៅ)។

២.ស្តាប់ធម៌សប្បុរស = បាននូវបរតោឃោសៈដែលល្អ
= **ធម្មំ សរណំ គច្ឆាមិ** (អង្គប្រកបខាងក្រៅ)។

៣.យោនិសោមនសិការ =ទទួលយកព្រះធម៌ដោយគោរព ដើម្បីរៀបចំដំណើរចូលទៅរកក្រុមសង្ឃ (អង្គប្រកបខាងក្នុង)។

៤_ធម្មានុធម្មប្បដិបត្តិ = ធ្វើដំណើរចូលទៅរកក្រុមសង្ឃ

= **សង្ឃំ សរណំ គច្ឆាមិ** (ចូលដល់ក្រុមសង្ឃ)។

* ទាំង ៤ នេះ ជាអង្គនាំឱ្យទៅដល់ផ្លូវសោតាបត្តិយង្គ: ។

ព្រះបច្ចេកពុទ្ធ និងព្រះអរហន្ត មានញាណគ្រាន់តែជាចំណែកខ្លះប៉ុណ្ណោះ រមែងដឹងច្បាស់ដោយប្រពៃក្នុងវិស័យរបស់ខ្លួន ឯចំណែកក្នុងអារម្មណ៍ ដែលមិនមែនជាវិស័យ ក៏ដូចជាចូលទៅក្នុងទីងងឹតដូច្នោះឯង ។

ព្រះសម្មាសម្ពុទ្ធ ពុំមានធម៌អ្វីណា ដែលព្រះអង្គមិនបានជ្រាប មិនបានដឹងនោះឡើយ ។ ព្រះអង្គទ្រង់ឃើញធម៌ ដែលប្រព្រឹត្តទៅនៅក្នុងកាលទាំង ៣ និងផុតចាកកាល (និព្វាន និងបញ្ញត្តិ) ។ ក្នុងសង្សារវដ្ត ដែលមិនប្រាកដខាងដើម និងខាងចុងព្រមទាំងលោកធាតុ ដែលច្រើនរកទីបំផុតមិនបាន ព្រះអង្គទ្រង់ជ្រាបដោយសព្វគ្រប់ទាំងអស់ ប្រៀបបីដូចកែវមណីក្នុងព្រះហស្តដូច្នោះឯង ។

ដោយសេចក្តីថា « ធម៌ទាំងពួង រមែងមកប្រាកដក្នុងសំណាញ់ព្រះញាណរបស់ព្រះដ៏មានព្រះភាគ » ។





# ព្រះធម៌

ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង គឺជាគោលនៃសេចក្តីពិត ជាគោលនៃសេចក្តីល្អ ដែលព្រះអង្គទ្រង់បានរកឃើញ ហើយណែនាំទូន្មានប្រៀនប្រដៅ ។

អ្នកមានទូវសទ្ធា គប្បីស្តាប់ដោយល្អ រៀនដោយល្អ យកមកពិចារណាដោយយោនិសោមនសិការ ឱ្យយល់ត្រឹមត្រូវតាមសេចក្តីពិត ដើម្បីនឹងបដិបត្តិឱ្យជាផ្លូវ (មគ្គ) និងឱ្យសម្រេចជាផលតទៅ (អ្វីដែលព្រះអង្គទ្រង់ត្រាស់សម្តែង គឺជាបរិយត្តិធម៌ ពាក្យថា ធម៌ គឺអរិយសច្ចធម៌ ជាគោលនៃសេចក្តីពិត) ។

**ធម្ម:** គឺសភាវៈទ្រទ្រង់

***សួរ***_ ទ្រទ្រង់អ្នកណា ?

**ឆ្លើយ**_ ទ្រទ្រង់អ្នកដែលតាំងនៅក្នុងធម៌ ដូចព្រះពុទ្ធវចនៈថា « **ធម្មោ ហវេ រក្ខតិ ធម្មចារី** = ធម៌ រមែងរក្សានូវអ្នកប្រព្រឹត្តធម៌ » ។

***សួរ***_ ទ្រទ្រង់យ៉ាងណា ?

**ឆ្លើយ**_ ទ្រទ្រង់មិនឱ្យធ្លាក់ទៅអបាយភូមិ ៤ និងទុក្ខក្នុងវដ្ដៈ

ដូចព្រះពុទ្ធវចនៈ ថា « **ន ទុគ្គតឹ គច្ឆតិ ធម្មចារី** = អ្នកប្រព្រឹត្តធម៌ នឹងមិនទៅកាន់ទុគ្គតិ ។ **ធម្មចារី សុខំសេតិ** = អ្នកប្រព្រឹត្តធម៌ រមែងនៅជាសុខ ។ **ធម្មោ សុចិណ្ណោ សុខមាវហាតិ** = ធម៌ដែលប្រព្រឹត្តល្អហើយ រមែងនាំសុខមកឱ្យ » ។

***សួរ***. អ្វីជាការទ្រទ្រង់ ?

***ឆ្លើយ***. ការកម្ចាត់នូវកិលេស ដែលកិលេសនោះធ្វើឱ្យសត្វធ្លាក់ក្នុងអបាយ និងឱ្យស្ថិតនៅក្នុងទុក្ខនៃវដ្ដៈ ។

ក្នុងសេចក្ដីដូចដែលសម្ដែងហើយនេះ អរិយមគ្គ និងព្រះនិព្វាន ឈ្មោះថា **ធម្ម** ព្រោះអរិយមគ្គ មានព្រះនិព្វានជាអារម្មណ៍ក្នុងការកម្ចាត់បង់នូវកិលេស ។ ធម៌ ៥ យ៉ាង គឺមគ្គ ៤ និងព្រះនិព្វាន ១ នេះ ឈ្មោះថា **ធម្ម** គឺសភាវៈទ្រទ្រង់ដោយត្រង់ ។

ព្រះបរិយត្តិធម៌ជាហេតុនៃការទ្រទ្រង់ ឯអរិយផល ៤ ជាផលនៃការទ្រទ្រង់ ។ ធម៌ទាំង ៥ យ៉ាង គឺផល ៤ និងព្រះបរិយត្តិធម៌ ១ នេះ ឈ្មោះថា **ធម្ម** គឺសភាវៈទ្រទ្រង់ដោយបរិយាយ (និប្បរិយាយ ≠ បរិយាយ)។

ម្យ៉ាងទៀត **ធម្ម** គឺសភាវៈដែលបុគ្គលគប្បីទ្រទ្រង់ទុកពោលគឺ គួរដល់ការទ្រទ្រង់ ។

***សួរ***. ព្រោះហេតុអ្វីទើបគួរដល់ការទ្រទ្រង់ ?





***ឆ្លើយ***. ព្រោះ **ធម្ម** ជាសភាវៈរំដោះនូវអ្នកដែលតាំងនៅក្នុងធម៌ ឱ្យផុតចាកទុក្ខ បានដល់ផលសុខ និងនិព្វានសុខ ។

***សួរ***. ធម៌នោះជាអ្វី ?

***ឆ្លើយ***. គឺ មគ្គ ៤ ផល ៤ ព្រះនិព្វាន ១ និងព្រះបរិយត្តិធម៌ ១ ។

ពួកធម៌ខ្លះ (មគ្គ ៤) បុគ្គលគប្បីទ្រទ្រង់ដោយការអប់រំចិត្ត ពួកធម៌ខ្លះ (ព្រះនិព្វាន) បុគ្គលគប្បីទ្រទ្រង់ដោយការធ្វើឱ្យជាក់ច្បាស់ ពួកធម៌ខ្លះ (ផល ៤) បុគ្គលគប្បីទ្រទ្រង់ដោយការនៅជាសុខក្នុងអត្តភាពបច្ចុប្បន្ន ពួកធម៌ខ្លះ (ព្រះបរិយត្តិធម៌) បុគ្គលគប្បីទ្រទ្រង់ដោយការសិក្សារៀនសូត្រចាំទុក ។

បដិបត្តិធម៌ ជាបដិបទាដើម (បុព្វភាគ) របស់មគ្គចាត់ចូលក្នុងមគ្គ ដូចបុព្វចេតនារបស់ទាន ដែលរាប់ចូលក្នុងទាន ដូច្នោះឯង ។

# ព្រះសង្ឃ

ព្រះសង្ឃ គឺពួកជនអ្នកបដិបត្តិតាមមគ្គ និងអ្នកសម្រេចផល ដែលអ្នកមានសទ្ធាទុកចិត្តមាំថា ជាសង្គមដ៏ប្រសើរ ឬជាពួកជនដ៏ប្រសើរ ដែលគួរសាងឱ្យកើតមានឡើង និងដែលខ្លួនអាចមានចំណែករួមផងបានដែរ ដោយការបដិបត្តិតាមមគ្គ និងការសម្រេចផលនោះ ដែលផ្ដើមដោយការបដិបត្តិតាមលក្ខណៈគំរូ ឬលក្ខណៈវិនិច្ឆ័យតាមធម៌វិន័យ ដែលមានភាពប្រាកដមកខាងក្រៅ គឺវិន័យ ការព្រមព្រៀង និងភាពជាកល្យាណមិត្តដល់គ្នា ។ ការមានកល្យាណមិត្តក្ដី ការមាននូវយោនិសោមនសិការក្ដី ការបដិបត្តិតាមមគ្គក្ដី រមែងចម្រើនរុងរឿងបានផលល្អ គឺស្ថិតនៅក្នុងសង្គមដែលប្រព្រឹត្តទៅតាមគតិនៃ សង្ឃនោះ ។





# ឧបមាព្រះរតនត្រៃ ២២ យ៉ាង

## អដ្ឋកថា ខុទ្ទកនិកាយ ខុទ្ទកបាឋ

១-ព្រះពុទ្ធប្រៀបដូចជាព្រះចន្ទពេញបូណ៌មី ព្រះធម៌ប្រៀបដូចជារស្មីនៃព្រះចន្ទ ព្រះសង្ឃប្រៀបដូចជាលោកដែលស្រស់បស់ដោយរស្មីនៃព្រះចន្ទពេញបូណ៌មីនោះ ។

២-ព្រះពុទ្ធប្រៀបដូចជាដួងអាទិត្យ ព្រះធម៌ប្រៀបដូចជារស្មីនៃព្រះអាទិត្យ ព្រះសង្ឃប្រៀបដូចជាលោកដែលដួងអាទិត្យកម្ចាត់ភាពងងឹតហើយ ។

៣-ព្រះពុទ្ធប្រៀបដូចជាអ្នកដុតព្រៃ ព្រះធម៌ដុតព្រៃ គឺកិលេស ប្រៀបដូចជាភ្លើងដុតព្រៃ ព្រះសង្ឃដែលជាបុញ្ញក្ខេត្ត ព្រោះដុតកិលេសបានហើយ ប្រៀបដូចជាភូមិភាគដែលជាស្រែ ព្រោះដុតព្រៃអស់ហើយ ។

៤-ព្រះពុទ្ធប្រៀបដូចជាមហាមេឃដែលឱ្យនូវភ្លៀង ព្រះធម៌ប្រៀបដូចជាទឹកភ្លៀង ព្រះសង្ឃអ្នករម្ងាប់នូវលំអងកិលេស ប្រៀបដូចជាជនបទ ដែលរម្ងាប់នូវលំអងធូលី ព្រោះភ្លៀងធ្លាក់ ។

៥.ព្រះពុទ្ធប្រៀបដូចជាសារថីដ៏ប្រសើរ ព្រះធម៌ប្រៀបដូចជាឧបាយសម្រាប់បង្ហឹកសេះអាជានេយ្យ ព្រះសង្ឃប្រៀបដូចជាហ្វូងសេះអាជានេយ្យ ដែលហ្វឹកហាត់ល្អហើយ ។

៦.ព្រះពុទ្ធប្រៀបដូចជាអ្នកដកព្រួញ ព្រោះទ្រង់ដកសរ គឺទិដ្ឋិបានអស់ ព្រះធម៌ប្រៀបដូចជាឧបាយដកសរចេញបាន ព្រះ-សង្ឃអ្នកដែលត្រូវដកសរគឺទិដ្ឋិចេញបានហើយ ប្រៀបដូចជាជនដែលត្រូវដកសរចេញបាន ។

៧.ព្រះពុទ្ធប្រៀបដូចជាពេទ្យភ្នែក ព្រោះទ្រង់បកស្រទាប់មោហៈចេញបានហើយ ព្រះធម៌ប្រៀបដូចឧបាយជាគ្រឿងបកភ្នែក ព្រះសង្ឃមានស្រទាប់ភ្នែកបកហើយ មានភ្នែកគឺញាណដ៏ភ្លឺថ្លាប្រៀបដូចជាជនដែលបកភ្នែកហើយមានភ្នែកភ្លឺ ។

៨.ព្រះពុទ្ធប្រៀបដូចជាពេទ្យដ៏ពូកែ ព្រោះទ្រង់អាចកម្ចាត់នូវព្យាធិ គឺកិលេស ព្រមទាំងអនុស័យចេញបាន ព្រះធម៌ប្រៀបដូចជាថ្នាំដែលផ្សំត្រឹមត្រូវហើយ ព្រះសង្ឃដែលមានព្យាធិ គឺកិលេស និងអនុស័យរម្ងាប់ហើយ ប្រៀបដូចជាពពួកជនដែលមានព្យាធិរម្ងាប់ហើយ ព្រោះគបនឹងថ្នាំ ។



៩.ព្រះពុទ្ធប្រៀបដូចជាអ្នកចង្អុលផ្លូវ ព្រះធម៌ប្រៀបដូចជាផ្លូវល្អ គឺផ្លូវដែលសម្រាប់រួចផុតពីភ័យ ព្រះសង្ឃប្រៀបដូចជាអ្នកដើរផ្លូវដល់ទីដែលផុតភ័យ ។

១០.ព្រះពុទ្ធប្រៀបដូចជាអ្នកអុំទូកដ៏ចំណាន ព្រះធម៌ប្រៀបដូចជាទូក ព្រះសង្ឃប្រៀបដូចជាអ្នកដើរផ្លូវបានដល់ត្រើយ ។

១១.ព្រះពុទ្ធប្រៀបដូចជាព្រៃហិមពាន្ត (ព្រៃដែលមានទឹកសន្សើម) ព្រះធម៌ប្រៀបដូចជាឱសថដែលកើតនៅព្រៃហិមពាន្តនោះ ព្រះសង្ឃប្រៀបដូចជាជនអ្នកមិនមានរោគព្រោះប្រើថ្នាំ ។

១២.ព្រះពុទ្ធប្រៀបដូចជាអ្នកប្រទានទ្រព្យ ព្រះធម៌ប្រៀបដូចជាទ្រព្យ ព្រះសង្ឃអ្នកបានអរិយទ្រព្យមកដោយប្រពៃ ប្រៀបដូចជាជនអ្នកបានទ្រព្យតាមបំណង ។

១៣.ព្រះពុទ្ធប្រៀបដូចជាអ្នកចង្អុលកំណប់ទ្រព្យ ព្រះធម៌ប្រៀបដូចជាកំណប់ទ្រព្យ ព្រះសង្ឃប្រៀបដូចជាជន អ្នកបានកំណប់ទ្រព្យ ។

១៤.ព្រះសម្មាសម្ពុទ្ធ ជាវីរបុរស ប្រៀបដូចជាអ្នកប្រទាននូវការមិនមានភ័យ ព្រះធម៌ប្រៀបដូចជាការមិនមានភ័យ ព្រះ-សង្ឃដែលរួចពីភ័យគ្រប់យ៉ាង ប្រៀបដូចជាជនអ្នកដល់នូវការមិនមានភ័យ ។

១៥.ព្រះពុទ្ធប្រៀបដូចជាអ្នកលួងលោម ព្រះធម៌ប្រៀបដូចជាការលួងលោម ព្រះសង្ឃប្រៀបដូចជាជនអ្នកត្រូវលួងលោម។

១៦.ព្រះពុទ្ធប្រៀបដូចជាមិត្តល្អ ព្រះធម៌ប្រៀបដូចជាពាក្យដាស់តឿនដែលជាពាក្យមានប្រយោជន៍ ព្រះសង្ឃប្រៀបដូចជាជនអ្នកជួបប្រសព្វនូវប្រយោជន៍ ព្រោះធ្វើតាមពាក្យរបស់មិត្តល្អ ។

១៧.ព្រះពុទ្ធប្រៀបដូចជាអណ្តូង នាំឱ្យកើតទ្រព្យ ព្រះធម៌ប្រៀបដូចជាទ្រព្យដែលមានសារៈ ព្រះសង្ឃប្រៀបដូចជាជនអ្នកប្រើទ្រព្យដែលជាសារៈ ។

១៨.ព្រះពុទ្ធប្រៀបដូចជា អ្នកស្រោចទឹកងូតឱ្យព្រះរាជកុមារ ព្រះធម៌ប្រៀបដូចជាទឹកស្រោចស្រពលើព្រះរាជកុមារតាំងពីព្រះសីសៈចុះមក ព្រះសង្ឃអ្នកបានទទួលនូវការស្រោចស្រពទឹកល្អហើយ ដោយទឹកគឺព្រះសទ្ធម្ម ប្រៀបដូចជាក្រុមព្រះរាជកុមារដែលបានស្រង់ទឹកល្អហើយ ។

១៩.ព្រះពុទ្ធប្រៀបដូចជាជាងធ្វើគ្រឿងប្រដាប់ ព្រះធម៌ប្រៀបដូចជាគ្រឿងប្រដាប់ (អលង្ការ) ព្រះសង្ឃជាអ្នកប្រដាប់ដោយព្រះសទ្ធម្ម ប្រៀបដូចជាព្រះរាជឱរសទាំងឡាយដែលទ្រង់ប្រដាប់ហើយ ។





២០.ព្រះពុទ្ធប្រៀបដូចជាដើមចន្ទន៍ ព្រះធម៌ប្រៀបដូចជាក្លិនដែលកើតអំពីខ្លឹមចន្ទន៍នោះ ព្រះសង្ឃបានរម្ងាប់នូវសេចក្តីក្តៅក្រហាយចិត្តដោយព្រះសទ្ធម្ម ប្រៀបដូចជាជនអ្នករម្ងាប់នូវភាពក្តៅផ្លូវកាយ ព្រោះប្រើលំអិតខ្លឹមចន្ទន៍នោះឯង ។

២១.ព្រះពុទ្ធប្រៀបដូចជាបិតា អ្នកចែកទ្រព្យមរតកប្រកបដោយធម៌ ព្រះធម៌ប្រៀបដូចជាទ្រព្យមរតក ព្រះសង្ឃអ្នកទទួលនូវទ្រព្យមរតកគឺព្រះសទ្ធម្ម ប្រៀបដូចជាបុត្រទាំងឡាយដែលជាអ្នកទទួលនូវទ្រព្យមរតក ។

២២.ព្រះពុទ្ធប្រៀបដូចជាផ្កាឈូកដែលរីក ព្រះធម៌ប្រៀបដូចជាលំអងកេសរ ដែលកើតក្នុងផ្កាឈូកនោះ ព្រះសង្ឃប្រៀបដូចជាពួកភមរជាតិ (មានសត្វឃ្មុំជាដើម ) ដែលក្រេបយកលំអងកេសរ ក្នុងផ្កាឈូក ។

គប្បីប្រកាសព្រះសរណត្រ័យនោះ ដោយសេចក្តីឧបមាទាំងឡាយដូចពោលមកនេះឯង ។

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
## ក្នុងការខាររធម្មទាន

១. ឧបាសក សំរ៉ង វ័ណ្ណ ២. ឧបាសក យន្ត សួន

៣. ឧបាសក គួង លាងផេង ៤. ឧបាសក មួង យេន

៥. លោកគ្រូ រស់ សូផាត ៦. ឧបាសក អ៊ិត ប្រាំង

៧. នាង ជា សុណារី ៨. នាង ឃុន សូនីម៉ា

៩. ឧបាសិកា ហួនចាន់បូដា ១០.ឧបាសក វ៉ាន់ ខុនណា

១១. ឧបាសក គុយ សុធន ១២.ឧបាសក ជឹង វ៉េងអ៊ាវ

១៣. ឧបាសក ជឹម ជំនិត ១៤.ឧបាសក ហាយ ចំរើន

១៥. ឧបាសិកា ប៊ុត ម៉ាលី ១៦.ឧបាសិកា ហាយ ច័ន្ទធីរី

១៧. លោកគ្រូ ជូ ប៊ុនយូ ១៨.លោកគ្រូ លាក់ តុង

១៩. ឧបាសក ង៉ូវ គា

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈

## រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
## ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

១. ឧ.ស. យូស៊ាង-ងួនលី និង ឧ.សិ. លីម-ឃីម ............. ស.រ.អ.

២. ឧ.ស. ឆាយ-អ៊ីវស៊ាង និងឧ.សិ.ហុង-គឹមសែ ..............ស.រ.អ.





៣. ឧ.ស. ឆាយអ៊ីវ-ស្រេងលីម និងឧ.សិ.ហួត-ឃីម............ស.រ.អ.

៤. ឧ.ស. ហៃ-ប៊ុនណារិន និងឧ.សិ.អោង-ស៊ីថាន់ ............ស.រ.អ.

៥. ឧ.ស. ហៀប-បេ និងឧ.សិ. ឡៅ-កែវម្លិះ ..................ស.រ.អ.

៦. ក្រុមឧ.ស. ឈុំ-កុសល និងឧ.ស. អ៊ុន-ឆាយគ្រី.............ស.រ.អ.

៧. ក្រុមឧ.ស. លឹម -ស៊ាង ( ហៅ ទូច ) ................. ស.រ.អ.

៨. ឧ.ស. យន្ត-សួន ឧ.សិ. តាំង ឈុងប៊ួយ និងបុត្រ ............ ភ.ព.

៩. ឧ.ស.ប៊ុន-ហេង ឧ.សិ.ជុំ-សុខុម ព្រមទាំងបុត្រ............អូស្ត្រាលី

១០. ឧ.សិ.ឱម-លក្ខណា ព្រមទាំងបុត្រធីតា .................. អូស្ត្រាលី

១១. លោក យូណូស អាស៊ីស អ្នកស្រី ហុក ណារី +បុត្រ ..........បារាំង

១២. ឧ.ស.ង៉ូវ ជួនណារេត ឧ.សិ.ង៉ូវ សោភ័ណ+បុត្រ..........បារាំង

១៣. ឧ.ស. ម៉ៅ វង់ និង ឧ.សិ. ឆាន់ កាន់ជួង .............ស.រ.អ.

១៤. ឧកញ៉ាមហាឧ.សិ.ញឹក ប៊ុនថា និង ឧ.សិ.ម៉ែន-សុភារី........ ភ.ព.

១៥. ឧ.សិ. ច័ន្ទ-បុប្ផាណា ព្រមទាំងបុត្រធីតា .................ភ.ព.

១៦. ឧ.សិ. អ៊ា នៅ ព្រមទាំងបងប្អូនកូនចៅ ............. កាណាដា

១៧. ឧ.ស. អ៊ុត-ឆៃវ៉ាន ឧ.សិ. ធាន ស៊ុនលី និងបុត្រ...................... ស.រ.អ.

១៨. ឧ.ស. ប្លោក-ងួនថៃ ឧ.សិ.ធាន ត្រលុច និងបុត្រ ...........ស.រ.អ.

១៩. ឧ.ស. ឡុក ប៊ុនអ៊ីវ និងឧ.សិ.តាន់ ស៊ីវឡាង+បុត្រ .......... បារាំង

២០. ឧ.សិ.ប៊ិតថងខាំ និង ឧ.សិ.សាន គីន +ឧ.សិ.សានផល្លីន...... ប.ប.

២១. ឧ.ស. យូ ម៉េង ......................................ក.ព.ស.

២២. ឧ.ស.ម៉ៅ-សុគន្ធ ឧ.សិ.អ៊ឹង-យ៉េកហួយ និងបុត្រ............ភ.ព.

២៣. ឧ.សិ. អ៊ឹង-យ៉េកសាង ព្រមទាំងបុត្រ ..................... បារាំង

២៤. ឯ.ឧ. អ៊ិត.ប្រាំង និង ជ.ទ.ញ៉ែម.សេដ្ឋា +បុត្រ............. ភ.ព.
២៥. ឯ.ឧ. ងី តាយី និង ជ.ទ. ហេង មុនីវ័ន្ន +បុត្រ ............... ភ.ព.
២៦. ឯ.ឧ.ចែម វីឌ្យ៉ា និង ជ.ទ.សុខា ស៊ូលីវណ្ណ +បុត្រ ............. ភ.ព.
២៧. ឯ.ឧ.ឧកញ៉ា ប៊ុត គឹមស៊ាន និង ជ.ទ.ឈួន ទូច +បុត្រ ....... ប.ប.
២៨. ឯ.ឧ.ប៉ុល.នាង និង ជ.ទ.គ្រៀល.ស៊ីយ៉ា +បុត្រ............... ភ.ព.
២៩. ឧ.ស. ស៊ិន សុខា និងឧ.សិ. សុខា ផល្លី និងបុត្រ ............. ភ.ព.
៣០. ឧ.សិ. ស៊ីវ យក់លុយ ..................................... ស.រ.អ.
៣១. ឧ.ស. ស៊ីវ សៅវ៍ និង ឧ.សិ. ស្រៀង រ៉ូចលាង
៣២. ឧ.សិ.ហេង.ស៊ីវខេង +ម្តាយឈ្មោះ អៀង.ហ្គិច ...........កណ្តាល
៣៣. ឧ.ស.យឹម.ស៊ីមុន្នី ឧ.សិ.យូ.ប៉ូលីន និងបុត្រ ................. ភ.ព.
៣៤. ឧ.ស. ឡាយ.សុខុម ឧ.សិ. សួន.ចន្ថា និងបុត្រ ...............ភ.ព.
៣៥. ឧ.ស.ងឹម.ញាណ ឧ.សិ. កាំង.ប៉ូលីន និងបុត្រ ............ក.ព.ស.
៣៦. ឧបាសិកា អ៊ំ.អ៊ន់
៣៧. ឧ.សិ. ប៉ូអាន.ស៊ីវុត្ថា ....................................... ភ.ព.
៣៨. ឧ.សិ. ប៉ូ ផាវ៉ាណ ..........................................ភ.ព.
៣៩. ឧ.សិ. ម៉ៅ សុន្ថា ..............................................ភ.ព.
៤០. ឧ.សិ. សាក់.ស៊ាងអេង ព្រមទាំងបុត្រ
៤១. ឧ.សិ. ជា.ផាត ព្រមទាំងបុត្រ
៤២. ឧ.ស.ស្វ ហុកឡុង ឧ.សិ.កាន់ ឈីវហា .................. ស.រ.អ.
៤៣. ឧបាសិកា គា.ស៊ីន ........................................... ប.ប.
៤៤. ឧបាសិកា អ៊ឹង ស៊ីវន ......................................ស.រ.អ.



៤៥. ឧ.ស.អ៊ុក.សាម៉ាណារ៉ា ឧ.សិ.ហ៊ាប.តេង និងបុត្រ............ភ.ព.
៤៦. ឧ.ស. ម៉ៅ.ស្រ៊ិន ឧ.សិ. ទូច.ស៊ីនហ៊ន និងបុត្រ................ភ.ព.
៤៧. ឧ.ស.ពុធ.ប៉ោលាង ឧ.សិ. ហ៊ុន.ស៊ីវអៀង ................កាណាដា
៤៨. Chhem Sokreth et Puth Kunthea .................កាណាដា
៤៩. ឧ.ស. ឡោ សេងជ្រុន ឧ.សិ.ផាំង លី និងបុត្រ................បារាំង
៥០. ឧ.ស. ម៉ែន.សឿន ឧ.សិ. អៀង ណារី និងបុត្រ ..............ភ.ព.
៥១. ឧ.សិ. សយ វណ្ណា និង ស្វាមី ព្រមទាំងបុត្រ ..................ភ.ព.
៥២. ឧ.សិ.ហេង បូរីស្រីនាថ និង កូនឯមភក្តី +ភរិយា +បុត្រ .....ភ.ព.
៥៣. ឧ.សិ. ចំណាន ព្រមទាំងក្រុមគ្រួសារ ......................កាណាដា
៥៤. ឧ.សិ. លី វន ព្រមទាំងក្រុមគ្រួសារ .......................កាណាដា
៥៥. ឧ.ស. ហួន ប៉ាន់ ឧ.សិ. ថៃ នាថ និងបុត្រ
៥៦. លោក ស៊ា រស់ អ្នកស្រី ញ៉េប ដារ៉េត និងបុត្រ
៥៧. លោក រឿង សេដ្ឋា អ្នកស្រី នាង ជួនអេង និងបុត្រ
៥៨. លោក សែន.សុវណ្ណរិទ្ធ និងភរិយា .............................ភ.ព.
៥៩. ឧ.ស. ប៉ូច បូរី ព្រមទាំងបុត្រ
៦០. ឧ.ស. អៀង ឆាយ និងឧ.សិ. អៀ.កេសរ +បុត្រ.............ស.រ.អ.
៦១. លោកតា តាន់.ឈីវហា និងលោកយាយ ស៊ូ.ចិន្ត្រា
៦២. ឧ.សិ. តែ.សាយជូ ព្រមទាំងកូនចៅ
៦៣. ឧ.សិ. តាន់.ជាលី និងពុទ្ធបរិស័ទខេត្តសៀមរាប ............... ស.រ.
៦៤. ឧ.សិ. ឯម សុខន ព្រមទាំងបុត្រ និងចៅ ...................... ភ.ព.
៦៥. ឧ.សិ. ម៉ិល.យ៉េម ....................................... ..ស.រ.អ.

៦៦. ឧ.សិ. កង.ភឹម
៦៧. ឧ.សិ. ម៉ក់.នាង
៦៨. ពុទ្ធបរិស័ទ ចាន់ នារីសុខ និងក្រុមគ្រួសារ ................... ស.រ.អ.
៦៩. ពុទ្ធបរិស័ទ ភឿក.កុំ
៧០. ឧ.សិ. ជុំ ឆាយ
៧១. ឧ.សិ. ស៊ីវ យក់លី ........................................... ភ.ព.
៧២. ឧ.ស. ជាន យ៉ែត ឧ.សិ. សុក ចេង ព្រមទាំងបុត្រ ............ភ.ព.
៧៣. ឧ.ស. សោម រតនៈ ឧ.សិ. ស៊ិប វណ្ណា ព្រមទាំងបុត្រ ......... ព.វ.
៧៤. ឧ.ស. ហេង សម្បូរជ្ឈ ឧ.សិ. ស៊ិនគន្ធា ........................ ភ.ព.
៧៥. ញោមប្រុស និង ញោមស្រីរបស់សាមណេរ ជា សុភក្រ្ត .......ភ.ព.
៧៦. ឧ.ស.សារឿន ឧ.សិ.លាប+ឧ.ស.ហ៊ីស៊ី ឧ.សិ.អាន......... ស.រ.អ.
៧៧. លោក សួន បូភា អ្នកស្រី ហួន ចាន់ផូ ព្រមទាំងបុត្រ
៧៨. លោកស្រី ហ៊ុយ សុខម៉ា និងស្វាមី ព្រមទាំងបុត្រ
៧៩. ឧបាសក តាំង ស៊ុនម៉ាប
៨០. ឧបាសិកា ចៅ សារ៉ូន
៨១. ឧបាសិកា ឱប រះ ...................................... ...ស.រ.អ.
៨២. ឧ.ស.គង់ សុគន្ធ ហៅផូគឹមសែ +បុត្រីគន្ធច័ន្ទដារា.............ភ.ព.
៨៣. ឧ.សិ. វណ្ណ មុនី ព្រមទាំងបុត្រ និងចៅ ...................... ភ.ព.
៨៤. ឧ.សិ. លឹម ប៊ូ ព្រមទាំងបុត្រធីតា
៨៥. ឧ.សិ. ឈុន លន
៨៦. ឧ.ស. ស៊ុយ ជូ និងឧ.សិ. តាំង ទៀង



៨៧. ឧ.សិ. ព្រុំ សុភាព ........................................... ភ.ព.
៨៨. ឧ.ស.ហេង គឹមរិន ឧ.សិ. ហោ ចន្ធូ ព្រមទាំងបុត្រ...........បារាំង
៨៩. ឧ.សិ. សុខ ភួង និង ឧ.សិ. សុខ ផៃ
៩០. ឧ.សិ. អួន ញ៉ ឧ.សិ. រស់ លីនណា និងបុត្រ ................ស.រ.អ.
៩១. លោក ចក់ ឈុន និង អ្នកស្រី វណ្ណារី សុខ
៩២. ឧ.សិ. អ៊ុក លន់ និងក្រុមវេន ព្រមទាំងបុត្រ ...................ភ.ព.
៩៣. ឧ.សិ. ជា គឹមហឿន ព្រមទាំងបុត្រ
៩៤. ឧបាសិកា អ៊ីវ ថា ព្រមទាំងក្មួយ និងចៅ
៩៥. ឧបាសិកា ឈុន តាំងសៀក ព្រមទាំងបុត្រ និងចៅ
៩៦. ឧ.សិ. ជា ម៉ាក់លាង
៩៧. ឧ.ស.ហ្វាន់ វ៉ាន់ហូ និងឧ.សិ.ហ្វាន់ យូលាង................... បារាំង
៩៨. ឧ.ស.លឹម ធីនសូ ឧ.សិ. អ៊ឹង ឆាយហូ +បុត្រ. ..............អូស្រ្តាលី
៩៩. ឧ.ស.ឡុង អ៊ាងលី ឧ.សិ. សេង ចិន្តា +បុត្រ ............... អូស្រ្តាលី
១០០. ឧ.សិ. ទិត នាង ............................................អូស្រ្តាលី
១០១. ឧ.ស. ប៉ុច រឿត ឧ.សិ.ញូង ស៊ាងម៉េង +បុត្រ ............អូស្រ្តាលី
១០២. ឧ.ស.ខ្វង ឆែម ឧ.សិ.អ៊ុយ អ៊ាត និងបុត្រ ....
១០៣. ឧ.ស. ឌឿ សេង ឧ.សិ.លឹម យី និងបុត្រ .....
១០៤. ឧ.ស. សុខ សារឿន ឧ.សិ.ទូច ម៉ុម និងបុត្រ ..
១០៥. ឧ.សិ. ទូច លឹមអាំង និងឧ.សិ.ទូច សុផានី .....
១០៦. ឧ.សិ. គង់ ម៉ៃ ច្បារអំពៅ .................................. ភ.ព.
១០៧. ឧ.ស. កែវ ឆាត ឧ.សិ.កាន គីរីសុខា +កូនចៅ ..

១០៨. លោកយាយ ពិន សាត .................................. ស.រ.អ.

១០៩. លោក ចាន់ ម៉ល់ និងអ្នកស្រី ជា សុផា ....................ស.រ.អ.

១១០. ភិក្ខុ ឈម បូ (វិជ្ជាសម្បទា )................................ស.រ.អ.

១១១. ឧ.ស.ឈឹម ហុកអ៊ាន .......................................បារាំង

១១២. ឧ.សិ.មុំ ទូច និងកូនឧ.សិ.សាមុល គឹមធន់ ................. ភ.ព.

១១៣. លោក ងួន បាន និងអ្នកស្រី លិន ដាណារី ............... ស.រ.អ.

១១៤. ឧ.សិ.រស់ សេរី និងឧ.សិ.សឿ ចន្ថា

១១៥. ឧ.សិ.លី ស៊ីវជូ ព្រមទាំងបុត្រ ......................... ភ.ព.

១១៦. ក្រុមគ្រួសារឧ.សិ. ឈ គឹមស៊ីន .............................អូស្ត្រាលី

១១៧. ក្រុម ឧ.ស.អ៊ុច សុខុន វេនប្រចាំខែវត្តសុវណ្ណបទុម .......... ភ.ព.

១១៨. ក្រុមឧ.ស. មួង .យេន វត្តសំពៅមាស ....................ភ.ព.

១១៩. ក្រុមឧ.ស. ផាន់. សារី វត្តទួលទំពូង ....................... ភ.ព.

១២០. ក្រុមវេនចង្ហាន់ ១កើតសំពៅមាស ៦កើតចំបក់មានជ័យ
១១កើតសុវណ្ណបទុម ១រោចធុតង្គ ៦រោចនិគ្រោធវ័ន
១០រោចវេឡុវ័ន ...............................................ភ.ព.

១២១. មណ្ឌលសិក្សាព្រះពុទ្ធសាសនាមណីរត្ន ខេត្តពោធិ៍សាត់ ..... ព.ស.

១២២. ក្រុមពុទ្ធបរិស័ទនៅទីក្រុងស៊ីតនី ប្រទេសអូស្ត្រាលី ....... អូស្ត្រាលី

១២៣. ក្រុមពុទ្ធបរិស័ទស្រុកមង្គលបូរី និងស្រុកសិរីសោភ័ណ .... ប.ម.ជ.

១២៤. ក្រុមពុទ្ធបរិស័ទចិត្តបុណ្យក្នុងសហគមន៍ធម្មទាន

≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈≈





## នាមពុទ្ធបរិស័ទដែលមានសទ្ធា
## បរិច្ចាគប្រាក់បោះពុម្ពសៀវភៅនេះ

| | | |
|---|---|---|
| ១- | ប្រាក់សល់ពីបោះពុម្ព សៀវភៅ បទពិចារណា ........................ | ៤៩៧៥ $ |
| ២- | ឧ.ស.ជូ គីមសែ ព្រមទាំងបុត្រី ជូ ស៊ីវគាង ........................ | ៥០០ $ |
| ៣- | ឧ.សិ.ឱម លក្ខណា ព្រមទាំងបុត្រធីតា ............................ | ៣០០ $ |
| ៤- | លោកយាយ លីម សូណៃ ............................................ | ២០០ $ |
| ៥- | ឧ.ស.សោម រតនៈ និង ឧ.សិ.ស៊ុប វណ្ណា ព្រមទាំងបុត្រ ........ | ១៦០ $ |
| ៦- | ឧ.សិ.អ៊ឹង ស៊ីវន ......................................................... | ១៣០ $ |
| ៧- | ឧ.ស.ចាន់ នៅ ( ហៅ ចាន់ សាមឿន)និងឧ.សិ.ជឹង ឆេង ..... | ១២៤ $ |
| ៨- | ឧ.ស.ផាន់ សារី និង ឧ.សិ.ខៀវ ណុង ព្រមទាំងបុត្រ ........... | ១១០ $ |
| ៩- | ឧ.ស.អ៊ី សុងលាង និងឧ.សិ.ហួយ លាងស្រ៊ី ព្រមទាំងបុត្រ ... | ១១០ $ |
| ១០- | ឧ.ស.អៀម វ៉ន និងឧ.សិ. សុខ សោរិន .............................. | ១០០ $ |
| ១១- | ឧ.ស.ថោង បូរ៉ាន់+ថោង បូរ៉ុង+ថន ស៊ីថា+ថោង បូរើន+ក្មួយៗ... | ១០០ $ |
| ១២- | ឧ.ស.ពុធ ប៉ោលាង និងឧ.សិ.ហ៊ុនស៊ីវអៀង ព្រមទាំងបុត្រ ......... | ១០០ $ |
| ១៣- | M.CHHEM SOKRETH et Mme PUTH KUNTHEA ............... ... | ១០០ $ |
| ១៤- | M.SU SOKUNORA et Mme INN VISAL+NARITAetRAKSA ... | ១០០ $ |
| ១៥- | ឧ.ស.កុក ឆាយ ព្រមទាំងកូនស្រី តាំង ផល្លា និង តាំង ស៊ីថា ....... | ១០០ $ |
| ១៦- | ឯកឧត្តម អ៊ិត ប្រាំង លោកជំទាវ ញ៉ែម សេដ្ឋា និងបុត្រ ............. | ១០០ $ |
| ១៧- | ឧ.ស. ប៉ុង អាង និងឧ.សិ.អឿង លាងជុន ព្រមទាំងបុត្រ............ | ១០០ $ |
| ១៨- | ឧ.សិ.អ៊ា នៅ ព្រមទាំងកូននិងចៅ ......................................... | ១០០ $ |
| ១៩- | ឧ.សិ.លុយ ឡៃ ព្រមទាំងបុត្រ ............................................. | ១០០ $ |
| ២០- | ឧ.សិ.ស៊ុយ ជាលី ព្រមទាំងបុត្រ និងចៅ ................................ | ១០០ $ |

២១- ឧ.ស.ឃួន យ៉ា និងឧ.សិ.មាស ឡៃស្រួយ ព្រមទាំងបុត្រ ........... ១០០ $
២២- ឧ.សិ.ផាំង ស្រួយ ព្រមទាំងបុត្រ និងចៅ .............................. ១០០ $
២៣- ឧ.សិ.ហុង គី .................................................................. ១០០ $
២៤- ឧ.ស.ហ៊ុន ហេង និង ឧ.សិ.ឆាង អម ...................................... ១០០ $
២៥- លោកតា ប៉ុង អាង និងលោកយាយ អឿង លាងជុន និងបុត្រ...... ១០០ $
២៦- លោកយាយ លុយ ឡាយ .................................................. ១០០ $
២៧- ឯកឧត្តម ចែម វីឌ្យ៉ា លោកជំទាវ សុខា ស៊ូលីវណ្ណ និងបុត្រ ....... ១០០ $
២៨- ឧ.ស.កែវ សោរ ឧ.សិ.ជ័យ សុខ និង ឧ.សិ.ស្រេង ឡាំងង៉ិច ....... ១០០ $
២៩- ឧ.សិ.យិន គន្ធរី ហៅ ធឿង ព្រមទាំងបុត្រ និងចៅ .................... ១០០ $
៣០- ឧ.សិ.ពិន សាត ................................................................ ១០០ $
៣១- លោក ចាន់ ម៉ល់ និង អ្នកស្រី ជា សុផា ................................ ១០០ $
៣២- ឧ.សិ.ហុង គី .................................................................. ១០០ $
៣៣- ឧ.សិ.ច័ន្ទ បុប្ផាណា ព្រមទាំងបុត្រធីតា ................................ ១០០ $
៣៤- ឧ.ស.ហង្ស ប៊ុនឡេង និង ឧ.សិ.កែវ នាង ព្រមទាំងបុត្រ ........... ១០០ $
៣៥- ឧ.ស.អ៊ុត ឆៃវ៉ាន និង ឧ.សិ.ធាន ស៊ុនលី ព្រមទាំងបុត្រ ........... ១០០ $
៣៦- ឧ.សិ.មុយ ចេង ព្រមទាំងបុត្រ និងចៅ ................................ ១០០ $
៣៧- ឧ.សិ.តាំង ប៉ោជឹង ហៅ ចែទន់ និង ស្វាមី ព្រមទាំងបុត្រ .......... ១០០ $
៣៨- ឧ.សិ.លឹម រួចណៃ ............................................................ ១០០ $
៣៩- ឧ.សិ.ហ៊ុន សំអាត ........................................................... ១០០ $
៤០- ឧ.សិ.ស្រួ គឹមធា ព្រមទាំងបុត្រ និងចៅ ................................ ១០០ $
៤១- ក្រុមវេនចង្ហាន់ព្រះសង្ឃថ្ងៃ ១ កើត វត្តធុតង្គ ចំការដូង ........... ៨៥ $
៤២- ឧ.សិ.អ៊ុន សាងឿន .......................................................... ៧៥ $
៤៣- ព្រះសង្ឃ និងឧ.សិ.ស៊ីវ ឡេង +ពុទ្ធបរិស័ទ .......................... ៧០ $
៤៤- ឯកឧត្តម ប៉ុល នាង លោកជំទាវ គ្រៀល ស៊ីយ៉ា ព្រមទាំងបុត្រ.. ៧០ $





៤៥- ឧ.ស.ង៉ូវ គា និង ឧ.សិ.ឈុន គឹមអេង ព្រមទាំងបុត្រ .......... ៦០ $
៤៦- ឧ.ស.ឡោ សេងជ្រុន និងឧ.សិ.ផាំង លី ព្រមទាំងបុត្រ ....... ៥០ $
៤៧- ឧ.ស.ខឹប ឡូយហៀង និងឧ.សិ. ខៀវ ស៊ីនួន .................. ៥០ $
៤៨- ឧ.សិ. ណាំ ប្រាង ព្រមទាំងបុត្រ .................................. ៥០ $
៤៩- លោកយាយ ជា យន .............................................. ៥០ $
៥០- លោកតា ហ៊ុន ហេង និងលោកយាយ ឆាង រ៉ម ព្រមទាំងកូនចៅ ៥០ $
៥១- ឧ.ស.សូ មាំង និងឧ.សិ.សូ ពៅ ព្រមទាំងញាតិមិត្ត ............. ៥០ $
៥២- ឧ.សិ.ឈឺន ណារី ព្រមទាំងបុត្រនិងចៅ .......................... ៥០ $
៥៣- ឧ.សិ.ច័ន្ទ សុម៉ាលី .................................................. ៥០ $
៥៤- ឧ.ស.សួរ អេងឡុង និងឧ.សិ.ព្រុំ លឹមហេង .................... ៥០ $
៥៥- នាង រុនណើ ............................................................ ៥០ $
៥៦- ឧ.សិ.វ៉ា សែម ........................................................ ៥០ $
៥៧- ឧ.សិ.សាន គិន និង អ្នកគ្រូ សាន ផល្លីន ........................ ៥០ $
៥៨- ឧ.ស.លន់ គឹមស៊ុយ និង ឧ.សិ.លាង មួយហួយ ព្រមទាំងកូនចៅ ៥០ $
៥៩- ឧ.សិ.អ៊ួង ឈុនហុង ព្រមទាំងបុត្រ .............................. ៥០ $
៦០- លោក ទឹម សុខា និង លោកស្រី អៀប គន្ធា .................. ៥០ $
៦១- លោក រស់ ប៊ុនឈឿន និង ភរិយា ព្រមទាំងបុត្រ ............ ៥០ $
៦២- ឧ.ស.ជឹម អេង និងឧ.សិ.វ៉ា សុខគិន ព្រមទាំងបុត្រ .......... ៥០ $
៦៣- ឧ.សិ.តាំង ស៊ុយគីម ព្រមទាំងបុត្រ ............................. ៥០ $
៦៤- ឧ.សិ.អ៊ា គុយឡាំង ព្រមទាំងបុត្រ និងចៅៗ .................. ៥០ $
៦៥- លោកយាយ ណាំ ប្រាំង ............................................ ៥០ $
៦៦- ឧ.ស.ឡាយ សុខុម និងឧ.សិ.សួន ចន្ថា ព្រមទាំងបុត្រ ........ ៥០ $
៦៧- ឧ.សិ.តោ ឡោ ...................................................... ៥០ $
៦៨- ឧ.ស.ស៊ិន សុខា និង ឧ.សិ.សុខា ផល្លី ព្រមទាំងបុត្រធីតា .. ៥០ $

៦៩- ឧ.ស.ប៉ាន់ ហួ និង ឧ.សិ.សាំង ឡេង ព្រមទាំងបុត្រ ............ ៥០ $

៧០- ឧ.ស.ជា គុំ ហៅ ហៀង .............................................. ៥០ $

៧១- ឧ.សិ.នាង វុនទី ........................................................ ៥០ $

៧២- ឧ.សិ.វ៉ា សែម ......................................................... ៥០ $

៧៣- លោក ភឿក កុំ និង ក្រុមគ្រួសារ ................................ ៥០ $

៧៤- ឧ.សិ.ចន្ទ នារីសុខ និង ក្រុមគ្រួសារ ............................. ៥០ $

៧៥- ឧ.សិ.ម៉ិល យ៉ែម ...................................................... ៥០ $

៧៦- ឧ.ស.យន្ត សួន និង ឧ.សិ.តាំង ឈុងប៊ួយ ព្រមទាំងបុត្រ ..... ៥០ $

៧៧- ដូនជី មាតារបស់អាចារ្យ ជឹម ជុំនិត ............................................ ៥០ $

៧៨- ឧ.សិ.ស្រេង់ ឡេង .................................................... ៤៥ $

៧៩- ឧ.សិ. ជា គីមហឿន ព្រមទាំងបុត្រ ធីតា.................... ៤០ $

៨០- ឧ.សិ.អួន ញ៉ ព្រមទាំងបុត្រា ប៊ុន នី និង ភរិយា .............. ៤០ $

៨១- ឧ.សិ. ទេព យ៉ុម ព្រមទាំងកូនចៅ ................................ ៤០ $

៨២- លោកយាយ ជា នាង ............................................... ៣០ $

៨៣- ឧ.សិ.វ៉ា សួស្តី .......................................................... ៣០ $

៨៤- លោក ពេជ្រ សីហា និង អ្នកស្រី ថាប់ សុវ័ត្ន ................... ៣០ $

៨៥- ឧ.សិ.ភឹម យឹម ........................................................ ៣០ $

៨៦- ឧ.ស.អ៊ុច ជិន និង ឧ.សិ.ម៉ម សុខហេង ព្រមទាំងបុត្រនិងចៅ ៣០ $

៨៧- ឧ.សិ.ហាយ ច័ន្ទធរី .................................................. ៣០ $

៨៨- ឧ.សិ.គុយ ហៀក +បុត្រ និងឧ.ស.ពុយ ហេង +បុត្រ ........ ៣០ $

៨៩- ឧ.ស.កាន់ វ៉ាត់ ឧ.សិ.កែវ កល្យាណ និងកញ្ញា កាន់ សុថារត្ន័ ៣០ $

៩០- លោក កែម សុគន្ធ និង អ្នកស្រី ជា សុភាព .................... ៣០ $

៩១- ឧ.សិ.យោគ សំអឿន ............................................... ៣០ $

៩២- លោក ឈើវ ឃួយ និង លោកស្រី ស៊ីវ លាង ព្រមទាំងបុត្រ .. ៣០ $



៩៣- ឧ.ស.សុខ ហេង និង ឧ.សិ.ហង់ សាណាបេកា ព្រមទាំងកូនចៅ ៣០ $

៩៤- ឧ.ស.ហ្វាន់ វ៉ាន់ហ៊ួ និង ឧ.សិ.ហ្វាន់ យូលាង ព្រមទាំងបុត្រ .. ៣០ $

៩៥- ឧ.ស. លាក់ តុង និងឧ.សិ. ជួន ហម ព្រមទាំងបុត្រ .............. ២៥ $

៩៦- ឧ.សិ.ហ៊ាន់ ហេង និងឧ.សិ.មាច ផល្លា ព្រមទាំងបុត្រ ........... ២៥ $

